# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economic


## សារណាបញ្ចប់ការសិក្សា

# ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០២១ ដល់ ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **កញ្ញា ឡុង ពិសី**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឌុឆ្វី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២១ ឆ្នាំសិក្សា២០១៧-២០២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

នាងខ្ញុំឈ្មោះ **ឡុង ពិសី** សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅចំពោះលោកឪពុក **ឡុង សម្ភស្ស** និងអ្នកម្តាយ **ទិត ង៉ែត** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងប្រៀនប្រដៅដល់រូបនាងខ្ញុំប្រកបដោយព្រហ្មវិហារធម៌ និងបានចំណាយថវិកាជាច្រើនដល់រូបនាងខ្ញុំ ដើម្បីបានសិក្សារហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

នាងខ្ញុំសូមថ្លែងអំណរគុណផងដែរដល់ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយពេលវេលា ទាំងកម្លាំងកាយ កម្លាំងចិត្ត និងយកចិត្តទុកដាក់បង្ហាត់បង្រៀន ប្រៀនប្រដៅដល់រូបនាងខ្ញុំដោយព្រហ្មវិហារធម៌ រហូតបានបញ្ចប់ការសិក្សាដោយជោគជ័យ។

សូមថ្លែងអំណរគុណជាពិសេសចំពោះលោកសាស្ត្រាចារ្យ **ញឹក វុទ្ធី** ដែលលោកគ្រូ បានយកចិត្តទុកដាក់អស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ ណែនាំអំពីការសរសេរសារណានេះដល់រូបនាងខ្ញុំប្រកបដោយជោគជ័យ។

ក្រៅពីលោកសាស្ត្រចារ្យដឹកនាំក្នុងការសរសេរសារណា ក៏នៅមានសិស្សច្បង និងរាមច្បងក្នុងវិស័យការងារមួយចំនួនទៀត ដែលបានចំណាយពេលក្នុងការណែនាំ ពន្យល់ និងផ្តល់ដំបូន្មានល្អៗ ត្រង់ចំណុចណាដែលនាងខ្ញុំមិនសូវយល់បានច្បាស់លាស់ រហូតដល់សារណានេះបានលេចចេញជារូបរាងឡើង។

ជាចុងក្រោយនាងខ្ញុំ សូមប្រសិទ្ធពរជ័យ សិរីមង្គលបវរមហាប្រសើរកើតមានដល់ លោកអ្នកមានគុណ លោក-លោកស្រីសាស្ត្រាចារ្យ មន្ត្រីរាជការ បងប្អូនសាច់ញាតិ មិត្តភក្តិ ព្រមទាំងជនជាតិខ្មែរទាំងអស់ អោយជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត ពិសេសចៀសចាកឆ្ងាយពីការរីករាលឆ្លងនៃជម្ងឺកូវីដ-១៩ ដែលកំពុងតែវាយលុកខ្លាំងក្នុងប្រទេសកម្ពុជាយើង ក៏ដូចជានៅជុំវិញពិភពលោក។

# អារម្ភកថា

សារណានេះ បានតាក់តែងឡើងនៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ហើយក៏ជាឧបករណ៍មួយសម្រាប់បង្ហាញសមត្ថភាព និងចំណេះដឹងដែលបានមកពីការខិតខំប្រឹងប្រែង និងសិក្សាស្រាវជ្រាវអស់រយៈពេល ៤ ឆ្នាំនៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ។ សារណាដែលបានតាក់តែងឡើងមកនេះ គឺជាស្នាដៃថ្មីមួយទុកជាគុណប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវសម្រាប់សិស្ស-និស្សិតដែលជាសិស្សប្អូននៅជំនាន់ក្រោយៗទៀត។

ក្រោយពីប្រទេសកម្ពុជាបានទទួលនូវសន្តិភាពពេញលេញរួចមក ការអភិវឌ្ឍនានាក៏ចាប់ផ្តើមមានសន្ទុះឡើងមកវិញជាលំដាប់។ ក្នុងនោះ ការធ្វើអស្សាមិករណ៍ពិតជាបានរួមចំណែកយ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេសជាតិ ក្នុងគោលបំណង និងគោលដៅបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិឲ្យកាន់តែរីកចម្រើន។ ស្របពេលដែលមានការធ្វើអស្សាមិករណ៍នេះកាន់តែច្រើនឡើងនៅក្នុងដំណើរអភិវឌ្ឍន៍សង្គមកម្ពុជា បែរជាប្រជាពលរដ្ឋកម្ពុជាផ្ទាល់ និងសិស្ស-និស្សិតមួយចំនួន ពុំទាន់បានយល់ច្បាស់ពីការធ្វើអស្សាមិករណ៍នេះនៅឡើយ ក៏ព្រោះតែច្បាប់អស្សាមិករណ៍នេះមិនមានការផ្សព្វផ្សាយទូលំទូលាយ ដែលជួនកាលបង្កើតឲ្យមានការយល់ច្រលំថាការធ្វើអស្សាមិករណ៍ គឺជាការដកហូតដោយបង្ខំនូវកម្មសិទ្ធិឯកជនរបស់ប្រជាពលរដ្ឋទៀត។

ហេតុដូចនេះ បានជានាងខ្ញុំខិតខំស្វែងរកឯកសារដែលពាក់ព័ន្ធនានា និងបានធ្វើការពិភាក្សាជាមួយសិស្សច្បង និងរាមច្បងក្នុងវិស័យការងារមួយចំនួនទៀតដោយបំណង គឺចង់យល់ដឹងអំពីលក្ខណៈពិសេសក្នុងការធ្វើអស្សាមិករណ៍ ដំណើរការដកហូតកម្មសិទ្ធិ ការប្រកាសគម្រោង ការផ្តល់សំណង និងមានដំណើរការច្រើនទៀតដែលត្រូវធ្វើឡើងក្នុងពេលដែលមានការធ្វើអស្សាមិករណ៍។ ប្រធានបទស្តីពី **"ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា"** នឹងក្លាយជាឧបករណ៍មួយសម្រាប់ធ្វើការពង្រីកចំណេះដឹងបន្ថែម ទាក់ទងនឹងការធ្វើអស្សាមិករណ៍នាពេលបច្ចុប្បន្នសម្រាប់ធ្វើការស្វែងយល់។

ទោះបីជាសារណាមួយនេះបង្កើតឡើងដោយការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់អស់ពីសមត្ថភាពយ៉ាងណាក្តី កំហុសខុសឆ្គងដោយអចេតនា ក៏ដូចជាការបកស្រាយខ្លឹមសារ និងការប្រើប្រាស់ពាក្យពេចន៍ ឃ្លាឃ្លោង និងប្រយោគជាដើម រមែងកើតមានឡើងជាក់ជាមិនខាន។ ហេតុដូច្នេះហើយ រាល់មតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ មិត្តនិស្សិតអ្នកអានទាំងអស់គ្នា គឺជាចំណែកដែលមិនអាចខ្វះបានដើម្បីជាការចូលរួមកែលម្អ និងដើម្បីទុកជាមេរៀនសម្រាប់អភិវឌ្ឍន៍ចំណេះដឹងក្នុងការស្រាវជ្រាវបន្តទៅទៀត។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ ឯកឧត្តមសាកលវិទ្យាធិការ និងលោកសាស្ត្រាចារ្យទាំងអស់ ដែលបានផ្តល់នូវចំណេះដឹងដ៏ថ្លៃថ្លា ដល់នាងខ្ញុំ និងបានធ្វើឲ្យការសិក្សាបានទទួលបានជោគជ័យបែបនេះ។

# មាតិកា

ទំព័រ

## សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ..................... ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..................... ២
៣. គោលបំណងនៃការស្រាវជ្រាវ ..................... ៤
៤. សារៈសំខាន់នៃការស្រាវជ្រាវ ..................... ៤
៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................... ៤

## ជំពូកទី១

## បុព្វហេតុនៃការធ្វើអស្សាមិករណ៍

**១.១ សញ្ញាណទូទៅ** ..................... ៧
១.១.១ បទប្បញ្ញត្តិទូទៅ ..................... ៨
១.១.២ គោលបំណងនៃការធ្វើអស្សាមិករណ៍ ..................... ៩
១.១.៣ អស្សាមិករណ៍ពិសេស ..................... ៩
**១.២ គោលការណ៍ទូទៅ** ..................... ១០
១.២.១ គោលការណ៍ទូទៅនៃការធ្វើអស្សាមិករណ៍ ..................... ១០
១.២.២ យន្តការអស្សាមិករណ៍ ..................... ១១

## ជំពូកទី២

## នីតិវិធីនៃអស្សាមិករណ៍

**២.១ នីតិវិធីមុនអស្សាមិករណ៍** ..................... ១៣
២.១.១ គម្រោង ..................... ១៣
២.១.២ ការប្រកាសគម្រោង ..................... ១៤
**២.២ នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍** ..................... ១៥
២.២.១ ការដកហូតអចលនវត្ថុ ..................... ១៨
២.២.២ ការអនុវត្តគម្រោង ..................... ១៩

**២.៣ ការទូទាត់សំណងនៃអស្សាមិករណ៍** ............ ២០
២.៣.១ គោលការណ៍នៃការផ្តល់សំណង ............ ២០
២.៣.២ នីតិវិធីនៃការផ្តល់សំណង............ ២១

## ជំពូកទី៣

## វិវាទដែលប្រឈមនឹងការធ្វើអស្សាមិករណ៍

**៣.១ បញ្ហាប្រឈម** ............ ២៥
៣.១.១ បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋ ............ ២៥
៣.១.២ បញ្ហាប្រឈមរវាងរដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ............ ២៩
**៣.២ ការដោះស្រាយវិវាទអស្សាមិករណ៍**............ ៣០
៣.២.១ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ............ ៣១
៣.២.២ ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ............ ៣២
**សេចក្តីសន្និដ្ឋាន**............ ៣៤
**អនុសាសន៍**............ ៣៧
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

សាវតានយោបាយដ៏រង្គោះរង្គើរបស់កម្ពុជាបានធ្វើឲ្យមានការផ្លាស់ប្តូរជាញឹកញាប់នូវក្របខណ្ឌសិទ្ធិដីធ្លី ដែលពុំមានភាពរឹងមាំនៅទូទាំងប្រទេស។ ជាពិសេស ការបង្កវិនាសកម្មនៃរបបខ្មែរក្រហមចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ដែលបានបំផ្លាញចោលនូវកម្មសិទ្ធិដីធ្លីឯកជន និងឯកសារដីធ្លីនានា ដែលនេះបានធ្វើអោយប៉ះពាល់ដល់សិទ្ធិដីធ្លីកាន់តែធ្ងន់ធ្ងរឡើង[1]។ រហូតមកទល់ ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាក៏បានធ្វើការប្រកាសខ្លួន ជាប្រទេសមួយដែលប្រកាន់យកនូវរបបប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូង ដោយមានការជួយសម្រួលក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រីលើកទីមួយ ពីសំណាក់អាជ្ញាធរបណ្ដោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា (ហៅកាត់ថា អ៊ុនតាក់) ក្រោមកិច្ចសហការណ៍ជាមួយក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា (ហៅកាត់ថា អេសអិនស៊ី)[2]។

ក្រោយពីមានការរៀបចំរដ្ឋាភិបាលអាណត្តិទីមួយមក ប្រទេសកម្ពុជាក៏បានចាប់ផ្តើមមានការងើបឡើងវិញនូវសេដ្ឋកិច្ចជាតិ ហេដ្ឋារចនាសម្ព័ន្ធ និងមានការអភិវឌ្ឍលើគ្រប់វិស័យជាបណ្តើរៗមកវិញ។ ដោយការអភិវឌ្ឍទាំងនេះមានការផ្តោតទៅលើវិស័យជាច្រើនដូចជា វិស័យរដ្ឋបាល វិស័យច្បាប់ ជាពិសេសគឺ ការគ្រប់គ្រងទឹកដី។ ការគ្រប់គ្រងដីធ្លី ពីសម័យកាលមួយទៅសម័យកាលមួយ តែងមានការវិវត្តន៍ប្រែប្រួលស្របទៅតាមការរីកចម្រើននៃសេដ្ឋកិច្ច និងគោលនយោបាយដឹកនាំរបស់រាជរដ្ឋាភិបាល។ ទោះបីជាមានការបង្កើតច្បាប់ពាក់ព័ន្ធនឹងបញ្ហាដីធ្លីជាច្រើនជាបន្តបន្ទាប់យ៉ាងណាក៏ដោយ ក៏បញ្ហារឿងវិវាទដីធ្លីនៅតែកើតមានឥតឈប់ឈរ រវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ រវាងប្រជាពលរដ្ឋនិងក្រុមហ៊ុនឯកជន និងរវាងប្រជាពលរដ្ឋនិងរដ្ឋជាដើម (ការដកហូតដីធ្លីពីប្រជាពលរដ្ឋ)[3]។ ដើម្បីសម្រួលនូវបញ្ហាវិវាទទាំងឡាយដែលតែងតែកើតមានឡើងនេះ ប្រទេសកម្ពុជាបានរៀបចំនូវស្ថាប័នផ្សេងៗសម្រាប់ជួយសម្រួលដោះស្រាយលើបញ្ហានេះផងដែរ។ ក្នុងនោះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការនេះ។ ដើម្បីងាយស្រួលក្នុងការសិក្សាស្វែងយល់ កាន់តែច្បាស់លាស់ និងស៊ីជម្រៅលើដំណើរការចូលរួមរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នាងខ្ញុំសូមលើកយកសាវតារបស់ក្រសួងនេះ និងចំណុចមួយទៀតដែលពិតជាមានភាពប្រទាក់ក្រឡា

[1] សារណាបញ្ចប់ការសិក្សា "នីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" របស់លោក ពេញ ប៊ុនថង និងកញ្ញា ប្រាក់ រតនៈវិតា ឆ្នាំ ២០២០ ទំព័រ១

[2] https://opendevelopmentcambodia.net/km/topics/elections/ ចូលមើលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

[3] អត្ថបទ "គុណសម្បត្តិនៃការធ្វើអស្សាមិករណ៍" ចូលមើលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

ជាមួយនឹងប្រធានបទនេះ។ ក្នុងសម័យសង្គមរាស្ត្រនិយមរហូតមកដល់មុនឆ្នាំ១៩៧៥ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋាន នគរូបនីយកម្មនិងលំនៅឋាន នៃក្រសួងសាធារណការ ហើយនៅតាមខេត្ត-ក្រុង កិច្ចការនេះត្រូវបានគ្រប់គ្រងដោយមន្ទីរសាធារណការខេត្ត-ក្រុង។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ មន្ទីររៀបចំក្រុង ត្រូវបានបង្កើតឡើងនៅក្រុងភ្នំពេញ និងការិយាល័យសំណង់ ត្រូវបានបង្កើតនៅតាមបណ្តាខេត្ត ដោយនៅខេត្តខ្លះត្រូវដាក់ឱ្យស្ថិតនៅក្រោមមន្ទីរផែនការ និងនៅខេត្តខ្លះទៀតការិយាល័យនេះស្ថិតនៅក្រោមមន្ទីរឧស្សាហកម្ម។ ទន្ទឹមនឹងនេះ សហគ្រាសសំណង់មួយក៏ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមក្រសួងឧស្សាហកម្ម ដើម្បីសាងសង់សំណង់របស់រដ្ឋនៅទូទាំងប្រទេស លើកលែងសំណង់របស់ក្រសួងពាណិជ្ជកម្ម ដែលនាពេលនោះមានក្រុមហ៊ុនស្ថាបនាមួយ។ ឆ្នាំ១៩៨៦ ដោយវិស័យសំណង់មានការរីកចម្រើន អគ្គនាយកដ្ឋានសំណង់ ត្រូវបានបង្កើតឡើងស្ថិតនៅក្រោមចំណុះក្រុមប្រឹក្សារដ្ឋមន្ត្រីដើម្បីគ្រប់គ្រងវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ឆ្នាំ១៩៩៣ រាជរដ្ឋាភិបាលនីតិកាលទី១នៃរដ្ឋសភា អគ្គនាយកដ្ឋាននេះ ស្ថិតនៅក្រោមក្រសួងសាធារណការ និងដឹកជញ្ជូន។ លុះឆ្នាំ១៩៩៤ ក្រោយមានច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ដែលមានទីស្នាក់នៅទីស្តីការគណៈរដ្ឋមន្ត្រី[4]។ នៅចុងឆ្នាំ ១៩៩៩ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យសាងសង់អគារថ្មី ដោះស្រាយបញ្ហាកន្លែងធ្វើការជូនមន្ត្រីរាជការ ដែលមានកំណើនជាលំដាប់ស្របតាមសំណូមពរការងារកាន់តែកើនឡើង ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ និងចូលជាធរមាននៅក្នុងឆ្នាំ១៩៩៩។ អាជ្ញាធរមានសមត្ថកិច្ចចំពោះផ្នែកនគរូបនីយកម្មរួមមាន គណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រុងភ្នំពេញ និងគណៈកម្មាធិការ[5]។

ជាបន្តបន្ទាប់ទៅនេះ នាងខ្ញុំនឹងធ្វើសិក្សាស្រាវជ្រាវអំពីការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយលំអិត ដូចខាងក្រោមនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស និងស្របតាមលក្ខខណ្ឌដែលប្រទេសកម្ពុជាទើបតែទើបខ្លួនពីសង្គ្រាមដែលអូសបន្លាយរាប់ឆ្នាំក្នុងស្រុកទៀតផងនោះ ដី និងទឹកជាធនធានសំខាន់ពីរជាមូលដ្ឋាន ដែលត្រូវប្រើប្រាស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច។ ប៉ុន្តែ រាល់

[4] http://www.mlmupc.gov.kh/?page=detail&menu1=215&menu2=263&ctype=article&id=263&lg=kh ចូលមើលថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២១

[5] សៀវភៅ នីតិនគរូបនីយកម្ម របស់លោកបណ្ឌិត អ៊ុន សក្កដា ជំពូកទី៤ ទំព័រទី១៣០

ធនធានខាងលើភាគច្រើនត្រូវបានកាន់កាប់ដោយបុគ្គលឯកជនរួចខ្លះទៅហើយ ដែលជាហេតុក្លាយទៅជាបញ្ហាស្មុគស្មាញពេលដែលរដ្ឋាភិបាល ធ្វើការដកហូតការកាន់កាប់ទាំងនោះយកមកធ្វើការអភិវឌ្ឍ។ មិនតែប៉ុណ្ណោះសិទ្ធិប្រើប្រាស់ និង/ឬ សិទ្ធិកម្មសិទ្ធិករលើធនធានទាំងនោះ គឺលទ្ធផលនៃដំណើរការចាត់ចែងប្រវត្តិសាស្ត្រដែលមានករណីខ្លះសិទ្ធិទាំងនោះត្រូវបានកំណត់មិនច្បាស់លាស់ ឬមានករណីទំនាស់សិទ្ធិគ្នាកើតឡើង ដែលការបែងចែកធនធានទាក់ទងនឹងដី និងការកំណត់កម្មសិទ្ធិ ព្រមទាំងការទទួលខុសត្រូវលើធនធានទាំងនោះមានសារៈសំខាន់ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។ ក្នុងនោះ ច្បាប់ភូមិបាលថ្មីបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ បានបង្កើតនូវមូលដ្ឋានយ៉ាងសំខាន់លើការកសាងក្របខណ្ឌច្បាប់ សម្រាប់ការងារគ្រប់គ្រងដីធ្លីនៅកម្ពុជា។ ប៉ុន្តែច្បាប់ភូមិបាលខ្លួនឯង បានត្រឹមផ្តល់ការណែនាំយ៉ាងតិចតួចអំពីរបៀបបកស្រាយអនុវត្ត និងប្រើប្រាស់ច្បាប់នេះ ហើយមានចំណុចជាច្រើននៃគោលនយោបាយដីធ្លីដែលច្បាប់នេះមិនបានចែង។ ហេតុដូចនេះ ទើបបានជារដ្ឋសភានីតិកាលទី៤ បានសម្រេចអនុម័តច្បាប់ស្តីពីអស្សាមិករណ៍ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ដោយច្បាប់នេះមាន ៨ ជំពូក និងចែកជា ៣៩ មាត្រា ដើម្បីកំណត់អំពីការដកហូតសិទ្ធិកម្មសិទ្ធិលើអចលនវត្ថុនៅក្នុងប្រទេសកម្ពុជា ដោយមានការកំណត់យ៉ាងច្បាស់លាស់អំពីគោលការណ៍ យន្តការ នីតិវិធីនៃការធ្វើអស្សាមិករណ៍ និងការទូទាត់សំណងដោយសមរម្យ និងយុត្តិធម៌សម្រាប់គម្រោងនីមួយៗ[6]។ ដោយសារតែច្បាប់អស្សាមិករណ៍ មានសារៈសំខាន់ក្នុងការអភិវឌ្ឍសង្គមយ៉ាងខ្លាំងបែបនេះហើយ បានជានាងខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់កាន់តែច្បាស់ពាក់ព័ន្ធនឹងការធ្វើអស្សមិករណ៍នេះ ជាហេតុនាងខ្ញុំចុងក្រោយសម្រេចចិត្តជ្រើសរើសយកប្រធាន **ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា** ដើម្បីធ្វើជាសារណាសម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។

ពាក់ព័ន្ធនឹងប្រធានបទដែលនាងខ្ញុំ បានលើកមកធ្វើការសរសេរសារណានេះផងដែរ មានសំណួរគតិយុត្តមួយចំនួនបានលើកឡើងថា៖ តើការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈដូចម្តេច? តើមានបញ្ហាប្រឈមអ្វីខ្លះនៅក្នុងអំឡុងការអនុវត្តនីតិវិធីពេលធ្វើអស្សាមិករណ៍? តើមានដំណោះស្រាយបែបណាខ្លះក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានទាំងនោះ? ដែលចំណុចទាំងបីនេះ នឹងក្លាយជាចំណោទបញ្ហាក្នុងការស្រាវជ្រាវនេះ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវលើប្រធានបទមួយនេះ ដោយនាងខ្ញុំមានគោលបំណងសំខាន់ៗ

[6] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧

ចំនួនពីរ ដូចខាងក្រោម៖

ទីមួយ ដោយសារបច្ចុប្បន្នបញ្ហាទំនាស់ដីធ្លី និងការបណ្តេញដោយបង្ខំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅតែមានចំនួនច្រើនគួរឲ្យកត់សម្គាល់ដដែរ ហើយបញ្ហាទាំងនេះទៀតសោតក៏មិនអាចនឹងបញ្ចប់ក្នុងរយៈពេលខ្លីបានឡើយ។ បើសិនជាបញ្ហានេះនៅតែកើតមានជាបន្តបន្ទាប់ ហើយការដោះស្រាយពុំទទួលបានប្រសិទ្ធភាពនោះទេ ពិតណាស់វាមិនត្រឹមតែជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនោះទេ រាល់ការធ្វើបាតុកម្ម និងការតវ៉ាផ្សេងៗដែលកើតចេញពីការធ្វើអស្សាមិករណ៍ និងទំនាស់រវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ទំនាស់រវាងប្រជាពលរដ្ឋនិងអ្នកធ្វើគម្រោង និងទំនាស់ប្រជាពលរដ្ឋនិងរដ្ឋទៀតផងនោះ នឹងនាំឲ្យខូចសណ្តាប់ធ្នាប់ជាសាធារណៈ និងសេចក្តីថ្លៃថ្នូររបស់ជាតិជាដើម។ ជាពិសេសនោះ ដោយសារតែមានបញ្ហាបែបនេះ អាចនឹងធ្វើឲ្យលឿនក្នុងការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា មានសន្ទុះមិនសូវលឿនជាដើម។ ដោយសារតែមើលឃើញពីបញ្ហាទាំងអស់នេះហើយ បានជាធ្វើឲ្យនាងខ្ញុំសម្រេចជ្រើសរើសប្រធានបទមួយនេះឡើង ដើម្បីដឹងកាន់តែច្បាស់ពីការធ្វើអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយតាមរយៈការសិក្សាស្វែងយល់លំអិតនៃការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជានេះ អាចធ្វើឲ្យនាងខ្ញុំនឹងធ្វើការវិភាគរកដំណោះស្រាយរួចចូលរួមក្នុងការផ្តល់ជាអនុសាសន៍។

ទីពីរ ដោយសារតែប្រធានបទស្តីពីការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជានេះ ពុំទាន់ឃើញមានការស្រាវជ្រាវណាបានសិក្សាលំអិតនូវឡើយ។ ការសិក្សាស្រាវជ្រាវនេះ គឺដើម្បីជាជំនួយបន្ថែម សម្រាប់មិត្តៗនិស្សិតដែលជាសិស្សប្អូនជំនាន់ក្រោយ ចង់សិក្សាពីស្រាវជ្រាវបែបប្រៀបធៀបឲ្យកាន់តែងាយស្រួល និងធំទូលាយជាងនេះទៅទៀត។

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាលំអិតអំពីការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជានេះ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះនាងខ្ញុំ ដើម្បីនឹងធ្វើការវិភាគរកដំណោះស្រាយមួយជាក់លាក់ រួចធ្វើការផ្តល់ជាអនុសាសន៍ ដើម្បីជាផ្នែកមួយក្នុងការពង្រីកចំណេះដឹងដែលទាក់ទងនឹងប្រធានបទមួយនេះ។

លើសពីនេះទៅទៀតប្រជាពលរដ្ឋអាចយល់ច្បាស់អំពីការធ្វើអស្សាមិករណ៍ នីតិវិធីនៃការធ្វើអស្សាមិករណ៍ និងសំណងបែបណាខ្លះដែលប្រជាពលរដ្ឋគួរតែទទួលបាន ចៀសវាងការកើតមានបញ្ហាប្រឈមពេលមានការធ្វើអស្សាមិករណ៍ផងដែរ។ តាមរយៈការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការធ្វើអស្សាមិករណ៍នេះ ក៏ជួយឲ្យការដោះស្រាយទំនាស់ដីធ្លី និង/ឬជំនាស់ផលប្រយោជន៍ អាចបញ្ចប់ដោយមានប្រសិទ្ធភាព និងចំណេញពេលវេលាផងដែរ។ ជាពិសេស បើប្រទេសយើងអាចកាត់បន្ថយវិវាទដែលកើតមានពេលមានគម្រោងអភិវឌ្ឍ សម្រាប់បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិនេះបានមែន ប្រាកដណាស់វាក៏ជាកត្តាមួយដែល

ជំរុញឲ្យប្រទេសកម្ពុជា ឈានទៅរកភាពរីកចម្រើនលឿនលើគ្រប់កិច្ចស្តារហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំប្រទេសឲ្យមានភាពសម្បូរបែបបានជាក់ជាមិនខាន។

## ៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះ នាងខ្ញុំបានធ្វើការបែងចែកជាបីជំពូករួមមាន៖

ជំពូកទី១ បុព្វហេតុនៃការធ្វើអស្សាមិករណ៍ ដោយនៅក្នុងជំពូកនេះគឺនាងខ្ញុំបានបែងចែកជា ២ ចំណុចធំៗ ទៀត និងក្នុង ២ ចំណុចធំៗនោះមានការបែងចែកជាចំណុចតូចៗលំអិតនៅក្នុងនោះទៀតគឺ៖

- ចំណុចទី១ សញ្ញាណទូទៅ (១.១.១ បទប្បញ្ញត្តិទូទៅ ១.១.២ គោលបំណងនៃការធ្វើអស្សាមិករណ៍ និង ១.១.៣ អស្សាមិករណ៍ពិសេស)
- ចំណុចទី២ គោលការណ៍ទូទៅ (១.២.១ គោលការណ៍ទូទៅនៃការធ្វើអស្សាមិករណ៍ ១.២.២ យន្តការអស្សាមិករណ៍)

ជំពូកទី២ នីតិវិធីនៃអស្សាមិករណ៍ ដោយនៅក្នុងជំពូកនេះនាងខ្ញុំនឹងធ្វើការបែងចែកជា ៣ ចំណុចធំៗ និងនៅក្នុង ៣ ចំណុចនោះនៅមានចំណុចតូចៗជាច្រើនទៀតគឺ៖

- ចំណុចទី១ នីតិវិធីមុនអស្សាមិករណ៍ (២.១.១ គម្រោង និង ២.១.២ ការប្រកាសគម្រោង)
- ចំណុចទី២ នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍ (២.២.១ ការដកហូតអចលនវត្ថុ និង ២.២.២ ការអនុវត្តគម្រោង)
- ចំណុចទី៣ ការទូទាត់សំណងនៃអស្សាមិករណ៍ (២.៣.១ គោលការណ៍នៃការផ្តល់សំណង និង ២.៣.២ នីតិវិធីនៃការផ្តល់សំណង)

ជំពូកទី៣ បញ្ហាដែលប្រឈមនឹងការធ្វើអស្សាមិករណ៍ ដោយនៅក្នុងជំពូកនេះនាងខ្ញុំនឹងធ្វើការបែងចែកជា ២ ចំណុចធំៗ និងចំណុចតូចៗបន្ថែមទៀតគឺ៖

- ចំណុចទី១ បញ្ហាប្រឈម (៣.១.១ បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋ ៣.១.២ បញ្ហាប្រឈមរវាងរដ្ឋ និងទ្រព្យសម្បត្តិរដ្ឋ)
- ចំណុចទី២ ការដោះស្រាយវិវាទអស្សាមិករណ៍ (៣.២.១ ការដោះស្រាយក្រៅប្រព័ន្ធតុលាការ និង ៣.២.១ ការដោះស្រាយក្នុងប្រព័ន្ធតុលាការ)។

ចំពោះខ្លឹមសារ ដែលទាក់ទងទៅនឹងចំណោទបញ្ហាដែលបានចោទឡើងក៏ដូចជារាល់ ចំណុចដែលបានលើកឡើងខាងលើនាងខ្ញុំ នឹងធ្វើការអត្ថាធិប្បាយខ្លឹមសារក្នុងអត្ថបទស្រាវជ្រាវនេះ។

# ជំពូកទី១

# មូលហេតុនៃការធ្វើអស្សាមិករណ៍

វិវាទដីធ្លីនៅកម្ពុជា ត្រូវបានគេមើលឃើញថាទូទៅថាជាបញ្ហាមួយក្នុងចំណោមបញ្ហាដ៏ធំបំផុត ដែលប្រជាពលរដ្ឋកម្ពុជាកំពុងប្រឈមមុខ។ នៅក្នុងករណីធ្ងន់ធ្ងរ វិវាទដីធ្លីអាចឈានដល់ការបាត់បង់ដីធ្លី និងការទទួលបាននូវធនធានដែលមិនសមស្របនឹងគោលការណ៍កាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាលកម្ពុជា។ កម្រិតនិងការកើតមានវិវាទដីធ្លីនៅកម្ពុជា បង្កើតឱ្យមានកង្វល់ក្នុងចំណោមសហគមន៍ជាតិ និងអន្តរជាតិ[7]។ ស្របតាមក្របខណ្ឌគតិយុត្តស្តីពីអស្សាមិករណ៍នេះផងដែរ ក៏មានចងកាតព្វកិច្ចនៅក្នុងក្របខណ្ឌអន្តរជាតិ។ ក្នុងនោះយោងតាមច្បាប់អន្តរជាតិ ការតាំងទីលំនៅថ្មីដោយបង្ខំ និងមិនមានការស្ម័គ្រចិត្ត ត្រូវបានចាត់ទុកថាជាការដើរថយក្រោយនៃការទទួលបានសិទ្ធិមនុស្ស។ ប្រទេសកម្ពុជា គឺជាប្រទេសភាគីហត្ថលេខីនៃសន្ធិសញ្ញាអន្តរជាតិជាច្រើន ហេតុដូចនេះហើយត្រូវមានកាតព្វកិច្ចការពារប្រជាពលរបស់ខ្លួនប្រឆាំងនូវរាល់វិធានការ ធ្វើឲ្យសិទ្ធិមនុស្សធ្លាក់ចុះ ដែលដាក់ចេញដោយអង្គភាពរដ្ឋាភិបាល និងតតិយជន[8]។ ក្នុងនោះ *អស្សាមិករណ៍* សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន ដី សំណង់ និងដំណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌[9] ជាមុន។ ការដកហូត ដែលធ្វើឡើងស្របតាមច្បាប់អស្សាមិករណ៍នេះផងដែរ គឺត្រូវធ្វើឡើងស្របតែទៅតាមកិច្ចអនុវត្តលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដែលបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិប៉ុណ្ណោះ។

ស្របតាមច្បាប់អស្សាមិករណ៍នេះ គឺអាចធ្វើឡើងដោយត្រូវស្របតាមតម្រូវការរបស់ជាតិ និងមានការស្នើសុំដោយកំណត់ដោយរដ្ឋាភិបាល ។ ដោយការកំណត់ទាំងនេះ ត្រូវស្ថិតណៅក្រោមគម្រោងមួយចំនួនដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការដឹកជញ្ជូន (ផ្លូវអេយស្ទ័នយាន ផ្លូវថ្នល់ ស្ពាន។ល។) ការផ្គត់ផ្គង់អគ្គិសនី (ស្ថានីយអគ្គិសនី ខ្សែបណ្តាញបញ្ជូន។ល។) គមនាគមន៍ (ប្រៃសនីយ៍ ផ្លូវទូរគមនាគមន៍ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ល។) កន្លែងកំសាន្តសាធារណៈ (សួនច្បារ ទីលានសាធារណៈ ។ល។) គោលបំណងខាងអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ (សាលា សាកលវិទ្យាល័យ សារមន្ទីរ។ល។) សេវាសុខភាព ( មណ្ឌលសុខភាព មន្ទីរពេទ្យ។ល។) ការរុករកធនធានធម្មជាតិ និងឥន្ធនៈផូស៊ីល (រោងចក្រហ្គាស បណ្តាញបំពង់ប្រេងឥន្ធនៈ រោង

[7] ការវិភាគស្ថិតិស្តីពី វិវាទដីធ្លីនៅកម្ពុជាឆ្នាំ ២០១៦

[8] https://opendevelopmentcambodia.net/km/topics/expropriation/ ចូលមើលថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

[9] វាក្យខណ្ឌទី១ មាត្រា៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ឆ្នាំ២០១០

ចក្រចម្រាញ់ប្រេង។ល។) អគារដែលរងការបំផ្លាញធ្ងន់ធ្ងរដោយគ្រោះធម្មជាតិ ក៏អាចជាកម្មវត្ថុនៃការដកហូតដូចគ្នាទៅនឹងតំបន់វប្បធម៌ និងតំបន់វិទ្យាសាស្ត្រពិសេស ដោយផ្តល់ផលប្រយោជន៍ខាងបរិស្ថាន និងប្រវត្តិសាស្ត្រ ព្រមទាំងដីដែលត្រូវការចាំបាច់សម្រាប់ការតាំងទីលំនៅថ្មី ការការពារ និងការគាំទ្រសិទ្ធិរបស់ប្រជាពលរដ្ឋកន្លែងកាត់ព្រំដែន ការពារជាតិ និងសន្តិសុខជាតិ[10]។ តាមរយៈការឆ្លុះបញ្ចាំងទាំងនេះ យើងឃើញថាការធ្វើអស្សាមិករណ៍ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន។

### ១.១ សញ្ញាណទូទៅ

ជាទូទៅ ការកសាង គឺជាការរួមចំណែកមួយនៃការអភិវឌ្ឍប្រទេសជាតិ ដើម្បីឈានទៅរកភាពរីកចម្រើន ដូចជា ការសាងសង់ស្ពាន ថ្នល់ សាលារៀន មន្ទីរពេទ្យ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដទៃទៀត អ្វីទាំងនេះសុទ្ធសឹងតែជាតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋ និងប្រទេសជាតិ[11]។ ក្នុងនោះ នៅក្នុងប្រទេសកម្ពុជា ដោយសារតែ សាកលភាវូបនីយកម្មសេដ្ឋកិច្ច ការពង្រីកការនាំចេញយ៉ាងរហ័ស និងកំណើនវិនិយោគទុនបរទេស ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ បាននាំមកនូវបញ្ហាដីធ្លីយ៉ាងខ្លាំងនៅកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឲ្យមានការជួលដីក្នុងទំហំធំសម្រាប់ផលប្រយោជន៍ពាណិជ្ជកម្ម តាមរយៈសម្បទានសេដ្ឋកិច្ច។ ការត្រៀមខ្លួនរបស់រដ្ឋាភិបាលក្នុងការបែងចែកដីធ្លីឡើងវិញ រួមជាមួយនឹងអសមត្ថភាពនៅក្នុងការកាន់កាប់ដីធ្លី ដោយសារតែកង្វះកម្មសិទ្ធិស្របច្បាប់យ៉ាងរីករាលដាល និងនីតិរដ្ឋទន់ខ្សោយទៀតផងនោះ បានសម្រួលដល់ការចាប់យកដីនិងការបណ្តេញចេញដោយបង្ខំយ៉ាងច្រើន[12]។ បន្ថែមពីនោះ នៅក្នុងប្រទេសកម្ពុជាមានកត្តាផ្សេងៗជាច្រើនរួមចំណែកនៅក្នុងការបង្កជម្លោះ និងការដកហូតដីធ្លី។ ការផ្តល់សម្បទានដី ការចុះបញ្ជីដីធ្លី និងដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិចន្លោះប្រហោង ការគំរាមគំហែង និងការបំភិតបំភ័យ របស់សហគមន៍ដែលរងគ្រោះ ព្រមទាំងកង្វះយន្តការដោះស្រាយជម្លោះ ប្រការទាំងនេះសុទ្ធតែបង្កឲ្យមានទំនាស់ដីធ្លីកាន់តែធ្ងន់ធ្ងរឡើង[13]។ ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជា បានខិតខំយ៉ាងខ្លាំងក្នុងការស្វែងរកមធ្យោបាយដើម្បីដោះស្រាយនូវបញ្ហាដែលកើតមានឡើងជាបន្តបន្ទាប់ ដោយសារតែការដកហូតកម្មសិទ្ធិដែលជាសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋមកធ្វើការអភិវឌ្ឍនេះ។

[10] https://opendevelopmentcambodia.net/km/topics/expropriation/ ចូលមើលថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២១

[11] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ន្ត បុប្ផាមុនិច ឆ្នាំ២០១៧

[12] របាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយខែកុម្ភៈ ឆ្នាំ២០១៦ "ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគនៅកម្ពុជា"

[13] កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយខែមីនា ឆ្នាំ២០១៤ " កំណែទម្រង់ដីធ្លី"

### ១.១.១ បទប្បញ្ញត្តិទូទៅ

មូលហេតុដែលចេះតែកើតមានដោយសារតែការដកហូតកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋទាំងនេះ បានជារដ្ឋាភិបាលកម្ពុជាបានបង្កើតនូវច្បាប់អស្សាមិករណ៍។ ច្បាប់នេះ មានគោលដៅកំណត់អំពីអស្សាមិករណ៍ នៅព្រះរាជាណាចក្រកម្ពុជា ដោយកំណត់អំពីគោលការណ៍ យន្តការ នីតិវិធីអស្សាមិករណ៍ និងសំណងឲ្យបាន សមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និងគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឲ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ និងការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា[14]។ យ៉ាងណាមិញ ការធ្វើអស្សាមិរណ៍ត្រូវកំណត់ឲ្យបានជាក់លាក់ អំពីប្រភេទអចលនវត្ថុ ដែលត្រូវយកមកធ្វើអស្សាមិករណ៍ ដោយគិតអំពីទំហំនៃចំណែកដែលត្រូវធ្វើ និងចំណែកដែលនៅសល់មុន និងក្រោយការធ្វើអស្សាមិករណ៍ អ្នកដែលមានសិទ្ធិពាក់ព័ន្ធនឹងចំណែកនោះនៅសល់ ប៉ុន្តែករណី ដែលមានការធ្វើអស្សាមិករណ៍ពិសេស គឺការដកត្រូវបានធ្វើភ្លាម និងជាបន្ទាន់ ដើម្បីការពារសុវត្ថិជូនសាធារណៈជន[15]។

### ១.១.២ គោលបំណងនៃការធ្វើអស្សាមិករណ៍

ច្បាប់ស្តីពីអស្សាមិករណ៍នេះផងដែរ បានចែងអំពីគោលបំណងជាអាទិ៍៖ ធានាការដកហូតសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌ ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌ បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ[16]។ នៅក្នុងការតាក់តែង និងអនុម័តច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ច្បាប់នេះ មិនគ្របដណ្តប់លើកកិច្ចព្រមព្រៀង ឬអនុស្សរណៈ ស្តីពីការគាំពារវិនិយោគរវាងរដ្ឋាភិបាល និងប្រទេសជាដៃគូដែលមានចែងនៅក្នុងអស្សាមិករណ៍ទេ។ ក្នុងករណី ដែលមិនមានកិច្ចព្រមព្រៀងនេះទេ ឬករណីដែលកិច្ចព្រមព្រៀង ឬអនុស្សរណៈពុំមានចែងពីអស្សាមិរកណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ[17]។

នៅមុនពេលធ្វើ រាជរដ្ឋាភិបាលត្រូវរៀបចំគណៈកម្មាធិការ ក្នុងគោលបំណងរៀបចំ និងត្រួតពិនិត្យទៅលើដំណាក់កាលនីមួយៗនៃការធ្វើអស្សាមិករណ៍។

[14] មាត្រា១ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[15] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ៉ិត្ន បុប្ផាមុនិច ឆ្នាំ ២០១៧

[16] មាត្រា២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[17] មាត្រា៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

**១.១.៣ អស្សាមិករណ៍ពិសេស**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ[18]។ ប៉ុន្តែ ទោះបីជារដ្ឋមាននូវបុព្វសិទ្ធិបែបនេះយ៉ាងណាក្តីក៏រដ្ឋមិនអាចធ្វើអស្សាមិករណ៍លើអចលនវត្ថុឯកជនបានទេ ក្រោមហេតុផលបន្លំថាជាផលប្រយោជន៍សាធារណៈ និងប្រយោជន៍ជាតិបានឡើយ នៅពេលដែលគោលបំណងពិតប្រាកដ គឺដើម្បីផ្ទេរអចនលវត្ថុនោះ ទៅតតិយជនណាម្នាក់ដើម្បីផលប្រយោជន៍ឯកជន។ យ៉ាងណាក្តី ក្នុងបញ្ហាពាក់ព័ន្ធនឹងផលប្រយោជន៍សាធារណៈ សន្តិសុខជាតិ និងអាសន្ន រដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុនោះជាបណ្តោះអាសន្ន ដោយមិនចាំបាច់មានការពិគ្រោះយោបល់ជាមុន[19]។

បន្ថែមពីនោះ រដ្ឋមិនអាចធ្វើការដកហូតនៅកម្មសិទ្ធិដែលជាអចលនវត្ថុទាំងអស់នៅក្នុងតំបន់ ដោយពុំមានហេតុផលច្បាស់លាស់ ឬយកសិទ្ធិអំណាចជាអាជ្ញាធរ ធ្វើការគៀបសង្កត់ប្រជាពលរដ្ឋបាននោះទេ គឺរដ្ឋាភិបាលចាំបាច់ត្រូវបង្កើតគម្រោងអភិវឌ្ឍន៍ សាងសង់ កំណែទម្រង់ និងគម្រោងថវិការឲ្យបានច្បាស់លាស់ ដោយសំណងត្រូវមានភាពសមរម្យ និង យុត្តិធម៌[20]។ នៅក្នុងនោះ គម្រោងដែលអាចយកច្បាប់ស្តីពីអស្សាមិករណ៍មកប្រើប្រាស់បានមានជាអាទិ៍ ៖ ក. ការសាងសង់ ឬពង្រីកផ្លូវអយស្ម័នយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ រួមទាំងរចនាសម្ព័ន្ធ និងឧបករណ៍។ ខ. ការសាងសង់ ឬពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និងខ្សែសម្រាប់ការដឹកជញ្ជូន និងចែកចាយថាមពលអគ្គិសនី។ គ. ការសាងសង់ ឬពង្រីកអគារ និងឧបករណ៍សម្រាប់ប្រៃសនីយ៍ និងទូរគមនាគមន៍ និងប្រព័ន្ធពត៌មានវិទ្យា។ ឃ. ការសាងសង់ ឬពង្រីកផ្លូវផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និងទីលានសាធារណៈ។ ង. ការសាងសង់ ឬពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធលូទឹកកខ្វក់ និងកន្លែងបម្រើសេវាសាធារណៈផ្សេងទៀត។ ច. ការសាងសង់ ឬពង្រីក អគារសម្រាបអប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និងកីឡាដ្ឋានសម្រាប់សំដែងជូនជាសាធារណៈ។ ឆ. ការសាងសង់ ឬពង្រីកកន្លែងចម្រាញ់ និងកន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការពារធម្មជាតិ និង បរិស្ថាន។ ជ. ការសាងសង់ ឬ ពង្រីកអគារ និងឧបករណ៍សម្រាប់ស្រាវជ្រាវ និងសម្រាប់អាជីវកម្មរ៉ែ និងធនធានធម្មជាតិផ្សេងទៀត។ ឈ. ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្របូមប្រេង និងបណ្តាញដទៃទៀត។ ញ. ការសាង

[18] វាក្យខណ្ឌទី១ មាត្រា៦ នៃច្បាប់ស្តីពី អស្សាមិករណ៍ ឆ្នាំ២០១០

[19] https://opendevelopmentcambodia.net/km/topics/expropriation/ ចូលមើលថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២១

[20] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧

សង់ ឬពង្រីកអគារទីតាំងលំនៅដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងរពីធម្មជាតិរួមមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះបាក់ដីជាដើម និងការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ។ ដ. ការសាងសង់ ឬពង្រីកអគារសម្រាប់ការការពារ និងការគាំពារប្រជាជន។ ឋ. ការសាងសង់ ឬពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន។ ឌ. ការកសាង ពង្រីក ឬការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬការពារសន្តិសុខ។ ឍ. ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភណ្ឌ វប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន។ ណ. ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រដ្ឋាភិបាល[21]។

## ១.២ គោលការណ៍ទូទៅ

### ១.២.១ គោលការណ៍ទូទៅនៃការធ្វើអស្សាមិករណ៍

ជាទូទៅ ការធ្វើអនុម័តឲ្យធ្វើអស្សាមិករណ៍ ត្រូវសិទ្ធិក្រោមអំណាចឆន្ទានុសិទ្ធិរបស់រដ្ឋាភិបាលផ្ទាល់តែប៉ុណ្ណោះ ប៉ុន្តែមានន័យថារដ្ឋអាចធ្វើការដកហូតបានរាល់នូវកម្មសិទ្ធិដែលសិទ្ធិស្របច្បាប់លើអចលនវត្ថុរបស់ប្រជាពលរដ្ឋបានដោយពុំមានមូលហេតុច្បាស់លាស់នោះទេ។ ក្រោយពីមានការដកហូតនូវអចលកវត្ថុរបស់ប្រជាពលរដ្ឋ ដោយមានការផ្តល់សំណងសមរម្យ និងយុត្តិធម៌រួចមក រដ្ឋក៏ត្រូវតែទទួលទិញនូវចំណែកអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយសមរម្យ និងយុត្តិធម៌ តាមសំណើររបស់ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិដែលពុអាចរស់នៅក្បែរគម្រោងបាន ឬពុំអាចសាងសង់លំនៅឋានបាន ឬពុំអាចប្រកបអាជីវកម្មអ្វីផ្សេងបាន[22]។ នៅពេលធ្វើអស្សាមិករណ៍ នៅក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬការវាយប្រហារដោយភេរវកម្ម និងស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចនវត្ថុ ឬសិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្ន ដោយមិនចាំបាច់មានការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិទៅវិញនៅពេលចប់ការដកហូតនេះ[23]។ នៅក្នុងនោះ គោលការណ៍នៃការធ្វើអស្សាមិករណ៍គឺ មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិការប្រចាំឆ្នាំឲ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឲ្យបានគ្រប់ចំនួន និងទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍ តាមសំណើររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍[24]។

[21] មាត្រា៥ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០២១

[22] មាត្រា៨ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០២១

[23] វាក្យខណ្ឌទី១ មាត្រា៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០២១

[24] មាត្រា១០ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០២១

### ១.២.២ យន្តការអស្សាមិករណ៍

នៅក្នុងការធ្វើគម្រោងអស្សាមិករណ៍មួយ ក៏មិនខុសពីការធ្វើគម្រោងអភិវឌ្ឍន៍ផ្សេងទៀតដែរ គឺចាំបាច់ទាមទារឲ្យមានការត្រួតពិនិត្យច្បាស់លាស់មុនពេលនឹងអនុវត្តគម្រោងនោះ ក្នុងនោះការបង្កើតនូវគណៈកម្មាធិការសម្រាប់ធ្វើការត្រួតពិនិត្យពិតជាមានសារៈសំខាន់ណាស់។ ក្រលេកមកធ្វើការបកស្រាយលើ បរិបទជុំវិញនៃការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជាយើងនេះក៏ដូចគ្នា ដោយគណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និងដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានតំណាងក្រសួងពាក់ព័ន្ធចូលរួម។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ ត្រូវកំណត់ដោយអនុក្រឹត្យ[25]។

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និងដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងមានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម[26]។ ក្រៅពីគណៈកម្មាធិការ និងអនុគណៈកម្មាធិការ ដែលតួនាទីសំខាន់នៅក្នុងដំណើរការអនុវត្តគម្រោងតែការធ្វើអស្សាមិករណ៍នៅមាន គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាមួយទៀត។ ក្រុមគណៈកម្មាធិការទាំងបីនេះ ត្រូវបានបង្កើតឡើងសម្រាប់ដោះស្រាយបណ្តឹងតវ៉ា គ្រប់គ្រងដំណើរការការធ្វើអស្សាមិករណ៍ និងស្វែងរកដំណោះស្រាយនានា ពេលមានវិវាទទាក់ទងនឹងអស្សាមិករណ៍នោះ។ ក្នុងនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើរតួនាទី ក្នុងការដោះស្រាយសំណងដោយសមរម្យ និងយុត្តិធម៌ដល់ប្រជាពលរដ្ឋជាម្ចាស់កម្មសិទ្ធិ និង/ឬម្ចាស់អចលនវត្ថុ ដែលទទួលរងផលប៉ះពាល់គម្រោងអស្សាមិករណ៍[27]។

[25] មាត្រា១២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០២១

[26] វាក្យខណ្ឌទី១ មាត្រា១៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[27] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ន្ត បុប្ផាមុនិច ឆ្នាំ២០១៧

# ជំពូកទី២
# នីតិវិធីនៃអស្សាមិករណ៍

ជាទូទៅ ទំនាក់ទំនងរវាងប្រជាជន និងដីដែលត្រូវបានកំណត់និយមន័យតាមផ្លូវច្បាប់ ឬតាមលក្ខណៈប្រពៃណី- វិធានសង្គមបានបង្កើតឡើងដើម្បីបែងចែកសិទ្ធិអំណាចអចលនទ្រព្យទៅលើ ផ្តល់លទ្ធភាពប្រើប្រាស់ និងគ្រប់គ្រងដី និងកំណត់អំពីការទទួលខុសត្រូវ និងការហាមឃាត់ដែលពាក់ព័ន្ធ។ ភាពរឹងមាំ នៃការកាន់កាប់ដី របស់ប្រជាពលរដ្ឋបែបនេះហើយ ទើបពេលដែលរដ្ឋមានគម្រោងក្នុងការដកហូតនៅកម្មសិទ្ធិដូចជាដីឯកជនរបស់ប្រជាពលរដ្ឋមកធ្វើគម្រោងអស្សាមិករណ៍ សម្រាប់បម្រើផលប្រយោជន៍ជាតិ និងបម្រើផលប្រយោជន៍សាធារណៈនោះ ឃើញថាមានការរកាំរកូសគ្នា ឬមានការមិនពេញចិត្តអំពីសំណាក់ប្រជាពលរដ្ឋដែលត្រូវបានរដ្ឋអំណាចដកហូត សិទ្ធិកាន់កាប់ស្របច្បាប់លើអចលនវត្ថុរបស់ខ្លួន។ ម្យ៉ាងការធ្វើអស្សាមិករណ៍ គឺជាគម្រោងមួយដែលរដ្ឋបានបង្កើតឡើងក្រោមហេតុផល ក្នុងការបម្រើផលប្រយោជន៍សាធារណៈ និងបម្រើផលប្រយោជន៍ជាតិ ដែលភាគច្រើនគម្រោងអស្សាមិរកណ៍ត្រូវបានគេមើលឃើញថា មានលក្ខណៈជាគម្រោងធំៗដូចជាគម្រោងការសាងសង់ស្ពាន ថ្នាល់ សាលារៀន មន្ទីរពេទ្យ។ល។) ក្នុងនោះ គម្រោងទាំងនោះទាមទារឲ្យមាន ការគិតគូរអំពីទំហំថវិការឲ្យបានសមស្រប ចំណាយពេលវេលាច្រើន និងមានមានភាពស្មុគស្មាញជាដើម។ ដូចនេះ នៅក្នុងវដ្តគម្រោងមួយ ត្រូវមានការកំណត់អំពីសេចក្តីត្រូវការ ការសិក្សាអំពីលទ្ធភាពមុនដំណាក់កាលអនុវត្តគម្រោង ការសិក្សាអំពីលទ្ធភាពគម្រោង និងការតាក់តែងប្លង់គម្រោងលំអិត ការអនុវត្តនូវគម្រោង ឬសមាសភាពនៃគម្រោងដែលទទួលបាន ការសម្រេចឯកភាព និងសម្រាប់គម្រោង ការតាមដាន និងការវាយតម្លៃលើការអនុវត្តគម្រោងជាដើម[28]។

លើសពីនេះទៀតផងដែរ ការធ្វើគម្រោងណាមួយ មិនត្រឹមតែគម្រោងដែលស្ថិតនៅក្នុងគម្រោងអស្សាមិករណ៍ប៉ុណ្ណោះទេ គម្រោងអភិវឌ្ឍន៍ដទៃទៀតក៏តម្រូវឲ្យមានការវាយតម្លៃផ្នែកបរិស្ថានទាំងអស់។ ដូចនេះដើម្បីឲ្យយល់កាន់តែច្បាស់អំពីនីតិវិធីនៃការធ្វើអស្សាមិករណ៍ នាងខ្ញុំបានធ្វើការបែងចែកជាបីចំណុច មកធ្វើការបកស្រាយ (ចំណុចលំអិតនីមួយៗមាន រៀបរាប់នៅក្នុងមាតិការួចជាស្រេច)។

[28] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ន្ត បុប្ផាមុនិច ឆ្នាំ ២០១៧

## ២.១ នីតិវិធីមុនអស្សាមិករណ៍

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និងមានការអនុញ្ញាតជាគោលការណ៍ពីរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសាមី។ គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងសម្រេច[29]។ នៅក្នុងនោះ រដ្ឋត្រូវតែរៀបចំប្រកាសសេចក្តីជូនដំណឹងទៅម្ចាស់អចលនវត្ថុ បានដឹងជាមុនសិន។ ការជូនដំណឹងត្រូវធ្វើឡើងក្នុងពេលវេលាសមស្រប និងទទួលយកបាន គឺមិនមែនចូលទៅយកថ្ងៃជូនដំណឹង ឬ ក្រោយម្សិលមិញនៃការជូនដំណឹងនោះទេ។ មួយវិញទៀត រដ្ឋ ឬ ក្រសួងសាមី ត្រូវធ្វើការរៀបចំគម្រោងផែនការច្បាស់លាស់ និងមានការបូកបញ្ចូលនូវចំនួនថវិការប៉ាន់ប្រមាណ សម្រាប់ទុកធ្វើជាសំណងឲ្យបានច្បាស់លាស់។ ចំពោះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ឬ អាជ្ញាធររដ្ឋបាលដែលជាអ្នកដើរតួនាទី ក្នុងនាមរដ្ឋត្រូវតែរួបរួមគ្នា ធ្វើយ៉ាងណាត្រូវដាក់លិខិតសំណើសុំការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលសម្រាប់ការអនុវត្តគម្រោង។

### ២.១.១ គម្រោង

ជាទូទៅ នៅក្នុងការធ្វើអស្សាមិករណ៍បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋ បើគម្រោងនៃការធ្វើអស្សាមិករណ៍នោះ បានស្ថិតនៅតាមតំបន់ ឬទីប្រជុំជនណាដែលមានប្រជាពលរដ្ឋរស់នៅជាហូរហែច្រើនគ្នា។ ដើម្បីចៀសវាងនូវបញ្ហាប្រឈមនានាដែលអាចនឹងកើតមានឡើង ពេលធ្វើអស្សាមិករណ៍ ដំណាក់កាលនៃគម្រោង គឺជាដំណាក់មួយដែលទាមទារឲ្យក្រសួងពាក់ព័ន្ធ ត្រូវធ្វើសេចក្តីស្នើមករាជរដ្ឋាភិបាល ដើម្បីធ្វើការសម្រេចដាក់ឲ្យដំណើរការនីតិវិធីដកហូត។ ចំណុចនេះចង់បញ្ជាក់ថា គោលការណ៍ដែលចេញដោយរដ្ឋាភិបាលជាលក្ខខណ្ឌសំខាន់បំផុតក្នុងការដំណើរការគម្រោងអស្សាមិករណ៍ ដោយក្នុងនោះនីតិវិធីត្រូវមានការយល់ព្រមពីនាយករដ្ឋមន្ត្រី ទើបអាចធ្វើឲ្យគម្រោងប្រព្រឹត្តទៅបាន[30]។

ក្រោយពីទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយកត់ត្រាភិនភាគឲ្យបានលំអិតចំពោះរាល់សិទ្ធិរបស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិលើអចលនវត្ថុ និងទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងសំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ។ ក្នុងការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែង ធ្វើការពិគ្រោះជាសាធារណៈនៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងជាមួយតំណាងភូមិ ឬសហគមន៍ដែលរងនូវអស្សាមិករណ៍ ដោយផ្តល់នូវព័ត៌មានជាក់លាក់ ច្បាស់លាស់ និងទទួលយកបាននូវយោបល់ពីគ្រប់ភាគីពាក់ព័ន្ធ អំពីសំណើរគម្រោងហេដ្ឋារនាសម្ព័ន្ធរូបវន្តសាធារណៈ។ ដើម្បីកំណត់ពេលវេលាដកហូត ឬទី

[29] មាត្រា១៥ នៃច្បាស់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[30]អត្ថបទ "គុណសម្បត្តិនៃការធ្វើអស្សាមិករណ៍" ចូលមើលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១

កន្លែងដែលផ្តល់ដីថ្មី ឬសំណង គណៈកម្មាធិការអស្សាមិករណ៍ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ឲ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។ ការធ្វើដូច្នេះ គឺដើម្បីគ្រប់ភាគីបានចូលរួមយ៉ាងសកម្មអំពីការដកហូត រួមទាំងម្ចាស់កម្មសិទ្ធិ និង/ឬ ម្ចាស់សិទ្ធិ និងអាជ្ញាធររដ្ឋបាលគ្រប់ជាន់ថ្នាក់ ដើម្បីកុំឲ្យមានការព្រួយបារម្ភលើថា ការធ្វើអស្សាមិករណ៍នេះឈរលើគោលការណ៍ មិនគោរពសិទ្ធិមនុស្ស ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ គណបក្សនយោបាយ ឬមានការគៀបសង្កត់ប្រជាពលរដ្ឋពីសំណាក់ជនឆ្លៀតឱកាសណាមួយឡើយ។ ក្នុងនោះ ការធ្វើអង្កេតជាសាធារណៈនេះ គឺជាការផ្តល់សិទ្ធិឲ្យប្រជាពលរដ្ឋអាចចូលរួម និងដឹងអំពីការដកហូតនេះ ដែលប្រើប្រាស់សម្រាប់បម្រើប្រយោជន៍សាធារណៈណាមួយ។ តាមទិដ្ឋភាពជាក់ស្តែង ពេលមានគម្រោងអស្សាមិករណ៍នេះ ចំណុចនៃការអង្កេតនេះ ត្រូវធ្វើឡើងដោយមានក្រុមចុះវាស់វែង ដែលបានទទួលភារកិច្ចពីអនុគណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការអន្តរក្រសួងជាអ្នកមានសិទ្ធិក្នុងការត្រួតពិនិត្យ និងធ្វើការសម្រេចលើលទ្ធផលលើការងារដែលបានសម្រេចរួចហើយ។

បន្ទាប់ពីធ្វើការអង្កេតចប់ជាស្ថាពរ ក្នុងរយៈពេល ៣០ថ្ងៃ គណៈកម្មាធិការអស្សាមិករណ៍ ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍ជានាដាក់ជូន និងសុំការសម្រេចពីរាជរដ្ឋាភិបាល[31]។ ការធ្វើរបាយការណ៍ ត្រូវធ្វើឡើងដោយមានការចូលរួមពីអាជ្ញាធរ ដែលមានសមត្ថកិច្ចពាក់ព័ន្ធក្នុងរឿងនេះទាំងអស់ចូលរួមធ្វើរបាយការណ៍។ ការធ្វើរបាយការណ៍នេះ ដោយធ្វើការពិភាក្សា និងបូកសរុបលទ្ធផលដែលមានរួចហើយក្នុងការដាក់របាយការណ៍ជូនរាជរដ្ឋាភិបាល ដើម្បីស្នើសុំការសម្រេច។ រាជរដ្ឋាភិបាល អាចយករបាយការណ៍ដែលបានដាក់មក ឬធ្វើការកែសម្រួលមុនធ្វើការចេញនូវសេចក្តីប្រកាស ទៅលើដំណើរការនៃការធ្វើអស្សាមិករណ៍។ ការធ្វើរបាយការណ៍នេះ ជាចំណុចសំខាន់ផងដែរ ក្នុងការអនុវត្តនីតិវិធីនៃអស្សាមិករណ៍ត្រង់ចំណុចណាមិនចាំបាច់ ឬមិនសូវសំខាន់រាជរដ្ឋាភិបាលអាច មានបុព្វសិទ្ធិសម្រេចមិនធ្វើគម្រោងនេះបាន ដោយងាកទៅធ្វើលើកន្លែងផ្សេង ឬមានការពន្យាពេលសិនដើម្បីរកដំណោះស្រាយ[32]។

**២.១.២ ការប្រកាសគម្រោង**

បន្ទាប់ពី រាជរដ្ឋាភិបាលបានពិនិត្យ និងសម្រេចឯកភាពលើសំណើគម្រោងអស្សាមិករណ៍រួចមក គណៈកម្មាធិការអស្សាមិករណ៍ នឹងចេញសេចក្តីសម្រេចស្តីពីគម្រោងអស្សាមិករណ៍។ សេចកក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នេះ ដែលមានត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិឲ្យបានដឹងពីអចលនវត្ថុ

[31] មាត្រា១៦ នៃច្បាស់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[32] អត្ថបទ "គុណសម្បត្តិនៃការធ្វើអស្សាមិករណ៍" ចូលមើលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១

ដែលជាកម្មសិទ្ធិនៃការដកហូតនោះ និងចែងច្បាស់អំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ឬ កម្មសិទ្ធិលើអចលនវត្ថុឲ្យបានច្បាស់លាស់ ដោយមានអនុវត្តនៅនីតិវិធីមួយចំនួនដូចជា៖

- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំងគម្រោង និងរយៈពេលសម្រាប់អនុវត្តគម្រោង និងអាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិដកហូតកម្មសិទ្ធិ និង/ឬ ទ្រព្យឯកជន
- កំណត់អំពីសំណងសមរម្យ និងយុត្តិធម៌
- កំណត់រយៈពេលនៃបណ្តឹងតវ៉ា ។ ចំណុចនេះ មានសារៈសំខាន់ព្រោះបាន រក្សាសិទ្ធិដល់ម្ចាស់កម្មសិទ្ធិករក្នុងការដាក់ពាក្យបណ្តឹងសុំឲ្យមានការស៊ើបអង្កេត ដើម្បីឲ្យដឹងថាជាតម្រូវការចាំបាច់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ បម្រើផលប្រយោជន៍ជាតិ ឬក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងផ្សេងវិញបាន ។ បណ្តឹងនេះ អាចធ្វើឡើងដោយមេធាវី ឬតំណាងរបស់កម្មសិទ្ធិករ។ បន្ថែមពីនេះ រយៈពេលនៃការត្រូវធ្វើឡើងនៅត្រឹម ៣០ ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការទទួលបានសេចក្តីប្រកាសអំពីគម្រោងស្តីពីអស្សាមិករណ៍ ជូនគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ បន្ទាប់ពីបានធ្វើការអង្កេតចប់ស្ពាវរ ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។
- ផ្ញើសេចក្តីប្រកាសទៅគ្រប់ម្ចាស់អចលនវត្ថុ និង/ឬ ទៅម្ចាស់កម្មសិទ្ធិដោយមានលិខិតចម្លងភ្ជាប់។
- ដាក់ពាក្យស្លោកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវដកហូតសម្រាប់បម្រើផលប្រយោជន៍រូបវន្តសាធារណៈ។ ការដាក់ពាក្យស្លោក ដើម្បីសម្គាល់ទីតាំងនៃគម្រោងអស្សាមិករណ៍នេះ បានផ្តល់ភាពងាយស្រួលក្នុងការបង្ហាញអំពីអចលនវត្ថុដែលត្រូវធ្វើអស្សាមិករណ៍ និងត្រូវធ្វើឲ្យមានភាពទូលំទូលាយ និងត្រូវធ្វើការផ្សព្វផ្សាយនេះនៅទីតាំងសាលាឃុំនៃគម្រោងនៃអស្សាមិករណ៍នោះ។
- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ។ ការផ្សព្វផ្សាយសេចក្តីប្រកាសនៃការជូនដំណឹងនេះមានសារៈសំខាន់ណាស់ ពីព្រោះបន្ទាប់ពីបានចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍រួចមកតែច្បាប់មិនអនុញ្ញាតឲ្យធ្វើការលក់ ឬផ្ទេរសិទ្ធិលើអចនវត្ថុពាក់ព័ន្ធ ឬធ្វើការសាងសង់ថ្មី ឬសង់បន្ថែមសំណង់លើសំណង់ដែលមានស្រាប់លើដីនោះឡើយ។ រដ្ឋ នឹងមិនទទួលស្គាល់ការលក់ ឬការផ្ទេរសិទ្ធិណាមួយដែលច្បាប់បានហាមឃាត់ឡើយ ហើយនឹងមិនផ្តល់សំណងចំពោះសំណង់ថ្មី ឬសំណង់ពង្រីកបន្ថែម ដែលច្បាប់នេះបានហាមឃាត់នោះផងដែរ។ រដ្ឋ នឹងធ្វើការដោះស្រាយជាមួយម្ចាស់

អចលនវត្ថុ និងម្ចាស់កម្មសិទ្ធិទាំងឡាយលើអចលនវត្ថុនោះ នៅត្រឹមតែថ្ងៃដែលចេញសេចក្តីប្រកាសនៃការប្រកាសគម្រោងអស្សាមិករណ៍នោះតែប៉ុណ្ណោះ[33]។

## ២.២ នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍

ដំណាក់កាលក្នុងពេលធ្វើអស្សាមិករណ៍ ជាដំណាក់កាលមួយដែលលំបាកក្នុងការអនុវត្តដោយអាជ្ញាធរ ពីព្រោះដំណាក់កាលនេះ ជាដំណាក់កាលដែលផ្តាច់កម្មសិទ្ធិលើអចលនវត្ថុដោយមានការរុះរើសំណង់ពីទីកន្លែង ដែលត្រូវដំណើរការគម្រោងនេះ។ ជាការពិបាកមួយ នៅពេលដែលម្ចាស់កម្មសិទ្ធិករធ្វើការចាកចេញដោយពួកគេគិតថា មិនដឹងទៅរស់នៅទីណា ឬ ក៏សំណងមិនមានភាពគ្រប់គ្រាន់ក្នុងការរើចេញទៅរកទីកន្លែងថ្មីនោះតែងតែកើតមានឡើង។ ក្នុងករណីនេះ ប្រសិនបើមានម្ចាស់កម្មសិទ្ធិកររូបណា ដែលបដិសេធមិនព្រមទទួលយកសំណង ដែលគម្រោងនៃអស្សាមិករណ៍បានផ្តល់ឲ្យនោះទេ ពេលនោះនៅពេលដែលផុតកំណត់រយៈពេលដូចដែលបានបញ្ជាក់ក្នុងសេចក្តីជូនដំណឹងនោះទេ គណៈកម្មាធិការអស្សាមិករណ៍ នឹងអាចស្នើសុំការអន្តរាគមន៍ពីអាជ្ញាធរសាធារណៈ ឬ អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការស្របច្បាប់ ដើម្បីសម្រេចឲ្យបាននូវ លទ្ធកម្មជាក់ស្តែងទៅលើអចលនវត្ថុដែលត្រូវបានដកហូតនោះ រួមទាំងវិធានការបណ្តេញជនទាំងនោះចេញពីទីតាំងដកហូតផងដែរ។

កិច្ចដំណើរការអស្សាមិករណ៍ អាចចាប់ផ្តើមបានបន្ទាប់ពីមានការប្រកាស ឲ្យចេញដំណើរការដោយរដ្ឋាភិបាលក្នុងការដកហូតកម្មសិទ្ធិ បើទោះបីជា មានការពាក្យបណ្តឹងពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិទាំងឡាយណាដែលបានដាក់បណ្តឹងប្តឹងទៅ គណៈកម្មាធិការបណ្តឹងតវ៉ារួចរាល់ទាំងស្រុងក្តី។

### ២.២.១ ការដកហូតអចលនវត្ថុ

ដំណើរការដកហូតអចលនវត្ថុពីម្ចាស់កម្មសិទ្ធិករ ជាដំណើរការមួយផ្តាច់សិទ្ធិទាំងស្រុង ទៅលើដី ផ្ទះសម្បែង ដំណាំ ឬអ្វីផ្សេងៗទៀតដែលត្រូវកាត់យកមកធ្វើអស្សាមិករណ៍។ ការដកហូតកម្មសិទ្ធិលើអចលវត្ថុ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍ បានផ្តល់សំណងទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និងយុត្តិធម៌ តាមគោលការណ៍ និងនីតិវិធីនៃការទូទាត់សំណង[34]។ ការដកហូតនេះ អាចប្រព្រឹត្តទៅបាន បើទោះបីជាទំនាស់មិនទាន់បានធ្វើការដោះស្រាយហើយក្តី។

[33] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា រ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧

ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិលើ ដែលបានទូទាត់សំណងរបស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និងការដោះស្រាយដែរ[35]។

នៅក្នុងការដកហូតអចលនវត្ថុនេះ ត្រូវបែងចែកជា *ការដកហូតទាំងស្រុង ការដកហូតមួយផ្នែក* និង *ការកាន់កាប់បណ្តោះអាសន្ន* ទៅតាមស្ថានភាពនៃការធ្វើគម្រោងអស្សាមិករណ៍ដែលមានគោលបំណង ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ក្នុងការធ្វើឲ្យមានដំណើរការអភិវឌ្ឍជាតិ។

នៅក្នុងដំណាក់កាលនៃការដកហូតទាំងស្រុង គឺជាការដកហូតលើអចលវត្ថុទាំងមូល ដែលមាននៅលើដីទាំងអស់ ដោយគ្មានសល់កន្លែងណាមួយ ឬទុកឲ្យនៅទំនេរសម្រាប់អចលនវត្ថុនេះបានទេ។ ទំហំនៃដីទាំងអស់នេះគឺទុកសម្រាប់ ធ្វើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈរបស់រដ្ឋ។ ករណីដែលដី រងផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍នេះ ឬប៉ះពាល់តែផ្នែកណាមួយ (មិនប៉ះពាល់ចំទាំងអស់នោះទេ) គឺរដ្ឋក៏មិនអាចធ្វើការដកហូតលើដីនោះបានទាំងអស់នោះដែរ ទោះបីជាមានហេតុផលណាក៏ដោយ លុះត្រាតែមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុនោះ។

ដំណាក់កាលនៃការដកហូតមួយផ្នែក គឺជាដកហូតផ្នែកណាមួយនៃអចលវត្ថុទាំងមូល។ ការដកហូតមួយផ្នែកនេះ ធ្វើឡើងព្រោះតែគម្រោងនៃអស្សាមិករណ៍ បានធ្វើប៉ះពាល់តែចំផ្នែកណាមួយនៃទំហំអចលនវត្ថុនោះ ។ ប៉ុន្តែ នៅក្នុងដំណើរការដកហូតអចលលវត្ថុតែងតែធ្វើឲ្យមានផលប៉ះពាល់ ដល់ម្ចាស់កម្មសិទ្ធិនៃអចលនវត្ថុនោះ បើទោះបីវាជាការដកហូតតែមួយផ្នែកក៏ដោយ។ ហេតុនេះហើយ បានជាការដកហូតនេះ បានក្លាយទៅជាការដកហូតមួយនាំឲ្យមានផលវិបាកទៅដល់ម្ចាស់អចនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុដែលត្រូវបានដកហូតនោះ។ ផ្ទុយទៅវិញ ការដកហូតដោយគម្រោងត្រង់ចំណុចនេះ វាក៏បានបង្កប់នូវផលវិជ្ជមានផងដែរថា បើការដកហូតដីសម្រាប់ការធ្វើអស្សាមិករណ៍រួចមក តែម្ចាស់កម្មសិទ្ធិមានទំហំដីដែលធំ ដូចនេះម្ចាស់កម្មសិទ្ធិមានលទ្ធភាពនៅសល់ដី សម្រាប់ការប្រកបរបររកស៊ី និងរស់នៅ និងដីមានតម្លៃថ្លៃ (ត្រូវចំគម្រោងណាដែលផ្តល់ទីតាំងងាយស្រួល សម្រាប់ធ្វើការធ្វើជំនួញ)។

ការកាន់កាប់បណ្តោះអាសន្ន គឺជាការកាន់កាប់មួយដែលស្ថិតនៅក្នុងស្ថានភាពពិសេស និងបន្ទាន់ដែលសុវត្ថិភាពសាធារណៈតម្រូវ។ ការកាន់កាប់នេះមានដូចជា ការប្រយុទ្ធប្រឆាំងគ្រោះអគ្គីភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាម ដែលប្រុងនឹងកើត និងការវាយប្រហារដោយភេរវកម្ម និងស្ថានភាពផ្សេងៗទៀត។ ដូចនេះ រាជរដ្ឋាភិបាលអាចធ្វើការ ដកហូតទ្រព្យសម្បត្តិជាបណ្តោះអាសន្នសិន ដោយមិនចាំបាច់មានការពិគ្រោះយោបល់ជាមុនជាមួយម្ចាស់កម្មសិទ្ធិឡើយ។ ការដែលធ្វើបែបនេះ គឺក្នុងគោលដៅជាតិតែមួយប៉ុណ្ណោះ ក្នុងការ

[35] មាត្រា១៩ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ធ្វើការគ្រប់គ្រងស្ថានភាពឲ្យបានទាន់ពេលវេលា។ ព្រោះថា បើត្រូវមានការអនុញ្ញាតជាមុនពីម្ចាស់កម្មសិទ្ធិ ឬនៅធ្វើតាមនីតិវិធីត្រូវតែចំណាយពេលវេលាយូរ ដូចនេះអាជ្ញាធរមិនអាចធ្វើការទប់ស្កាត់បញ្ហាដែលកើតមានចំពោះមុខបានទាន់ពេលវេលាបានឡើយ។ នៅពេលបំពេញភារកិច្ចបានចប់សព្វគ្រប់ រដ្ឋនឹងប្រគល់អចលនវត្ថុ ដែលអាចធ្វើការដកហូតនោះជូនទៅម្ចាស់អចលនវត្ថុវិញ។ រាជរដ្ឋាភិបាលមានឆន្ទានុសិទ្ធិនៅក្នុងការធ្វើអស្សាមិករណ៍ ព្រោះវាជាករណីបន្ទាន់ និងចាំបាច់ដែលផលប្រយោជន៍តម្រូវ។ បើពុំមាន អំណាចឆន្ទានុសិទ្ធិសម្រាប់រាជរដ្ឋាភិបាលនោះទេ ផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិនឹងមានការខូតខាតធ្ងន់ធ្ងរជាមិនខាន។

បន្ថែមពីនោះ គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងនៃសេក្តីសម្រេចនៃអស្សាមិករណ៍ និងត្រូវផ្តល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍[36]។ ស្របពេលនៃការដកហូតអចលនវត្ថុនេះផងដែរ ក៏តម្រូវឲ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិលើអចលនវត្ថុមានកាតព្វកិច្ចមួយចំនួនទៀតផងដែរ ដែលត្រូវបំពេញពេលមានការដកហូត។ សម្រាប់កាតព្វកិច្ច ដែលត្រូវបំពេញនោះមានដូចជា៖

- ការរុះរើសំណង់ ៖ ការរុះរើសំណង់នេះ គឺជាកាតព្វកិច្ចនៃជំហានដំបូងរបស់ម្ចាស់អចលនវត្ថុ ដើម្បីធ្វើការផ្លាស់ប្តូរ ពីទីកន្លែងរស់នៅចាស់ទៅទីកន្លែងរស់នៅថ្មី។ ការរុះរើនេះ ធ្វើឡើងក្រោយពីមានការប្រកាសសេចក្តីជូនដំណឹងពីគណៈកម្មាធិការអស្សាមិករណ៍ អំពីការរុះរើលំនៅឋានទៅទីតាំងផ្សេងទៀត។ សម្រាប់ក្នុងករណីដែលរយៈពេលកំណត់បានមកដល់ តែម្ចាស់អចលនវត្ថុ មិនព្រមក្នុងការរុះរើ ឬចាកចេញពីអចលនវត្ថុ ដែលជាកម្មសិទ្ធិនៃការដកហូតនេះទេ អាជ្ញាធរនឹងធ្វើការបង្ខំក្នុងការរុះរើសំណង់នេះ ចំណែកតម្លៃនៃការរុះរើសំណង់នេះ ម្ចាស់សំណងគឺជាភាគីដែលត្រូវតែចេញជំនួយរដ្ឋផងដែរ។ ការបង្ខំឲ្យរុះរើចេញដោយអាជ្ញាធរបែបនេះ ព្រោះមិនចង់ឲ្យដំណើរការរាំងស្ទះដល់គម្រោងនៃអស្សាមិករណ៍។ នៅពេលមានការបង្ខំ គឺមានការចូលរួមពីស្ថាប័នអយ្យការ និង កងរក្សាសណ្តាប់ធ្នាប់ផងដែរ ដើម្បីបញ្ចៀសពីការបង្កអសន្តិសុខពីសំណាក់ម្ចាស់អចលវត្ថុ ដែលប្រឆាំងការតវ៉ាមិនព្រមចាកចេញពីទីកន្លែងដែលបានដកហូត។
- ការផ្តាច់សិទ្ធិលើអចនវត្ថុ ៖ ក្រោយពីមានការរុះរើសំណង់លើគម្រោងដែលត្រូវធ្វើអស្សាមិករណ៍ ម្ចាស់កម្មសិទ្ធិត្រូវបាត់បង់សិទ្ធិ ដោយអចលនវត្ថុបានក្លាយជាទ្រព្យសម្បត្តិរដ្ឋ។ ចំណែកអចនវត្ថុដែលប្រមូលបាននោះនឹងយកទៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិសម្រាប់ការអភិវឌ្ឍប្រទេស។ ការផ្តាច់កម្មសិទ្ធិលើអចលនវត្ថុនេះ កើតឡើងបានពេលដែលម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់

[36] មាត្រា២១ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

សិទ្ធិត្រូវផ្ដាច់កម្មសិទ្ធិលើអចលនវត្ថុ តាមរយៈការទទួលយកសំណងពីគណៈកម្មាធិការអស្សាមិករណ៍ជាមុនសិន។ ចាប់តាំងពីថ្ងៃចេញសេចក្ដីប្រកាសនៃគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ មិនអាចធ្វើការលក់ និងផ្ទេរកម្មសិទ្ធិទៅអ្នកផ្សេងឡើយ។ ក្នុងករណីបើមាន រាល់ការលក់និងផ្ទេរទាំងនោះត្រូវចាត់ទុកជាមោឃៈ។

- ការហាមឃាត់ការសាងសង់បន្ថែម ៖ ក្នុងការសាងសង់បន្ថែម ត្រូវបានហាមឃាត់ជាដាច់ខាត ព្រោះអចលនវត្ថុនឹងត្រូវធ្វើការដកហូត ដើម្បីយល់ទៅធ្វើក្នុងដំណើរការគម្រោង។ កាលណាមានការសាងសង់បន្ថែម នាំឲ្យមានការខូចខាតកាន់តែច្រើន និងទំហំកាន់តែធំ នាំឲ្យរដ្ឋត្រូវផ្ដល់សំណងកាន់តែច្រើន និងខាតពេលក្នុងរុះរើ ហើយពេលខ្លះក្លាយជាចេតនារបស់ម្ចាស់កម្មសិទ្ធិដើម្បីទាមទារសំណងពីរដ្ឋ។ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចធ្វើការកាន់កាប់អចលនវត្ថុបានរយៈពេល ១ ខែ ដែលបានកំណត់ក្នុងសេចក្ដីប្រកាសសម្រាប់ការរុះរើទៅទីតាំងថ្មី ដូចនេះរយៈពេល ១ ខែ នឹងផ្ដល់លទ្ធភាពឲ្យម្ចាស់កម្មសិទ្ធិរស់នៅបន្តរុះរើ ឬទទួលផលដំណាំដែលមាននៅលើដីដែលត្រូវធ្វើអស្សាមិករណ៍នោះ[37]។

### ២.២.២ ការអនុវត្តគម្រោង

ការអនុវត្តគម្រោង គឺជាដំណើរការមួយដែលសំខាន់ ក្រោយពីអនុវត្តនីតិវិធីអស្សាមិករណ៍រួចមក ម្ចាស់គម្រោងត្រូវធ្វើដំណើរការនៃអនុវត្តគម្រោងឲ្យបាន ព្រោះកាលណាបើមានការពន្យារពេល ឬ ក៏ប្រើប្រាស់អចលនវត្ថុដែលបានមកពីដកហូត ទៅប្រើប្រាស់ខុសបំណងដែលបានគ្រោងទុក។ ប្រសិនបើរដ្ឋ ឬម្ចាស់គម្រោងទុកអចលនវត្ថុនោះឲ្យនៅទំនេរចោលដោយគ្មានហេតុផលសមរម្យ ឬ ផ្ទេរទៅឲ្យឯកតិយជនណាម្នាក់ និងមិនបានអនុវត្តន៍ទៅតាមគម្រោងដែលបានគ្រោងទុកនោះ គឺអាចមានផលប៉ះពាល់ដល់រាជរដ្ឋាភិបាល ដែលធ្វើឲ្យបាត់បង់ការទុកចិត្តពីសំណាក់ប្រជាពលរដ្ឋទៅលើរាជរដ្ឋាភិបាល បើមិនដូចនោះទេនឹងកើតមានវិវាទរវាងប្រជាពលរដ្ឋនឹងរាជរដ្ឋាភិបាល ឬ ម្ចាស់អចលនវត្ថុអាចនឹងទាមទារយកទ្រព្យដែលធ្វើការដកហូតនោះមកវិញផងដែរ។ ប៉ុន្តែរដ្ឋក៏អាចអចលនវត្ថុនោះនៅទំនេរសិនក៏បាន បើក្នុងករណីដែលស្ថានភាពនៃការអនុវត្តគម្រោងមិនអំណោយផងដូចជា ក្នុងករណីប្រធានសក្ដិ ឬករណីផ្សេងៗទៀតដែលមិនអាចអនុវត្តគម្រោងនោះបាន[38]។

## ២.៣ ការទូទាត់សំណងនៃអស្សាមិករណ៍

ការទូទាត់សំណង ជាដំណាក់កាលសំខាន់មួយដែលត្រូវតែកើតឡើងនៅក្នុងដំណើរការអស្សាមិករណ៍ ព្រោះមុនការចាប់ផ្ដើមគម្រោង លុះត្រាមានការផ្ដល់នូវសំណងដោយសមរម្យ និងយុត្តិធម៌ទៅដល់ម្ចាស់អចលន

[37] អត្ថបទ "គុណសម្បត្តិនៃការធ្វើអស្សាមិករណ៍" ចូលមើលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២១

[38] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា វ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧

វត្ថុ និង/ឬ ម្ចាស់សិទ្ធិជាមុនសិន។ សំណង ដែលត្រូវផ្តល់ជូនម្ចាស់កម្មសិទ្ធិ ត្រូវបានវាយតម្លៃដោយអាជ្ញាធរមានសមត្ថកិច្ច ជាមុនរួចជាស្រេចដូចដែលបានកំណត់ទុកក្នុងច្បាប់អស្សាមិករណ៍។ ដូចនេះ រាល់អចលនវត្ថុដែលត្រូវធ្វើអស្សាមិករណ៍ មិនអាចមានការកំណត់នូវតម្លៃពីភាគីម្ចាស់កម្មសិទ្ធិ ដូចក្នុងករណីមានការទិញ-លក់ដីឯកជនបានទេ ដោយមានតែភាគីរដ្ឋតែប៉ុណ្ណោះដែលមានសិទ្ធិក្នុងការកំណត់លើតម្លៃនៃអចលនវត្ថុដែលត្រូវធ្វើអស្សាមិករណ៍នោះ (ការលក់ដោយបង្ខំ)។

ប៉ុន្តែបើទោះបីជារដ្ឋជាអ្នកកំណត់តម្លៃលើអចលនវត្ថុដែលត្រូវធ្វើអស្សាមិករណ៍ក្តី ក៏ប្រាក់សំណងដែលត្រូវផ្តល់ឲ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួសទៅកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍។ ថ្លៃទីផ្សារ និងថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍[39]។

**២.៣.១ គោលការណ៍នៃការផ្តល់សំណង**

ជាទូទៅ គោលការណ៍នៃការផ្តល់សំណងត្រូវធ្វើស្របតាមច្បាប់អស្សាមិករណ៍ ក្នុងនោះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបានសំណងពីការខូចខាតអចលនវត្ថុជាក់ស្តែង ដែលមានចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និងយុត្តិធម៌[40]។ ការសងសំណងអស្សាមិករណ៍ត្រូវគិតតាមថ្លៃទីផ្សារ ឬថ្លៃជំនួស គឺជាវិធីសាស្ត្រមួយសម្រាប់ផ្តល់សំណងដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិបានដោយមានការពេញចិត្ត។ ថ្លៃទីផ្សារជាតម្លៃព្រមព្រៀងគ្នា រវាងអ្នកលក់ដែលមានឆន្ទៈលក់ និងអ្នកទិញដែលមានឆន្ទៈទិញ នៅក្នុងជីវភាពសាមញ្ញ គឺភាគីទាំងសងខាងមានឯករាជ្យ[41] ។ ចំណែក ថ្លៃជំនួស គឺជាការវាយតម្លៃទ្រព្យសម្បត្តិដែលកំណត់អំពីបរិមាណនៃសំណងដែលគ្រប់គ្រាន់សម្រាប់ជំនួសទ្រព្យដែលបានបាត់បង់រួមមានទាំង រាល់ការចំណាយប្រតិបត្តិការចាំបាច់នានា[42]។

ប្រាក់សំណង ត្រូវទូទាត់ជាប្រាក់សាច់ប្រាក់ ជាទ្រព្យ ឬជាសិទ្ធិជំនួសទៅតាមភាពជាក់ស្តែងដែលមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិពីគណៈកម្មាធិការអស្សាមិករណ៍[43]។ បន្ថែមពីនោះ ប្រាក់សំណង ត្រូវគិតតាមតំលៃសំណងសរុប ដកចំនួនទឹកប្រាក់ពន្ធប្រថាប់ត្រា និង/ឬ ពន្ធលើដីមិនប្រើប្រាស់ដែល

---

[39] មាត្រា២២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[40] មាត្រា២៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[41] សៀវភៅច្បាប់អចលនវត្ថុនៅកម្ពុជា រៀបរៀងដោយ East- West management institute.inc នៅខែវិច្ឆិកា ឆ្នាំ២០១២ ជំពូកទី១១ ទំព័រ ៣៧៦

[42] សេចក្តីព្រាង "ក្របខណ្ឌគោលនយោបាយសម្រាប់ការតាំងទីលំនៅឡើងវិញ" ឆ្នាំ២០១៦

[43] វាក្យខណ្ឌ១ មាត្រា២៤ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

កន្លងមកមិនមានការបង់ជូនរដ្ឋ ហើយគណៈកម្មាធិការត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិការជាតិ តាមនីតិវិធីជាធរមាន។ កន្លែងនេះចង់បញ្ជាក់ និងមានការក្រើនរំលឹកដល់ម្ចាស់អចលនវត្ថុទាំងឡាយ ដែលតែងតែភ្លេច ឬមិនបានគោរពកាតព្វកិច្ចក្នុងនាមជាពលរដ្ឋ ក្នុងការបង់ពន្ធជូនរដ្ឋអំណាច ដូចនេះពេលមានការសើរើ ឬពេលមានការទូទាត់ផ្សេងៗដែលមានជាប់ពាក់ព័ន្ធជាមួយនឹងប្រជាពលរដ្ឋខ្លួនឯង និងរដ្ឋ។

ក្រលេកមកវិញ ជុំវិញគោលការណ៍នៃការផ្តល់សំណងដោយសមរម្យ និងយុត្តិធម៌ដែលមានចែងនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍នេះ បានធ្វើឲ្យមានសំណួរជាច្រើនបានចោទសួរឡើងថា តើភាពសមរម្យ និងយុត្តិធម៌នៃសំណងទាំងនោះមានការគណនាច្បាស់លាស់ដែរឬទេ? តើការគណនាសំណងនោះធ្វើឡើងបានតាមរបៀបណា? ដើម្បីធ្វើឲ្យចំណុចនៃគោលការណ៍នៃការផ្តល់សំណងអស្សាមិករណ៍ មានភាពកាន់តែច្បាស់លាស់ ខ្ញុំនឹងធ្វើការរៀបរាប់ដូចតទៅ៖

- ភាពសមរម្យ និងយុត្តិធម៌ ដែលមានចែងក្នុងច្បាប់នៃអស្សាមិករណ៍ គឺមានន័យថាបន្ទាប់ពីការឆ្លងកាត់ការវាយតម្លៃជាក់លាក់ តាមថ្លៃទីផ្សារ និងថ្លៃជំនួស ដោយការវាយតម្លៃនេះ មានគណៈកម្មការវាយតម្លៃ ឬភ្នាក់ងារឯករាជ្យដែលជ្រើសរើសដោយគណៈកម្មាធិការអស្សាមិករណ៍ជាអ្នកវាយតម្លៃ។
- របៀបនៃការវាយតំលៃលើសំណង ដែលសមរម្យ និងយុត្តិធម៌នោះ ត្រូវធ្វើឡើងតាមរូបមន្ត ឬ តារាងក្នុងការកំណត់ដើម្បីធ្វើការវាយតំលៃ។ ជាធម្មតា គោលការណ៍នៃការវាយតំលៃនេះ ត្រូវធ្វើនៅថ្ងៃចេញសេចក្តីប្រកាសនៃគម្រោងអស្សាមិករណ៍។ ចំណែកការកំណត់តំលៃនៃផលប៉ះពាល់ដោយអស្សាមិករណ៍ ត្រូវបូកបញ្ចូលទាំងអស់រួមមាន ព្យសនះកម្ម និងផលរំខានផ្សេងទៀតដែលកើតមានដោយសារតែការធ្វើអស្សាមិករណ៍នេះ។ ក្រោយការវាយតំលៃបានបញ្ចប់សព្វគ្រប់ តែមានការឡើងនូវតំលៃដីជាបន្តបន្ទាប់ ប្រកាសនេះមិនអាចធ្វើការទាមទារយកឯកសារថ្មីបានទេ។ ការដែលមិនអាចធ្វើការទាមទារឯកសារថ្មីនេះបាន ជាវិធីសាស្ត្រមួយចៀសវាងនាំឲ្យដំណើរការនៃគម្រោងអស្សាមិករណ៍មានភាពអាក់ខានក៏ប៉ុន្តែវិធីសាស្ត្រនេះក៏បានជះផលប៉ះពាល់មួយចំនួនដែរដូចជា មានប្រជាពលរដ្ឋមួយចំនួនដែលជាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ស្នើសុំរដ្ឋឲ្យមានការតំឡើងថ្លៃដីដែលរដ្ឋត្រូវផ្តល់សំណងនោះ ព្រោះភាគច្រើននៃប្រជាពលរដ្ឋគិតថា ប្រសិនបើមានការអស្សាមិករណ៍នៅតំបន់ដែលពួកគាត់កំពុងរស់នៅដូចនេះតំលៃដីនឹងចាប់ផ្តើមមានទីផ្សារ។ ការគិតបែបនេះ បានធ្វើឲ្យមានបញ្ហាប្រឈមជាច្រើន ក្នុងនោះពេលខ្លះមានការធ្វើជាបាតុកម្មធំៗពីសំណាក់ប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិទៀតផងក៏មាន។

### ២.៣.២ នីតិវិធីនៃការផ្តល់សំណង

បែបបទ និងនីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទោះបីជានីតិវិធីនៃការទូទាត់សំណង មិនបានចែងនៅក្នុងច្បាប់អស្សាមិករណ៍ឲ្យបាន

ច្បាស់លាស់យ៉ាងណាក្តី ក៏នីតិវិធីនៃសំណងនៃអស្សាមិករណ៍នេះ ត្រូវបានធានាច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ភូមិបាលផងដែរ ដោយតម្រូវឲ្យអាជ្ញាធរត្រូវតែគោរពប្រតិបត្តិតាមជាដាច់ខាត។ ការធានានេះ គឺចង់សំដៅដល់ការប្រព្រឹត្តនៃអាជ្ញាធរ ក្នុងការផ្តល់សំណងដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដោយផ្អែកលើមូលដ្ឋានច្បាប់ក្នុងការផ្តល់សំណង។ ម្យ៉ាងការផ្តល់សំណងនេះទៀតសោត នឹងត្រូវផ្តល់ជាមុនដល់ម្ចាស់អចលវត្ថុ ដោយសមរម្យ និងយុត្តិធម៌ប្រកបដោយតម្លាភាព។

ជាទូទៅនៅក្នុងនីតិវិធីនៃការផ្តល់សំណងនេះផងដែរ ក៏មានដំណាក់កាលនៃការទូទាត់លំអិតបន្ថែមដើម្បីធានាថាសំណង ដែលបានផ្តល់ម្ចាស់កម្មសិទ្ធិពិតជាមានតម្លាភាព សមរម្យ និងយុត្តិធម៌ប្រាកដមែនជៀសវាងបង្កជាបញ្ហាប្រឈមណាមួយកើតឡើង។ នៅក្នុងនីតិវិធីនៃការផ្តល់សំណងនេះ មានដូចជា៖

**ការគណនាសំណង** ៖ ការទូទាត់សំណងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការគណនាអំពីទំហំនៃសំណង ដែលត្រូវផ្តល់ជូនម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិជាមុនសិន។ ជាទូទៅ ការទូទាត់សំណងចំពោះអចលនវត្ថុ គ្រាន់តែជាសំណងមួយផ្នែកដែលមិនទាន់បូកបញ្ចូលចំពោះសំណងដទៃទៀតទេ ព្រោះសំណងដែលបានកំណត់នេះគ្រាន់តែជាសំណងនៃតំលៃដី និងតំលៃផ្ទះប៉ុណ្ណោះ។ តែប្រសិនបើម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិចង់ឲ្យមានការទូទាត់សំណងផ្សេងទៀតមានដូចជា សំណងព្យសនកម្មជាដើម ដូចនេះគេត្រូវធ្វើការគណនាសំណងព្យសនកម្មនេះផងដែរ។ ចំពោះការទូទាត់សំណងព្យសនកម្ម គឺជាការគិតដល់ព្យសនកម្មទាំងឡាយណា ដែលកើតឡើងពេលមានការដកហូតដោយសារគម្រោងអស្សាមិករណ៍ ក្នុងគោលបំណងបម្រើផលប្រយោជនសាធារណៈ និងផលប្រយោជន៍ជាតិ ប៉ុន្តែធ្វើឲ្យមានផលប៉ះពាល់ដល់ការធ្វើអាជីវកម្ម ឬមុខរបររកស៊ី ចិញ្ចឹមជីវិតរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ។ ដូចនេះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចធ្វើការទាមទារព្យសនកម្ម ដែលកើតឡើងដោយការធ្វើអស្សាមិរណ៍ ដោយហេតុថាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ បានបាត់បង់ ឬមិនអាចធ្វើអាជីវកម្ម រកស៊ីចិញ្ចឹមជីវិតបានទៀត។ ដូចនេះ ការទូទាត់សំណងត្រូវគិតបញ្ចូលទាំងទំហំនៃការខូតខាតថាតើដល់កម្រិតណា ចំណែកអាជ្ញាធរ នឹងចេញសំណងសម្រាប់ការខូចខាតនេះផងដែរ ដោយបូកបញ្ចូលទៅក្នុងតំលៃនៃអចលវត្ថុជាមួយ។ ក្រៅពីសំណងព្យសនកម្ម ក៏នៅមានសំណងបន្តបន្ទាប់ផ្សេងទៀត ដែលត្រូវបូកក្នុងសំណងព្យសនកម្ម ដោយសំណងទាំងនោះមានដូចជា ដើមឈើប្រភេទហូបផ្លែ ថ្លៃជួលសម្រាប់ធ្វើការរុះរើផ្ទះសម្បែង និងការដឹកជញ្ជូន (បើមាន)។ ចំពោះការទូទាត់សំណងប្រភេទនេះ ត្រូវបានវាយតំលៃដោយអាជ្ញាធរដោយមានភ្ជាប់នូវតារាងរាយនាមជាច្រើនលើព្យសនកម្ម ដែលកើតមានទាំងនោះពេលត្រូវបានការកំណត់តំលៃរួចហើយ លទ្ធផលនៃសំណងត្រូវទូទាត់ជូនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិប្រកបដោយតម្លាភាព និងគណនីយភាព។

**រូបមន្តនៃការទូទាត់សំណង** ៖ ដូចមានចែងនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍ មាត្រា២៤ គឺការទូទាត់សំណងត្រូវធ្វើតាមរយៈសាច់ប្រាក់ និង សិទ្ធិជំនួស ឬទ្រព្យជំនួស។ ដូចនេះ នាងខ្ញុំសូមធ្វើការរៀបរាប់លំអិតដូចខាងក្រោម៖

- **តាមរយៈសាច់ប្រាក់ ៖** អាជ្ញាធរអាចធ្វើការចរចារជាមួយម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិតាមរយៈការវាយតម្លៃរបស់គណៈកម្មការ ឬភ្នាក់ងារឯករាជ្យដែលបានជ្រើសរើសដោយគណៈកម្មាធិការអស្សាមិករណ៍ ដោយការផ្តល់សំណងនេះត្រូវធ្វើឡើងក្នុងរូបភាពការទូទាត់ជាសាច់ប្រាក់។ ប៉ុន្តែប្រសិនករណីមិនមានថវិការគ្រប់គ្រាន់នោះទេ ការដំណើរការអនុវត្តគម្រោងអស្សាមិករណ៍មិនអាចប្រព្រឹត្តទៅបាននោះទេ។
- **តាមរយៈសិទ្ធិជំនួស ៖** សំណងតាមរយៈសិទ្ធិជំនួស ឬអាចហៅម្យ៉ាងទៀតថា ជាថ្លៃជំនួសនេះមាននីតិវិធីជាច្រើនក្នុងការគណនា។ ក្នុងនោះ (១) ចំពោះដីកសិកម្ម៖ ថ្លៃជំនួស គឺជាថ្លៃដែលគណនាមុនពេលមានគម្រោង ឬមុនពេលជន្លៀសដោយយកតាមថ្លៃណាមួយដែលខ្ពស់ជាង ដែលគិតតាមតម្លៃទីផ្សារនៃដីដែលមានសក្តានុពលក្នុងការផលលិត ឬ ការប្រើប្រាស់ដូចគ្នា ដែលស្ថិតនៅជិតៗដីធ្លីដែលរងផលប៉ះពាល់ បូកនឹងថ្លៃរៀបចំដីរហូតដល់កម្រិតដែលប្រហាក់ប្រហែលនឹងថ្លៃដីដែលរងផលប៉ះពាល់ បូកនឹងថ្លៃចុះបញ្ជីនានា និងពន្ធលើការផ្ទេរកម្មសិទ្ធិ។ (២) ចំពោះដីតាមទីប្រជុំជន ៖ គឺគណនាថ្លៃទីផ្សារមុនពេលជន្លៀស នូវដីធ្លីដែលមានទំហំ និងការប្រើប្រាស់ដូចគ្នា ដែលមានហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មសាធារណៈប្រហាក់ប្រហែលគ្នា ឬដែលបានកែលម្អ និងស្ថិតនៅទីកន្លែងដែលជិតនឹងដីធ្លីដែលរងផលប៉ះពាល់ បូកនឹងថ្លៃចុះបញ្ជីនានា និងពន្ធលើការផ្ទេរកម្មសិទ្ធិ។ (៣) ចំពោះផ្ទះ និងរចនាសម្ព័ន្ធដទៃទៀត ៖ គឺត្រូវគណនាតាមថ្លៃទីផ្សារ នូវសម្ភារៈសម្រាប់សាងសង់រចនាសម្ព័ន្ធជំនួសមួយនូវទំហំ និងគុណភាពប្រហាក់ប្រហែលគ្នានឹងផ្ទះ និងរចនាសម្ព័ន្ធដែលរងផលប៉ះពាល់ ឬដើម្បីជួសជុលផ្នែកនៃរចនាសម្ព័ន្ធដែលរងការប៉ះពាល់ បូកនឹងថ្លៃដឹកជញ្ជូនសម្ភារៈសាងសង់មកកាន់ទីកន្លែងសំណង់ បូកនឹងថ្លៃពលកម្ម និងថ្លៃឈ្នួលអ្នកម៉ៅការ បូកនឹងថ្លៃចុះបញ្ជីនានា និងពន្ធលើការផ្ទេរកម្មសិទ្ធិ។ ក្នុងការគណនាសំណងតាមរយៈសិទ្ធិជំនួសនេះ មិនមានថ្លៃរំលោះសម្រាប់ទ្រព្យ និងតំលៃសម្ភារៈសម្រាប់ស្រោចស្រង់ ក៏ដូចជាថ្លៃអត្ថប្រយោជន៍ដែលកើតចេញពីគម្រោង ដែលត្រូវដកចេញនៅពេលមានការវាយតំលៃទ្រព្យសម្បត្តិដែលរងផលប៉ពាល់នោះ។ ក្នុងករណី ដែលច្បាប់នៅក្នុងប្រទេស

មិនមានភាពស្របគ្នាក្នុងការផ្តល់សំណាង តាមរយៈសិទ្ធិជំនួសទេនោះ សំណាងនៅក្នុងច្បាប់ក្នុងប្រទេស ត្រូវតែបំពេញដោយវិធានការបន្ថែម ដើម្បីបំពេញតាមស្តង់ដារនៃសិទ្ធិជំនួស[44]។

- **តាមរយៈជាទ្រព្យ** ៖ សំណាងជាទ្រព្យសំដៅលើ ការសងទាំងឡាយណាដែលមិនមែនស្ថិតនៅក្នុងប្រភេទសំណាងជាសាច់ប្រាក់ ឬជាសិទ្ធិជំនួស។ សំណាងជាទ្រព្យ បានផ្តល់ការអនុញ្ញាតដល់ម្ចាស់អចលនវត្ថុដែលរងការដកហូត បាននទទួលនូវកម្ចីពិសេស និងការជួលពិសេសជាដើម។ល។

[44] សេចក្តីព្រាង "ក្របខណ្ឌគោលនយោបាយសម្រាប់ការតាំងទីលំនៅឡើងវិញ" ឆ្នាំ២០១៦

# ជំពូកទី៣
# វិវាទដែលប្រឈមនឹងការធ្វើអស្សាមិករណ៍

ជាទូទៅ វិវាទដែលប្រឈមនឹងតែងតែកើតមានឡើងនៅកន្លែងណាដែលមានការពាក់ព័ន្ធ ទៅលើសិទ្ធិការអាស្រ័យផល ការគ្រប់គ្រងទ្រព្យសម្បត្តិ ឬកន្លែងណាដែលអាចនឹងទាញយកផលប្រយោជន៍បានជាដើម។ ជាក់ស្តែង នៅក្នុងការធ្វើអស្សាមិករណ៍ក៏ដូចគ្នា យើងអាចកត់សម្គាល់ឃើញថាកន្លែងណាមានដែលមានការអភិវឌ្ឍ មានការរីកចម្រើនជាបន្តបន្ទាប់ កន្លែងនោះនឹងកើតនឹងតែងតែមានបញ្ហាប្រឈមលេចឡើងមកស្រប ជាមួយគ្នាផងដែរ។ វិវាទដែលប្រឈមទាំងនោះ អាចនឹងកើតមានឡើងនៅមុនពេលធ្វើអស្សាមិករណ៍ ឬ ក្នុងអំឡុងពេលអស្សាមិករណ៍ ឬពេលដែលមានការទូទាត់សំណងអស្សាមិករណ៍ជាដើម ដែលបញ្ហាទាំងនេះពិតជាទាមទារឲ្យរដ្ឋាភិបាលដាក់ចេញនូវវិធានការណ៍ផ្សេងៗ និងរកស្វែងរកដំណោះស្រាយឲ្យខានតែបានចៀសវាងនាំឲ្យមានការរាក់ខាននូវកិច្ចការអភិវឌ្ឍប្រទេសជាតិ។ ដូចគ្នានេះផងដែរ ការដោះស្រាយវិវាទត្រូវបានចែងនៅជំពូកទី៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ចែងនូវគោលការណ៍ជាមូលដ្ឋានមួយចំនួន និងនីតិវិធីសម្រាប់ប្តឹងតវ៉ាដែលប្រជាពលរដ្ឋអាចប្រើបាននៅដំណាក់កាលផ្សេងៗគ្នានៃវគ្គរបស់គម្រោងអស្សាមិករណ៍។ ប៉ុន្តែ មានតែបីមាត្រាប៉ុណ្ណោះ ដែលត្រូវបានចែងនៅក្នុងជំពូកនេះ ដូចនេះសេចក្តីលំអិតភាគច្រើននឹងមានចែងបន្ថែមនៅក្នុងអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងៗទៀត សម្រាប់ធ្វើការណែនាំក្នុងការអនុវត្តច្បាប់អស្សាមិករណ៍នេះ [45]។

ម្យ៉ាងវិញទៀត ដោយសារតែការធ្វើអស្សាមិករណ៍ បានធ្វើឲ្យមានការប៉ះពាល់ដល់ទ្រព្យសម្បត្តិដែលជាអចលនវត្ថុរបស់ប្រជាពលរដ្ឋផងនោះ បញ្ហាចៀសមិនផុតតែងកើតមានឡើង។ ភាគច្រើន នៃបញ្ហាប្រឈមដែលកើតមាន គេសង្កេតឃើញថាមានបញ្ហាដូចជា បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋ បញ្ហាប្រឈមរវាងរដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ និងនៅមានបញ្ហាប្រឈមផ្សេងៗទៀត។ល។

ដើម្បីកាន់តែងាយស្រួលយល់ក្នុងចំណុចបញ្ហាប្រឈមនេះ ខ្ញុំនឹងធ្វើការពន្យល់លំអិតនៅចំណុចនីមួយៗដូចនៅចំណុចបន្ទាប់ខាងក្រោម។

## ៣.១ បញ្ហាប្រឈម

### ៣.១.១ បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋ

ដើម្បីធ្វើអស្សាមិករណ៍ប្រព្រឹត្តទៅបានដោយរលូន រដ្ឋនឹងត្រូវដកហូតនៅអចលនវត្ថុរបស់ប្រជាពលរដ្ឋត្រង់ចំណុចណាដែលគម្រោងតម្រូវឲ្យមានការដកហូត ក្រោមហេតុផលបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ ប៉ុន្តែ បើនិយាយពីរូបភាពនៃការអនុវត្តជាក់ស្តែងវិញ បញ្ហាការដកហូតនេះវាពិតជាមិន

[45] សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែនពិសិដ្ឋ និងកញ្ញា រ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧ ទំព័រ២១

មានភាពងាយស្រួលឡើយ ព្រោះវាទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋ ពិសេសលើកម្មសិទ្ធិ។ ប្រសិនបើ ការដកហូតប្រព្រឹត្តមិនមានតម្លាភាពតាមនីតិវិធី សំណងគ្មានភាពសមរម្យ និងយុត្តិធម៌សម្រាប់ផ្តល់ជូនប្រជាពលរដ្ឋពេលធ្វើគម្រោងអស្សាមិករណ៍ទេនោះ បញ្ហាប្រឈមរវាងរដ្ឋ និងប្រជាពលរដ្ឋច្បាស់ជាកើតមានឡើងជាក់ជាមិនខាន។ បញ្ហាប្រឈមទាំងនេះ ភាគច្រើនឃើញថាកើតមានព្រោះប្រជាពលរដ្ឋមិនអាចទទួលយកសំណងដែលបានផ្តល់ជូនពួកគាត់ មិនទាន់ការស្វែងយល់ស៊ីជម្រៅពីអ្វីជាការធ្វើអស្សាមិករណ៍ ចង់ទាមទារបន្ថែមនូវសំណងដែលផ្តល់ជូន និងមិនចង់ចាកចេញពីកន្លែងដែលត្រូវដកហូតធ្វើអស្សាមិករណ៍។ល។

នៅក្នុងករណីផ្សេងៗគ្នា ដែលបានលើកឡើងខាងលើនេះ យើងឃើញថាមានករណីចំនួន ៣ ដែលតែងតែកើតមានបញ្ហាប្រឈមពេលមានការធ្វើអស្សាមិករណ៍ ក្នុងនោះមានដូចជាៈ

ទីមួយ *ការមិនព្រមទទួលសំណងពីអាជ្ញាធរ* ព្រោះប្រជាពលរដ្ឋមួយចំនួនធំគិតថា កាលណាមានការធ្វើអស្សាមិករណ៍លើតំបន់ណាមួយ តំបន់នោះនឹងមានតម្លៃទីផ្សារដីឡើងថ្លៃ ដូចនេះប្រសិនបើរដ្ឋមិនអាចផ្តល់ជូននូវសំណងដែលមានតម្លៃខ្ពស់ ដូចដែលភាគីប្រជាពលរដ្ឋយល់ឃើញថាអាចនឹងទទួលបានពីរដ្ឋនោះទេ ក្រុមប្រជាពលរដ្ឋនឹងបដិសេធមិនព្រមទទួលសំណង ដោយហេតុផលសំអាងថាសំណងដែលទទួលបាន មិនមានភាពសមរម្យ និងយុត្តិធម៌។ ម្យ៉ាងទៀត ករណីដែលអាជ្ញាធរបានផ្តល់សំណងដល់ប្រជាពលរដ្ឋរួចហើយក៏ពិតមែន ប៉ុន្តែសំណងនោះមិនអាចបំពេញនៅតម្រូវការរស់នៅជាមូលដ្ឋាន ដល់ប្រជាពលរដ្ឋនៅខណៈពេលដែលមានការផ្លាស់ប្តូរលំនៅដ្ឋានទៅរស់នៅតំបន់មួយផ្សេង ក្រៅពីតំបន់ដែលកំពុងអនុវត្តគម្រោងអស្សាមិករណ៍នេះ។ ជាក់ស្តែង ទំបន់វារីអគ្គិសនីសេសានក្រោម២ ដែលត្រូវបានស្នើឡើងសម្រាប់ការសាងសង់លើទន្លេសេសានចម្ងាយប្រហែល ២៥ គីឡូម៉ែត្រខ្សែទឹកខាងលើពីទីរួមខេត្តស្ទឹងត្រែង និង ប្រហែល ១.៥ គីឡូម៉ែត្រខ្សែទឹកខាងក្រោមនៃកន្លែងជួបប្រសព្វនៃទន្លេសេសាន និងទន្លេស្រែពក។ ទន្លេទាំងពីរនេះ មានប្រភពនៅក្នុងតំបន់ខ្ពង់រាបកណ្តាលនៃប្រទេសវៀតណាម និងហូរកាត់ខេត្តស្ទឹងត្រែង និងខេត្តរតនគីរី (និង ខេត្តមណ្ឌលគីរី) នៅភាគឦសាននៃប្រទេសកម្ពុជា ដែលធ្វើឲ្យការអភិវឌ្ឍវារីអគ្គិសនីនៅលើដៃទន្លេមេគង្គ ទាំងពីរនេះក្លាយជាការបារម្ភមួយដែលមានលក្ខណៈអន្តរជាតិ និងឆ្លងដែន។ ក្នុងនោះប្រសិនបើមានការសាងសង់ហើយ ទំបន់វារីអគ្គិសនីសេសេនក្រោម២ នឹងជន់លិចបូរណភាពកម្ពុជាទំហំ ៣៣៥ គីឡូម៉ែត្រការ៉េ និងធ្វើឲ្យប្រជាជនចំនួន ១.០០០ គ្រួសារ ឬ ៥.០០០ នាក់ និងភូមិរាប់សិបនៅតាមដងទន្លេទាំងនេះ ដែលនៅលើខ្សែទឹកខាងលើ និងនៅខ្សែទឹកខាងក្រោម ត្រូវរើផ្លាស់លំនៅដ្ឋាន។ ការផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ក្រោមហេតុផលនៃការដកហូតដីសម្រាប់ធ្វើគម្រោងអស្សាមិករណ៍នៅទំបន់វារីអគ្គិសនីសេសេនក្រោម២ បានអនុវត្តគោលការណ៍សំណងសមរម្យ និងយុត្តិធម៌តាមរយៈការប្រើសំណងជាសិទ្ធិជំនួស ជាជាងតាមរយៈការប្រើសំណងដោយសាច់ប្រាក់។ ប៉ុន្តែក្រោយពីមានការផ្លាស់ប្តូរទីតាំងសម្រាប់ប្រជាពលរដ្ឋ ដែលជាអ្នករងផលប៉ះពាល់ដោយសារការអនុវត្តគម្រោង

អស្សាមិករណ៍នៃទំនប់វារីអគ្គិសនីសេសានក្រោម២ នេះរួចមមកមានប្រជាជនជាច្រើនបានចាប់ផ្តើមលើកឡើងនូវបញ្ហាប្រឈមនានារបស់ខ្លួនព្រោះតែការផ្លាស់ប្តូរទីលំនៅនេះ។ ពីព្រោះនៅក្នុងគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ បានប្រើប្រាស់ដីក្នុងការដោះដូរ ទៅលើដីដែលត្រូវដកហូតពីប្រជាពលរដ្ឋដែលជាម្ចាស់កម្មសិទ្ធិស្របច្បាប់ ប៉ុន្តែដីដែលប្រើប្រាស់សម្រាប់ការដោះដូរ ជាប្រភេទដីដែលមានទីតាំងមិនសូវអំណោយផលក្នុងការតាំងទីសម្រាប់ការរស់នៅទេ។ ក្នុងនោះយោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងសេសានក្រោម២ បានលើកឡើងពីការប៉ាន់ប្រមាណថា មានប្រជាជនប្រមាណជា ៣០.០០០ នាក់ដែលរស់នៅតាមខ្សែទឹកខាងក្រោម នឹងរងផលប៉ះពាល់ជាអវិជ្ជមានដោយសារការសាងសង់ និងប្រតិបត្តិការនៃគម្រោងសេសានក្រោម២ និងនៅមានប្រជាពលរដ្ឋរាប់សិបនាក់ទៀតដែលរងផលប៉ះពាល់។ មិនតែប៉ុណ្ណោះ ពេលអនុវត្តគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នេះ ម្ចាស់គម្រោងមិនបានបង្ហាញពីភស្តុតាងណាមួយក្នុងការគិតគូរបូកបញ្ចូលបញ្ហាសុខភាព ជីវភាព ទ្រព្យសម្បត្តិ និងអនាគតសេដ្ឋកិច្ចរបស់ប្រជាជនរាប់សិបនាក់ដែលជាប្រជាពលរដ្ឋដែលត្រូវផ្លាស់ប្តូរលំនៅដ្ឋាននោះទេ[46]។

ទីពីរ *ភាពមិនទាន់យល់ច្បាស់ ឬស៊ីជម្រៅថាអ្វីជាការធ្វើអស្សាមិករណ៍ពីសំណាក់ប្រជាពលរដ្ឋ* ។ បញ្ហានេះតែងតែកើតមានឡើងជានិច្ចរាល់ពេលធ្វើអស្សាមិករណ៍ ព្រោះប្រជាពលរដ្ឋយល់ពួកគាត់ជាម្ចាស់ស្របច្បាប់លើអចលនវត្ថុដែលពួកគាត់កំពុងតែអាស្រ័យនៅ ដូចនេះគ្មានហេតុផលណាមួយដែលរដ្ឋត្រូវមកធ្វើការដកហូតភាពជាម្ចាស់កម្មសិទ្ធិរបស់គាត់ ឲ្យក្លាយទៅជាកម្មសិទ្ធិរបស់រដ្ឋក្រោមរូបភាពនៃការអភិវឌ្ឍបានទេ។

ទីបី *ការបដិសេធមិនព្រមទទួលសំណង និង/ឬ មិនព្រមឲ្យមានការដកហូតពីសំណាក់អាជ្ញាធរ*។ បញ្ហាប្រឈមប្រភេទនេះ ឃើញថាមានការកើតឡើងជាញឹកញាប់ខ្លាំងជាងគេ ពេលមានការធ្វើអស្សាមិករណ៍ ដែរប្រភពឬសគល់នៃបញ្ហាអាចកើតមានក្នុងរូបភាពផ្សេងគ្នាជាច្រើន។ នៅក្នុងនោះមានដូចជា ការចុះបញ្ជី និងមានប័ណ្ណកម្មសិទ្ធិ ការមកតាំងទីលំនៅដោយអនាធិបតេយ្យរយៈពេលយូរជាដើម។ ដើម្បីងាយយល់ ខ្ញុំសូមធ្វើការបកស្រាយបន្ថែមដូចខាងក្រោម៖

**ការចុះបញ្ជី និងមានប័ណ្ណកម្មសិទ្ធិ ៖** សិទ្ធិនៃកម្មសិទ្ធិឯកជនត្រូវបានបង្កើតឡើងជាផ្លូវការនៅក្នុងរដ្ឋធម្មនុញ្ញ ១៩៩៣ ប៉ុន្តែក្របខណ្ឌគតិយុត្តដែលគ្របដណ្តប់លើសិទ្ធិទាំងនោះមិនត្រូវបានបង្កើតឡើងនោះទេ រហូតដល់ការអនុម័តឆ្នាំភូមិបាលឆ្នាំ ២០០១។ ក្នុងគោលបំណង ចុះបញ្ជីដីធ្លីទាំងអស់ជាប្លង់រឹងដែលមានការទទួលស្គាល់ថ្នាក់ជាតិ។ ជាលទ្ធផល កម្ពុជាមានប្រព័ន្ធកម្មសិទ្ធិដីធ្លីពីរគឺ ប្លង់រឹង និងប្លង់ទន់។ ការមានប្លង់រឹង ជាវិធីសាស្រ្តតែមួយគត់ដែលម្ចាស់ដីអាចទទួលបានសិទ្ធិស្របច្បាប់ ជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ចំណែកឯការមានប្លង់

[46] សៀវភៅ "ការពិនិត្យលើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននៃគម្រោងវារីអគ្គិសនីសេសានក្រោម២"

ទន់ គឺមិនមានការផ្តល់សិទ្ធិស្របច្បាប់លើសិទ្ធិជាកម្មសិទ្ធិលើអចលនវត្ថុឡើយ។ នៅក្នុងនោះច្បាប់ក៏មានបញ្ជាក់ផងដែរថា ភោគៈស្របច្បាប់ គឺគ្រាន់តែជាសិទ្ធិបណ្តោះអាសន្ន ដែលភោគីមានសិទ្ធិស្រដៀងគ្នានឹងម្ចាស់កម្មសិទ្ធិករដែរ។ លើសពីនេះផងដែរ ដីដែលមានប្លង់រឹង ត្រូវមានការចុះបញ្ជី និងមានការចេញជាប័ណ្ណកម្មសិទ្ធិតាមរយៈកម្មវិធីចុះបញ្ជីដីមួយនៅថ្នាក់ជាតិ និងតាមរយៈយន្តការចុះបញ្ជីដីមួយក្នុងចំណោមយន្តការបីផ្សេងទៀត។ ការចុះបញ្ជី និងការមានប័ណ្ណកម្មសិទ្ធិ ជាការទទួលស្គាល់មួយជាផ្លូវការលើកម្មសិទ្ធិ ដែលវាជាប្រកាសសំខាន់មួយ ព្រោះវាអាចកាត់បន្ថយហានិភ័យជម្លោះដីធ្លី និងការពារម្ចាស់ដីពីការបាត់បង់អចលនវត្ថុរបស់ខ្លួន ហើយឯកសារនៃការចុះបញ្ជី និងមានប័ណ្ណកម្មសិទ្ធិនេះផងដែរ គឺអាចយកទៅប្រើប្រាស់នៅក្នុងតុលាការពេលមានជម្លោះណាមួយកើតឡើង។ លើសពីនេះ ពេលមានការដកហូតដីសម្រាប់គម្រោងអស្សាមិករណ៍ នឹងអាចមានសិទ្ធិក្នុងការទទួលបានសំណងសមរម្យ និងយុត្តិធម៌បាន។ ពីព្រោះការធ្វើអស្សាមិករណ៍ គឺនឹងធ្វើការដកហូតដីពីម្ចាស់អចលនវត្ថុស្របច្បាប់ សម្រាប់ធ្វើការអភិវឌ្ឍនានាតាមគម្រោងដែលបានកំណត់ ក្នុងគោលបំណងបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ។ គម្រោងអស្សាមិករណ៍នេះផងដែរ នឹងផ្តល់សំណងតែទៅដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិណាដែលមានការចុះបញ្ជីដី និងមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ប៉ុណ្ណោះ។

**ការតាំងទីលំនៅដោយអនាធិបតេយ្យក្នុងរយៈពេលយូរ ៖** ការមិនមានប័ណ្ណកម្មសិទ្ធិស្របច្បាប់ និងមិនមានការទីលំនៅច្បាស់លាស់របស់ប្រជាជន រហូតក្លាយជាជនដែលធ្វើការបំលាស់ទីក្នុងការស្វែងរកទីតាំងសម្រាប់តាំងទីលំនៅនោះ បានក្លាយជាបញ្ហាស្មុគស្មាញមួយនៅក្នុងសង្គមកម្ពុជាពេលដែលមានគម្រោងនៃការអភិវឌ្ឍ។ ក្នុងនោះឬសគល់នៃការកើតមានបែបនេះ ពីព្រោះពេលមានប្រជាពលរដ្ឋដែលបានមកតាំងទីនៅលើដីណាមួយដោយមិនមែនជាកម្មសិទ្ធិស្របច្បាប់របស់ខ្លួន រួមជាមួយភាពការមិនបានហាមឃាត់របស់អាជ្ញាធរផង ការតាំងទីនេះនឹងមានភាពអូសបន្លាយកាន់តែយូរ រហូតក្លាយជាមានការតាំងទីលំនោះដោយខុសច្បាប់ ។ នៅពេលដែលមានការបណ្តេញចេញដោយបង្ខំ ជម្លោះនឹងកើតមានរវាងប្រជាពលរដ្ឋ និងអាជ្ញាធរ ព្រមទាំងធ្វើការតវ៉ាមិនព្រមចាកចេញពីតំបន់នោះ ដោយលើកឡើងនូវហេតុផលសំអាងថានៅពេលមកតាំងទី មិនមានអាជ្ញាធរមកធ្វើការហាមឃាត់មិនឲ្យមានការសាងសង់ឡើយ ។ តាមរយៈការអនុវត្តជាក់ស្តែងកន្លងមក រាជរដ្ឋាភិបាលបានព្យាយាមដោះស្រាយបញ្ហាបែបនេះ តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ច ដល់ប្រជាពលរដ្ឋជាថ្នូរនឹងការទូទាត់នូវសំណងនៃកាចាកចេញ។ ជាក់ស្តែង នៅក្នុងករណីដ៏ល្បីរន្ទឺមួយក្នុងរាជធានីភ្នំពេញនៃការបណ្តេញប្រជាពលរដ្ឋចេញពីលំនៅឋានដើម្បីធ្វើការអភិវឌ្ឍតំបន់នោះ គឺករណីបុរីកីឡា។ ក្នុងនោះកាលពីដំបូងឡើយ បុរីកីឡាមានផ្ទៃដីសរុប ១៤.១២ ហិចតា ដោយមានប្រជាជនសរុបចំនួន ១.៧៧៦គ្រួសារ ដែលបានតាំងទីលំនៅនៅទីនោះ។ នៅក្នុងឆ្នាំ ២០០៣ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់ដីសម្បទានសង្គមកិច្ចទំហំ ៤.៦ ហិចតា ទៅ

ក្រុមហ៊ុន *ផានអ៊ីមិច* ។ ក្រោមកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុន *ផានអ៊ីមិច* បានសន្យាសាងសង់អាគារចំនួនដប់លើទំហំផ្ទៃដីចំនួនពីរហិចតាឲ្យអ្នកភូមិបុរីកីឡា និងជាការផ្លាស់ដើម្បីទទួលបានសិទ្ធិអភិវឌ្ឍន៍លើទំហំដីដែលនៅសល់ចំនួន ២.៣ ហិចតា។ បន្ទាប់ពីបានសាងសង់អគារត្រឹមតែចំនួន ៨ ក្នុងចំណោមអគារចំនួន ១០ ក្រុមហ៊ុន *ផានអ៊ីមិច* ស្រាប់តែធ្វើការស្នើសុំរាជរដ្ឋាភិបាលក្នុងការសាងសង់អគារពីរបន្ថែមសម្រាប់អ្នកភូមិនោះ ទុកជារបស់ក្រុមហ៊ុនផ្ទាល់ទៅវិញ ដោយអះអាងថាខ្វះថវិការ ហើយទុកឲ្យប្រជាពលរដ្ឋចន្លោះពី ៣០០ ទៅ ៤០០ គ្រួសារឲ្យគ្មានលំនៅឋានអចិន្ត្រៃយ៍។ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ មានប្រជាពលរដ្ឋចំនួន ៣០០ គ្រួសារបានបន្តរស់នៅក្នុងបុរីកីឡា ក៏ត្រូវបានអាជ្ញាធរបណ្តេញចេញដោយហិង្សាពីលំនៅឋានរបស់ខ្លួន។ ដោយកម្មករសំណង់បានធ្វើការបំផ្លិចបំផ្លាញលំនៅដ្ឋានរបស់ពួកគាត់ អមដោយកម្លាំងសន្តិសុខបានប្រើគ្រាប់ជ័រ និងឧស្ម័នបង្ហូរទឹកភ្នែកប្រឆាំងអ្នកភូមិ ដោយមានមនុស្សជាង ៦៤ នាក់បានរងរបួស ហើយមនុស្សចំនួន ៨ នាក់ត្រូវបានអាជ្ញាធរចាប់ខ្លួនក្នុងអំឡុងពេលនៃការបណ្តេញចេញនោះ។ បន្ថែមពីករណីបុរីកីឡា ក៏នៅមានករណីជាងច្រើនទៀតដែលត្រូវបណ្តាអង្គការជាតិ និង/ឬ អង្គការអន្តរជាតិដែលកំពុងធ្វើការលើការលើកកម្ពស់សិទ្ធិមនុស្ស បានព្យាយាមធ្វើឲ្យមានភាពប្រសើរឡើងទាក់ទងនឹងការបណ្តេញចេញដោយបង្ខំនេះ។ ជាក់ស្តែង សកម្មជនដីធ្លីដែលបានជំទាស់នឹងការបណ្តេញចេញដោយបង្ខំ និងការការពារសិទ្ធិរបស់ខ្លួនជានិច្ចជាកាលត្រូវបានទទួលរងការយាយី និងមានការចាប់ពន្ធធានាជាច្រើននាក់ដោយឈរលើបទចោទប្រកាន់ផ្សេងៗគ្នា។ តាមរយៈរបាយការណ៍ដែលចេញផ្សាយនៅឆ្នាំ ២០១២ ដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) បានអះអាងថាឆ្នាំ ២០១២ គឺជាឆ្នាំដែលមានការប្រើប្រាស់កម្លាំងដែលបង្កឲ្យមានគ្រោះថ្នាក់លើអាយុជីវិតសកម្មជន ព្រោះតែសកម្មជនទាំងនោះបានធ្វើការតវ៉ាទាក់ទងនឹងករណីនៃការបណ្តេញចេញនៅបុរីកីឡា កាលពីខែតុលា ឆ្នាំ២០១៣ នគរបាលបានប្រើដំបង ហើយបានវាយអ្នកតវ៉ាដែលជាអ្នកស្នើសុំឲ្យរដ្ឋបានរាជធានីភ្នំពេញ គោរពតាមការសន្យាក្នុងការដោះស្រាយជំនាស់ដីធ្លីរបស់ប្រជាពលរដ្ឋក្នុងតំបន់នៃបុរីកីឡា[47]។

**៣.១.២ បញ្ហារវាងរដ្ឋ និងទ្រព្យសម្បត្តិរបស់រដ្ឋ**

ដូចមានចែងនៅក្នុងមាត្រា ៧ នៃច្បាប់ស្តីពីសអស្សាមិករណ៍ ឆ្នាំ២០១០ បានចែងថា មានតែរដ្ឋទេ គឺជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅនៃការបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ ដោយការធ្វើអស្សាមិករណ៍អាចសម្រេចទៅបាន លុះត្រាបានយកទៅអនុវត្តន៍គម្រោងដូចមានចែងនៅក្នុងមាត្រា ៥ នៃច្បាប់នេះ។ នៅពេលដែលមានការដកហូតទ្រព្យសម្បត្តិសម្រាប់ធ្វើការអភិវឌ្ឍ ដោយមិនមានការកំណត់គម្រោងច្បាស់លាស់ ឬការមិនបានអនុវត្តឲ្យបានត្រឹមត្រូវដូចការដែលមានចែងនៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍នោះទេ ពេលនោះម្ចាស់គម្រោងនៃអស្សាមិករណ៍អាចបង្កឲ្យមានបញ្ហា ព្រោះតែការមិនអាចអនុវត្ត

[47] កំណត់ត្រារបស់ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាស្តីពី "កំណែទម្រង់ដីធ្លី" ឆ្នាំ២០១៤

ន៍តាមការស្នើសុំទៅរដ្ឋាភិបាល ឬខុសពីគម្រោងនោះ។ នេះជាបញ្ហាមួយធំដែលរាជរដ្ឋាភិបាលព្យាយាមបញ្ចៀសនូវបញ្ហា ព្រោះវាធើឲ្យមានការបាត់បង់ទំនុកចិត្តពីបណ្ដាសហគមន៍អន្តរ និងអាចឈានទៅដល់ការផ្ដាច់ជំនួយ ដើម្បីអនុវត្តន៍គម្រោងអស្សាមិករណ៍នេះ។ ក្នុងករណីប្រសិនបើមាន ការបញ្ចប់នូវការផ្តល់ជំនួយក្នុងការធ្វើអស្សាមិករណ៍ នេះនឹងក្លាយជាបញ្ហាមួយក្នុងការបង្កឲ្យមានភាពយឺតយ៉ាវក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិ។ បញ្ហានៃការអនុវត្តខុសពីគម្រោងដែលបានគ្រោងទុកមិនសូវមានការជួនប្រទះច្រើន ដូចករណីដែលមាននៅក្នុងបញ្ហារវាងរដ្ឋ និងប្រជាពលរដ្ឋនោះទេ។

## ៣.២ ការដោះស្រាយវិវាទអស្សាមិករណ៍

ដូចដែលបានចែងនៅក្នុងច្បាប់ស្តីពីការធ្វើអស្សាមិករណ៍ ឆ្នាំ២០១០ ក្រោយពីមានផ្តល់សំណងទៅដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អ្នកដែលមិនសុខចិត្តនឹងសំណងនោះអាចតវ៉ា ឬ ធ្វើការប្តឹងទាមទារសំណងបាន។ ការទាមទារសំណងអាចធ្វើបាន តាមរយៈយន្តការពីរប្រភេទ ដែលបានកំណត់នៅក្នុងច្បាប់ស្តីពីអស្សាមិករណ៍ ដែលអាជ្ញាធរមានសមត្ថកិច្ច។ តាមការអនុវត្តកន្លងមក មុនពេលដែលមិនទាន់មានការបង្កើតច្បាប់អស្សាមិករណ៍នេះ អាជ្ញាធរដែលមានសមត្ថកិច្ចឈ្មោះថា គណៈកម្មាធិការដោះស្រាយផលប៉ះពាល់ ដែលកាលនោះគណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយអនុក្រឹត្យដោយឡែកមួយ ដែលមានភារៈកិច្ចក្នុងការដោះស្រាយចំពោះបណ្តឹងតវ៉ាចំពោះសំណង ដែលគណៈកម្មាធិការបានផ្តល់ឲ្យ និងមានតួនាទីជាអ្នកសម្របសម្រួលចំពោះការផ្តល់សំណង និងការចេញសំណង។ រហូតបច្ចុប្បន្ន ពេលមានការបង្កើតនូវច្បាប់អស្សាមិករណ៍មក ការដោះស្រាយបណ្តឹងដែលកើតឡើងពេលធ្វើអស្សាមិរកណ៍ ត្រូវបានផ្ទេរទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ ចំពោះដំណើរការបណ្តឹង ដំបូងម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្តឹងទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា[48]។ ករណីគ្មានការដោះស្រាយប្រកបដោយការពេញចិត្តពីប្រជាពលរដ្ឋ ឬ អ្នកខូចប្រយោជន៍ទេនោះ អ្នកតវ៉ាអាចដាក់ពាក្យបណ្តឹងទៅកាន់គណៈកម្មាធិការអាចដោះស្រាយបណ្តឹងតវ៉ា។ បន្ទាប់មក គណៈកម្មាធិការអស្សាមិករណ៍ និងគណៈកម្មាធិការបណ្តឹងតវ៉ាមានសមត្ថកិច្ចពិនិត្យ និងដោះស្រាយបណ្តឹងតវ៉ា[49]។ ក្រោយពីគណៈកម្មាធិការបានពិនិត្យលើបណ្តឹង និងធ្វើការដោះស្រាយហើយ ប៉ុន្តែម្ចាស់អលចនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនមានការយល់ព្រមចំពោះសេចក្តីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចធ្វើការប្តឹងបន្តទៅតុលាការមានសមត្ថកិច្ចបាន។

[48] មាត្រា៣៣ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

[49] មាត្រា៣២ នៃច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

ចំណែកពាក់ព័ន្ធនឹងសិទ្ធិ ឬផលប្រយោជន៍នានាដែលមាននៅលើដី ឬទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ពិសេសដែលកើតចេញពីការគណនាសំណង ដោយផ្អែកលើទ្រព្យដែលរងផលប៉ះពាល់នោះ ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ នឹងត្រូវបានផ្តល់ឱកាសក្នុងការជម្រាបអំពីការទាមទាររបស់ខ្លួន ទៅក្រុមអ្នកស៊ើបអង្កេតសាធារណៈ ដែលជាក្រុមមួយត្រូវបានចាត់តាំងឡើងដោយគណៈកម្មាធិការអស្សាមិករណ៍។

### ៣.២.១ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

Alternative Dispute Resolution ឬ ADR មានន័យថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ វាសំដៅដល់វិធីផ្សេងៗដែលភាគីដែលមានវិវាទនឹងគ្នា អាចដោះស្រាយវិវាទក្រៅអំពីប្រព័ន្ធជំនុំជម្រះដែលមានតាំងពីមុនមក ដែលមានការពឹងផ្អែកទាំងស្រុងលើតុលាការ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំទៅដោយទម្រង់ជាច្រើន នៃនីតិវិធីដោះស្រាយវិវាទ ដែលមួយចំនួនមានលក្ខណៈសាមញ្ញ និងខ្លះទៀតមានលក្ខណៈថ្មីប្លែក[50]។ ដូចគ្នានេះដែល វិវាទដែលកើតមានាឡើងនៅក្នុងការធ្វើអស្សាមិករណ៍ ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានគេយកមកអនុវត្ត មុននឹងឈានទៅដល់ការអនុវត្តការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ ដោយការដាក់ពាក្យបណ្តឹងត្រូវធ្វើឡើង ដោយអ្នករងផលប៉ះពាល់ផ្ទាល់។ អ្នកទទួលរងផលប៉ះពាល់នេះ គឺជាអ្នកមិនសុខចិត្តនឹងសំណង ដែលបានផ្តល់ឲ្យទើបមានសិទ្ធិធ្វើបណ្តឹងមកបាន។ ការដាក់បណ្តឹងនេះផងដែរ ហាមដាច់ខាតចំពោះជនទុច្ចរឹតដែលមានគំនិត ក្នុងការរារាំងការធ្វើគម្រោងអស្សាមិករណ៍។

នៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងការធ្វើអស្សាមិករណ៍នេះ ត្រូវចែកជាពីរដំណាក់កាល គឺ ការទទួលពាក្យបណ្តឹង និងការដោះស្រាយរបស់អាជ្ញាធរដោះស្រាយបណ្តឹង។

**ការទទួលពាក្យបណ្តឹង៖** ដោយជាធម្មតា វិវាទដែលមានក្នុងអស្សាមិករណ៍ជាវិវាទដែលកើតដោយការមិនសុខចិត្តនឹងសំណងដែលរដ្ឋបានផ្តល់ជូន ដូចនេះការទទួលពាក្យបណ្តឹងកន្លែងនេះចង់សំដៅដល់ ការទទួលពាក្យបណ្តឹងទាមទារសំណង។ ជាធម្មតា ការទទួលពាក្យបណ្តឹងទាមទារសំណង ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចធ្វើការប្តឹងផ្ទាល់ទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដោយមិនចាំបាច់មានការប្តឹងតវ៉ាទៅគណៈកម្មាធិការអស្សាមិករណ៍មុនក៏បាន។ ពីព្រោះ ទោះបីជាច្បាប់ស្តីពីអស្សាមិករណ៍ មិនបានបែងចែកនូវឋានានុក្រមនៃក្រុមគណៈកម្មាធិការដែលមាននៅក្នុងច្បាប់ក៏ដោយ ប៉ុន្តែបើពិនិត្យទៅលើការអនុវត្តជាក់ស្តែងកន្លែងមកឃើញថា គណៈកម្មាធិការអស្សាមិករណ៍មានឋានានុក្រមទាបជាងគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។

[50] សៀវភៅ "ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា: ទស្សនៈទានសំខាន់ៗ" រៀបរៀងដោយមេធាវី ស៊ីវិន អ៊ែល អូស្ទើរមីឡឺរ៍ បោះពុម្ពនៅខែមករា ឆ្នាំ២០១០ ទំព័រ១

**អាជ្ញាធរដោះស្រាយបណ្តឹងទាមទារសំណង ៖** អាជ្ញាធរមានសមត្ថកិច្ច គឺជាអាជ្ញាធរដែលមានការកំណត់ទុកមុនដោយរដ្ឋ។ អាជ្ញាធរនេះមានសមត្ថកិច្ច ដោះស្រាយតែរឿងអស្សាមិករណ៍ប៉ុណ្ណោះ មិនអាចក្លាយជាអ្នកដកហូត ហើយធ្វើជាអ្នកចេញសងបានទេ។ អាជ្ញាធរនេះ ត្រូវបានបង្កើតឡើងដោយគណៈកម្មាធិការផលប៉ះពាល់ ដែលបច្ចុប្បន្នហៅថាគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា។ នៅក្នុងបណ្តឹងទាមទារសំណងនេះ ប្រសិនបើការទាមទាររបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនបានកត់ត្រាបានត្រឹមត្រូវ និងមានភាពខ្វះខាតក្នុងកំណត់ត្រាអង្កេតនោះ អ្នកដែលមានសិទ្ធិក្នុងការទាមទារ គួរតែគិតអំពីមធ្យោបាយច្បាស់លាស់ក្នុងការនាំបញ្ហាទៅជម្រាបជូន គណៈកម្មាធិការអស្សាមិករណ៍។ ប្រសិនបើ នៅក្នុងរយៈពេលសមរម្យមួយហើយ តែនៅតែមិនទាន់ទទួលបានការឆ្លើយតប ឬសេចក្តីសម្រេចគួរទទួលយកបានណាមួយ ពីខាងគណៈកម្មាធិការអស្សាមិករណ៍ទេនោះ ជនដាក់ពាក្យបណ្តឹងអាចធ្វើការប្តឹងបន្តទៅកាន់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ក្នុងអំឡុងពេលដែលច្បាប់បានកំណត់។ ចំពោះនីតិវិធីនៃការប្តឹងនេះគឺ បន្ទាប់ពីទទួលបានសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលមិនយល់ស្របនឹងគម្រោងអស្សាមិករណ៍ អាចធ្វើពាក្យបណ្តឹងស្នើសុំឲ្យមានការអង្កេត ដោយក្នុងនោះបណ្តឹងនេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីបញ្ជាក់ឲ្យមានភាពច្បាស់លាស់នៅក្នុងបណ្តឹងនេះ។ ការអង្កេតនេះ ត្រូវធ្វើឡើងនៅក្នុងរយៈពេល ៣០ ថ្ងៃ។ ក្រោយពីបានធ្វើការអង្កេតចប់ជាស្ថាពរ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍មួយដែលមានការលើកឡើងនូវអនុសាសន៍ និងសុំការសម្រេចពីរាជរដ្ឋាភិបាល។ ឈរលើការសម្រេចរបស់រដ្ឋាភិបាល គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាត្រូវចេញនូវសេចក្តីប្រកាសរបស់ខ្លួន ចំពោះបណ្តឹងរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ។ ក្នុងនោះផងដែរ សេចក្តីប្រកាសនេះត្រូវធ្វើទៅភាគីដែលជាអ្នកដាក់បណ្តឹង ដើម្បីឲ្យបានដឹងពីអត្ថន័យនៃប្រកាសនេះ។

### ៣.២.២ ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ

បន្ទាប់ពីបានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមក ចំពោះអ្នកដែលទទួលសំណងនៅតែមិនសុខចិត្តចំពោះសេចក្តីសម្រេច ដែលធ្វើឡើងដោយគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា គឺអាចមានសិទ្ធិក្នុងការប្តឹងមកតុលាការដែលមានសមត្ថកិច្ចបាន។ ការដាក់ពាក្យបណ្តឹងនេះ ទាមទារឲ្យអ្នកដាក់ពាក្យបណ្តឹងត្រូវដឹងពីសមត្ថកិច្ចរបស់តុលាការជាមុនសិន ថាតើតុលាការណាមានសមត្ថកិច្ចធ្វើការដោះស្រាយរឿងសំណងទាក់ទងនឹងការដកហូតអចលនវត្ថុមកធ្វើអស្សាមិករណ៍នេះ។

ការស្វែងរកតុលាការដែលមានសមត្ថកិច្ចនេះ គឺពិតជាមានសារៈសំខាន់ណាស់ក្នុងការ ការពារកុំឲ្យខាតពេលវេលា និងប្រាក់កាក់ ព្រមទាំងនាំឲ្យមានមោឃៈភាពនៃសេចក្តីសម្រេច។ តុលាការនីតិរូបដែលមានសមាសភាពសំដៅទៅដល់ តុលាការសាលាដំបូង ឧទ្ធរណ៍ កំពូល និងតុលាការរាជធានី/ខេត្ត គឺជាតុលាការដែលម្ចាស់អចលវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាចធ្វើការដាក់ពាក្យបណ្តឹងប្តឹងតវ៉ាបាន។

ម្យ៉ាងទៀត សម្រាប់ដីការសម្រេចរបស់តុលាការ គឺជាការសម្រេចបិទផ្លូវតវ៉ា ដោយមានន័យថាបណ្ដឹងរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិមិនអាចប្រព្រឹត្តនៅការដោះស្រាយក្រៅប្រព័ន្ធតុលាការបានម្ដងទៀតទេ។ ក្នុងនោះសមត្ថភាពជាភាគីក្នុងការធ្វើបណ្ដឹង ត្រូវធ្វើឡើងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ក្នុងការធ្វើបណ្ដឹង គឺបុគ្គលដែលមានសិទ្ធិ និងករណីកិច្ចតាមផ្លូវច្បាប់។ ប៉ុន្តែសម្រាប់បុគ្គលដែលជាម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដែលមានសមត្ថភាពអាចធ្វើខ្លួនឯងតាមទៅតាមបញ្ញត្តិនៃច្បាប់ អាចធ្វើការដាក់ពាក្យបណ្ដឹងដោយខ្លួនឯងទៅកាន់គណៈកម្មាធិការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយបណ្ដឹងតវ៉ាបាន។

ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចធ្វើសកម្មភាពតាមអ្នកតំណាងដោយអាណត្តិរបស់ខ្លួន ដែលត្រូវបានជ្រើសរើស។ ក្នុងនោះអ្នកតំណាងដោយអាណត្តិ ចាំបាច់ត្រូវមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ដើម្បីធ្វើសកម្មភាពបណ្ដឹង ហើយសកម្មភាពណាមួយដែលអ្នកតំណាងដោយអាណត្តិបានធ្វើដោយមិនមានការយល់ស្របពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ គឺសកម្មភាពទាំងនោះនឹងមិនមានអនុភាពឡើយ។ ដូចនេះ អ្នកតំណាងអាណត្តិត្រូវតែមានសិទ្ធិពិសេសពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិពិសេសក្នុងការធ្វើសកម្មភាពដូចជា ការប្ដឹង ការដាក់ពាក្យបណ្ដឹង ការផ្សះផ្សារ ការលះបង់ការទាមទារ ឬការទទួលស្គាល់នូវការទាមទារ ហើយរាល់សកម្មភាពរបស់អ្នកតំណាងដោយអាណត្តិ ត្រូវចាត់ទុកជាសកម្មភាពរបស់គូភាគី។

បន្ថែមពីនោះ ក្នុងលិខិតនៃពាក្យបណ្ដឹងត្រូវសរសេរបញ្ជាក់អំពី ឈ្មោះរបស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន លេខទូរស័ព្ទ និងមូលហេតុនៃការដាក់ពាក្យបណ្ដឹង ដោយមានបន្ថែមការរៀបរាប់ពីលក្ខណៈស្របច្បាប់នៃដីនោះ ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិនៅលើដីដែលបានដកហូតនេះនៅក្នុងពាក្យបណ្ដឹងដែលភាគីបានប្ដឹង។ មិនតែប៉ុណ្ណោះ ត្រូវសរសេរបញ្ជាក់ឲ្យបានច្បាស់លាស់ និងអង្គហេតុនៃការប្ដឹងទាមទារ។

# សេចក្តីសន្និដ្ឋាន

រាល់សកម្មភាពដែលរដ្ឋបានធ្វើឡើង គឺដើម្បីជម្រុញឲ្យប្រទេសកម្ពុជាយើងមានការអភិវឌ្ឍទៅមុខ។ ដោយរាល់សកម្មភាពនៃការអភិវឌ្ឍទាំងឡាយនេះ តែងតែមានផលប៉ះពាល់ទៅដល់សិទ្ធិ និងផលប្រយោជន៍ អ្នកដែលកាន់កាប់សិទ្ធិ ឬអ្នកដែលមានសិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈរួមមាន សំណង់ ដី និងដំណាំផ្សេងៗទៀតជាដើម។ មិនតែប៉ុណ្ណោះ ដោយមើលឃើញពីផលលំបាករបស់ប្រជាជន និងដល់អាជ្ញាធរ និងក្រសួងដែលពាក់ព័ន្ធជាពិសេសរដ្ឋាភិបាល ដែលជាតួអង្គសំខាន់ក្នុងកិច្ចការអភិវឌ្ឍន៍ប្រទេសហេតុដូចនេះបានជា នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ រដ្ឋសភាបានអនុម័តច្បាប់ស្តីពី អស្សាមិករណ៍នេះឡើង និងបានប្រកាសនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១០ ដែលមានសរុបចំនួន ៨ ជំពូក និងបែងចែកជា ៣៩ មាត្រា។ ក្នុងនោះត្រូវបានបង្កើតឡើងក្នុងគោលបំណងកំណត់អំពីគោលការណ៍ យន្តការ នីតិវិធីអស្សាមិករណ៍ និងសំណងដោយសមរម្យ និងយុត្តិធម៌។

ដោយយោងតាមការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើ យើងខ្ញុំសូមធ្វើការសន្និដ្ឋានចំពោះបញ្ហាបីចំណុចដែលបានលើកឡើងនៅក្នុងចំណោទបញ្ហានៃការស្រាវជ្រាវខាងលើនេះ។ បីចំណុចនោះរួមមាន៖

ទីមួយ តើការធ្វើអស្សាមិករណ៍នៅប្រទេសកម្ពុជាមានលក្ខណៈដូចម្តេច? ទីពីរ តើមានបញ្ហាប្រឈមអ្វីខ្លះនៅក្នុងអំឡុងពេលធ្វើអស្សាមិករណ៍? ទីបី តើមានដំណោះស្រាយបែបណាខ្លះក្នុងការដោះស្រាយបញ្ហាប្រឈមដែលកើតមានទាំងនោះ?

ខាងក្រោមនេះនាងខ្ញុំ នឹងធ្វើការសន្និដ្ឋានចំពោះបញ្ហាដែលបានលើកឡើងខាងលើនេះ៖

+ទីមួយ ការធ្វើអស្សាមិករណ៍នៅប្រទេសកម្ពុជា មានដូចជា ១. បទប្បញ្ញត្តិទូទៅ ២. គោលបំណងនៃការធ្វើអស្សាមិករណ៍ ៣. អស្សាមិករណ៍ពិសេស ៤. គោលការណ៍ទូទៅនៃការធ្វើអស្សាមិករណ៍ ៥. យន្តការអស្សាមិករណ៍។

ចំពោះគោលការណ៍ទូទៅ នៅពេលដែលមានច្បាប់ស្តីពីអស្សាមិករណ៍កើតឡើងនៅឆ្នាំ២០១០ គេសង្កេតឃើញថាភាគីគោលការណ៍ទូទៅនេះត្រូវបានចចែងមុនគេបំផុតនៃច្បាប់ (មិនខុសពីស្ថានភាពច្បាប់ផ្សេងទៀតដែរ មាត្រា១ ជាមាត្រាដែលកំណត់អំពីបទប្បញ្ញត្តិទូទៅ)។ នៅក្នុងនោះ ត្រង់ចំណុចបទប្បញ្ញត្តិទូទៅនេះបាននិយាយរៀបរាប់យ៉ាងច្បាស់អំពីការកំណត់ពីគោលការណ៍ យន្តការ នីតិវិធីអស្សាមិករណ៍ និងសំណងដែលមានភាពសមរម្យ និងយុត្តិធម៌។

ចំពោះ គោលបំណងនៃការធ្វើអស្សាមិករណ៍ គឺធ្វើឡើងដើម្បីធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និងយុត្តិធម៌ ធានាការទូទាត់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ការធ្វើអស្សាមិករណ៍សម្រាប់បម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិ និងសម្រាប់ធ្វើការអភិវឌ្ឍលើហេដ្ឋារចនា

សម្ព័ន្ធរូបវន្តសាធារណៈ ។ ការធានាបែបនេះ ព្រោះទោះបីជាប្រទេសកម្ពុជាមានច្បាប់ភូមិបាលឆ្នាំ២០០១ ដែលទាក់ទងនឹងដីធ្លីយ៉ាងណាក៏ដោយ ក៏មិនបានចែងពេលមានករណីនៃការដកហូតអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិសម្រាប់មកធ្វើការអភិវឌ្ឍដែរ។

ចំពោះ អស្សាមិករណ៍ពិសេស ជាការបញ្ជាក់អំពីបុព្វសិទ្ធិរបស់រដ្ឋ ដែលអាចធ្វើអស្សាមិករណ៍បាន។ មានតែរដ្ឋប៉ុណ្ណោះ ដែលមានបុព្វសិទ្ធិបែបនេះ ព្រោះការធ្វើអស្សាមិករណ៍ទាក់ទងនឹងគម្រោងស្ថារ អភិវឌ្ឍន៍ដែលមានលក្ខណៈធំៗ ដែលទាក់ទងនឹងការបម្រើផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍ជាតិជាធំ។

ចំពោះគោលការណ៍ទូទៅនៃការធ្វើអស្សាមិករណ៍ គឺចង់សំដៅដល់ការដកហូតនៅកម្មសិទ្ធិឯកជនដែលមកពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ យកមកធ្វើដោយមានគោលការណ៍ដកហូតច្បាស់លាស់ ចៀសវាងការដកមកធ្វើការផ្ទេរទៅតតិយជន ឬមិនមានការអនុវត្តគម្រោងអភិវឌ្ឍន៍ណាមួយ។ មានករណីមួយចំនួនរដ្ឋអាចធ្វើការដកហូត ដោយមិនចាំបាច់មានការជូនដំណឹងជាមុនដល់ម្ចាស់កម្មសិទ្ធិករឡើយ។

ចំពោះយន្តការអស្សាមិករណ៍ គឺត្រូវអនុវត្តដោយមានការបង្កើតនូវគណៈកម្មាធិការផ្សេងៗមួយចំនួនសម្រាប់ពិនិត្យ និងដោះស្រាយពេលមានគម្រោងអស្សាមិករណ៍ ។ គណៈកម្មាធិការទាំងនោះមានដូចជា គណៈកម្មាធិការអស្សាមិករណ៍ គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា។

+ទីពីរ ចំពោះនីតិវិធីនៃការធ្វើអស្សាមិករន៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានការបែងចែកជាបីដំណាក់សំខាន់ៗមានដូចជា នីតិវិធីមុនអស្សាមិករណ៍ នីតិវិធីក្នុងពេលធ្វើអស្សាមិករណ៍ និងនីតិវិធីការទូទាត់សំណងអស្សាមិករណ៍។ ដែលដំណាក់កាលនីមួយមានភាពប្រទាក់ប្រឡាគ្នា និងគម្រោងអស្សាមិករណ៍ នឹងមិនអាចសម្រេចទៅបានទេបើគ្មាននីតិវិធីទាំងបីដំណាក់កាលនេះ។

+ទីបី ការដោះស្រាយវិវាទដែលមានបញ្ហាប្រឈមពេលធ្វើអស្សាមិករណ៍៖

**ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ**

ដូចដែលបានរៀបរាប់នៅខាងលើនៅកន្លែងអត្ថបទដែរ អ្នកទទួលរងផលប៉ះពាល់នេះ គឺជាអ្នកមិនសុខចិត្តនឹងសំណង ដែលបានផ្តល់ឲ្យទើបមានសិទ្ធិធ្វើបណ្តឹងមកបាន។ ការដាក់បណ្តឹងនេះផងដែរ ហាមដាច់ខាតចំពោះជនទុច្ចរឹតដែលមានគំនិត ក្នុងការរារាំងការធ្វើគម្រោងអស្សាមិករណ៍។នៅក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងការធ្វើអស្សាមិករណ៍នេះ ត្រូវចែកជាពីរដំណាក់កាលគឺ ការទទួលពាក្យបណ្តឹង និងការដោះស្រាយរបស់អាជ្ញាធរដោះស្រាយបណ្តឹង។ ការទទួលពាក្យបណ្តឹង៖ ដោយជាធម្មតា វិវាទដែលមានក្នុងអស្សាមិករណ៍ជាវិវាទដែលកើតដោយការមិនសុខចិត្តនឹងសំណងដែលរដ្ឋបានផ្តល់ជូន ដូចនេះការទទួលពាក្យបណ្តឹងកន្លែងនេះចង់សំដៅដល់ ការទទួលពាក្យបណ្តឹងទាមទារសំណង។ ជាធម្មតា ការទទួលពាក្យបណ្តឹងទាមទារសំណងម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិអាចធ្វើការប្តឹងផ្ទាល់ទៅគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដោយមិន

ចាំបាច់មានការប្តឹងតវ៉ាទៅគណៈកម្មាធិការអស្សាមិករណ៍មុនក៏បាន។ និងដាក់ពាក្យទៅអាជ្ញាធរដោះស្រាយបណ្តឹងទាមទារ ។

**ការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ**

ចំពោះនីតិវិធីស្នើសុំដោះស្រាយទំនាស់ដីធ្លីក្រៅប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាទាក់ទងនឹងការធ្វើអស្សាមិករណ៍នេះវិញ គឺអ្នកដែលមិនសុខចិត្តនឹងការសម្រេចរបស់គណៈកម្មាធិកាដោះស្រាយបណ្តឹងតវ៉ា អាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការបាន ដោយការដាក់ពាក្យបណ្តឹងនេះត្រូវធ្វើឡើងតាមរយៈអ្នកតំណាងរបស់ខ្លួន ឬក៏អាចធ្វើដោយខ្លួនឯងក៏ប្រសិនបើម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិដែលរងប៉ះពាល់នោះមានចំណេះដឹងផ្នែកច្បាប់គ្រប់គ្រាន់។ រាល់ការសម្រេចរបស់តុលាការ ជាការសម្រេចបិទផ្លូវតវ៉ា ដែលហាមមិនឲ្យមានការដោះស្រាយក្រៅប្រព័ន្ធតុលាការម្តងទៀតឡើយ។

# អនុសាសន៍

យោងតាមការបកស្រាយទៅលើអត្ថន័យ និងខ្លឹមសារជាច្រើនរួចមក យើងអាចដឹងច្បាស់ថាការអនុវត្តច្បាប់ស្តីពីអស្សាមិករណ៍នៅប្រទេសកម្ពុជា គឺជាវិធីសាស្ត្រតែមួយគត់ដែលមិនអាចមើករំលងបានឡើយ ព្រោះរាល់កិច្ចអភិវឌ្ឍន៍ទាំងឡាយណាដែលមានការប៉ះពាល់ដល់កម្មសិទ្ធិឯកជន ចាំបាច់មានធានាច្បាស់លាស់ចៀសវាងការយល់ច្រលំពីសំណាក់ប្រជាពលរដ្ឋមកលើរដ្ឋថា ជាអ្នករំលោភសិទ្ធិមនុស្ស និងមានគោលការណ៍ច្បាស់លាស់ក្នុងការធានាការរស់នៅរបស់កម្មសិទ្ធិឯកជនប្រជាពលរដ្ឋជាដើម។

ដើម្បីជាដំណោះស្រាយ នឹងបញ្ហាដែលកើតមានឡើង នាងខ្ញុំសូមលើកឡើងនូវមតិយោបល់មួយចំនួនដូចតទៅ៖

- សូមអំពាវនាវដល់ម្ចាស់គម្រោង គួរមានការពិគ្រោះយោបល់ជាជនរងផលប៉ះពាល់មុនពេលមានការអនុវត្តនីតិវិធីដែលមាននៅក្នុងគម្រោងដោយ ធ្វើសេចក្តីអធិប្បាយសង្ខេបអំពីការប្រាស្រ័យទាក់ទងដែលបើកចំហជាសាធារណៈទូទៅ ដើម្បីប្រកាសអំពីការបើកគម្រោង និងស្នើសុំយោបល់ និងពិគ្រោះយោបល់ជាអ្នកពាក់ព័ន្ធ ពិសេសម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់កម្មសិទ្ធិ ដើម្បីពិនិត្យ និង/ពិគ្រោះយោបល់លើគម្រោងដែលមាន។
- ការទទួលខុសត្រូវខាងស្ថាប័នសម្រាប់ការផ្តល់សំណង ដោយមានការដាក់ចេញនូវថេរវេលាច្បាស់លាស់សម្រាប់ការផ្តល់សំណងជូនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និងមានការយន្តការចាត់ចែងបណ្តឹង ឬការទាមទារប្រកបដោយតម្លាភាព និងគណីយភាពក្នុងនាមជាម្ចាស់គម្រោង ដើម្បីធានាថាសិទ្ធិរបស់ប្រជាពលរដ្ឋនឹងមិនត្រូវបានរំលោភបំពាន។
- ការប្រមាណមើលទៅលើផលប៉ះពាល់ដែលអាចកើតមានឡើងនៅពេលមានការធ្វើអស្សាមិករណ៍ ដោយត្រូវបង្កើនការប៉ាន់ប្រមាណអំពីផលប៉ះពាល់ទាំងឡាយនៅពេលមុនការអនុវត្ត ក្នុងអំឡុងពេលអនុវត្តគម្រោង និងក្រោយពេលអនុវត្តគម្រោង ដោយត្រូវបូកបញ្ចូលយន្តការ កាត់បន្ថយការតាំងលំនៅដ្ឋានឡើងវិញរបស់ប្រជាពលរដ្ឋដែលមានការប៉ះពាល់ដោយសារតែគម្រោងអស្សាមិករណ៍។
- ការវាយតំលៃដីធ្លី ដោយមានការដាក់ចេញនូវតារាងបញ្ជាក់ច្បាស់លាស់ និងបើកបង្ហាញជាសាធារណៈ និងមានការផ្សព្វផ្សាយទៅដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ឲ្យបានទូលំទូលាយពេលអនុវត្តគម្រោងអស្សាមិករណ៍នេះ។

# ឯកសារយោង

- **ឯកសារជាភាសាខ្មែរ**
- **រដ្ឋធម្មនុញ្ញ**
  - រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
  - រដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧២
- **ច្បាប់ និងអនុក្រឹត្យ**
  - ច្បាប់ភូមិបាល ២០០១
  - ច្បាប់ស្តីពី "អស្សាមិករណ៍ ឆ្នាំ២០១០"
  - ច្បាប់ភូមិបាល ១៩៩២
  - ច្បាប់ភូមិបាល សន្ធានុក្រម (លទ្ធកម្មនៃកម្មសិទ្ធិ)
  - ច្បាប់ពាក់ព័ន្ធ (ព្រៃឈើ ជលផល បរិដ្ឋាន ក្រមរដ្ឋប្បវេណី...)
  - ព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០០៦ ស្តីពីបង្កើត អ.ជ.ដ
  - អនុក្រឹត លេខ ៦៥ រនក្រ.បក ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ។
  - អនុក្រឹត្យលេខ ១២២៧ អនក្រ.តត ស្តីពីការកែសម្រួលសមាសភាពរបស់ អ.ជ.ដ។
  - អនុក្រឹត្យលេខ ១១៤៦ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពរបស់ អ.ជ.ដ។
  - អនុក្រឹត្យលេខ ១១៨ អណក្រ/បកចុះថ្ងៃទី ០៧/១០/២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។
  - អនុក្រឹត្យ លេខ៤៧ អនក្រ បក ចុះថ្ងៃទី៣១-០៥-០២ ស្តីពីការ រៀបចំនិងប្រព្រឹត្តទៅរបស់គណៈកម្មការសុរិយោដី និងអនុក្រឹត្យ លេខ៣៤អនក្រ.បកចុះថ្ងៃទី២០-០៤-០៦ស្តីពីការកែសំរួលមាត្រា៥ និងមាត្រា២៨នៃអនុក្រឹត្យ៤៧ខាងលើ។
- **ប្រកាស**
  - ប្រកាសលេខ១១២ ដនស/ប្រក. ចុះថ្ងៃទី ២១-០៨-០២ស្តីពីគោលការណ៍ណែនាំ និងនីតិវិធីរបស់គណៈកម្មការសុរិយោដី។
  - ប្រកាសអន្តរក្រសួងលេខ០២ ប្រករ.០៣ រវាងក្រសួងយុត្តិធម៌ និងក្រសួង ដនស.ចុះថ្ងៃទី២៦-១១-០៣ ស្តីពីការកំណត់ភារកិច្ច របស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនិងវិវាទដីធ្លី។
  - ប្រកាសលេខ០៣២ប្រក.ដនស/ចុះថ្ងៃទី២១-០១-១០ស្តីពីការធ្វើ ប្រតិភូកម្មមុខងារជូនអភិបាលនៃ

គណៈអភិបាលរាជធានី ខេត្ត និង ជាប្រធានគណៈកម្មការសុរិយោរាជធានី ខេត្ត ដើម្បីធ្វើសេចក្តីសម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី។

- ប្រកាសរួមលេខ០៥ សណន ស្តីពីសេចក្តីណែនាំរួមរវាងក្រសួង មហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តីពីការ អនុវត្តអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី២០/០៤/២០០៦។

➢ **សៀវភៅ និងឯកសារផ្សេងៗ**

- សារណាបញ្ចប់ការសិក្សា ការធ្វើអស្សាមិករណ៍នៅព្រះរាជាណាចក្រកម្ពុជា របស់លោក អ៊ុំ ប៉ែន ពិសិដ្ឋ និងកញ្ញា រ័ត្ន បុប្ផាមុនិច ឆ្នាំ ២០១៧
- សារណាបញ្ចប់ការសិក្សា "នីតិវិធីក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ" របស់លោក ពេញ ប៊ុនថង និងកញ្ញា ប្រាក់ រតនៈវិតា ឆ្នាំ២០២០ ទំព័រ១
- របាយការណ៍របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយខែកុម្ភៈ ឆ្នាំ២០១៦ "ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាពរបស់សហគមន៍ជនជាតិដើមភាគនៅកម្ពុជា"
- កំណត់ត្រាសង្ខេបរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ចេញផ្សាយខែមីនា ឆ្នាំ២០១៤ " កំណែទម្រង់ដីធ្លី"
- សេចក្តីព្រាង "ក្របខណ្ឌគោលនយោបាយសម្រាប់ការតាំងទីលំនៅឡើងវិញ" ឆ្នាំ២០១៦
- សៀវភៅ "ការពិនិត្យលើការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាននៃគម្រោងវារីអគ្គិសនីសេសានក្រោម២"

➢ **ឯកសារជាភាសាបរទេស**

- CCHR Report Cambodia: Land in Conflict and overview of the Land Situation.

➢ **វេបសាយ និងគេហទំព័រ**

- របាយការណ៍របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា (https://opendevelopmentcambodia.net/km/topics/expropriation/)
- https://opendevelopmentcambodia.net/km/topics/elections/ ចូលមើលថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

## **មាតិកាឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១ ៖** ជំពូកទី៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

**ឧបសម្ព័ន្ធទី២ ៖** ច្បាប់ស្តីពីអស្សាមិករណ៍ ឆ្នាំ២០១០

**ឧបសម្ព័ន្ធទី៣ ៖** ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ស្តីពី គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

**ឧបសម្ព័ន្ធទី៤ ៖** អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាន

**ឧបសម្ព័ន្ធទី៥ ៖** អនុក្រឹត្យលេខ ១២៩ អនក្រ.បក ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

# ឧបសម្ព័ន្ធទី១

## ជំពូកទី ៣
## អំពី សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ

**មាត្រា ៣១.-**

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។

ប្រជាពលរដ្ឋខ្មែរ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់ ។

**មាត្រា ៣២.-**

ជនគ្រប់រូប មានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។

**មាត្រា ៣៣.-**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបានរដ្ឋគាំពារ ។

ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៤.- ថ្មី**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ ឆ្នាំ មានសិទ្ធិបោះឆ្នោត ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា ។

បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត ត្រូវចែងក្នុងច្បាប់បោះឆ្នោត ។

**មាត្រា ៣៥.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌



Downloaded from http://www.khmerlaws.com

របស់ប្រទេសជាតិ ។

សេចក្តីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋ ។

**មាត្រា ៣៦.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា ។

ការងារមេផ្ទះមានតម្លៃស្មើគ្នានឹងកំរៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។

ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់ ។

**មាត្រា ៣៧.-**

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។

**មាត្រា ៣៨.-**

ច្បាប់រ៉ាប់រង មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។

ច្បាប់ការពារជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារត្រូវហាមឃាត់មិនធ្វើឡើយ ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំ តាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធ-ភាពទេ ។

វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ។

ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។

**មាត្រា ៣៩.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុស



Downloaded from http://www.khmerlaws.com

ច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណង ជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ ។

**មាត្រា ៤០.-**

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់ របស់ប្រជាពលរដ្ឋត្រូវបានគោរព ។

ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាមទូរស័ព្ទត្រូវបានធានា ។

ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គលត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

**មាត្រា ៤១.-**

ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។

របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។

**មាត្រា ៤២.-**

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគម និងគណបក្សនយោបាយ ។ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ។

ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការមហាជនជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។

**មាត្រា ៤៣.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ ។

សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវបានរដ្ឋធានា ក្នុងលក្ខខណ្ឌដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ។

ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។

**មាត្រា ៤៤.-**

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ ។ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតនៅក្រោមការគាំពារនៃច្បាប់ ។

ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រាតែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ក្នុងករណីដែលច្បាប់បានបញ្ញត្តិទុក ហើយត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។



Downloaded from http://www.khmerlaws.com

**មាត្រា ៤៥.-**

ការរើសអើងគ្រប់ប្រភេទប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ។

ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រីត្រូវហាមឃាត់ ។

បុរស និងស្ត្រី មានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ ជាពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារ ។

អាពាហ៍ពិពាហ៍ ត្រូវធ្វើតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។

**មាត្រា ៤៦.-**

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារីត្រូវហាមឃាត់ ។

ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកនៅពេលសម្រាលកូន ដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុងការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។

រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។

**មាត្រា ៤៧.-**

មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

កូនមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ ។

**មាត្រា ៤៨.-**

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវ-កម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**មាត្រា ៤៩.-**

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ។

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ ។

កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។

**មាត្រា ៥០.-**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈ និងកម្មសិទ្ធស្របច្បាប់របស់ឯកជន ។



Downloaded from http://www.khmerlaws.com

# ឧបសម្ព័ន្ធទី ២

# ព្រះរាជក្រម

នស/រកម/០៤១០/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីអស្សាមិករណ៍ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១០ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ១០៤/០០១/២០១០ ក.ប.ធ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១០ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# អស្សាមិករណ៍

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីអស្សាមិករណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយកំណត់ពីគោលការណ៍ យន្តការ នីតិវិធីនៃអស្សាមិករណ៍ និង សំណងឱ្យបានសមរម្យ និង យុត្តិធម៌ សម្រាប់គម្រោងស្ថាបនា ស្តារ និង គម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ បម្រើឱ្យផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការអភិវឌ្ឍរបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងជាអាទិ៍ :

- ធានាការដកសិទ្ធិស្របច្បាប់លើកម្មសិទ្ធិឯកជនដោយសមរម្យ និង យុត្តិធម៌
- ធានាការទូទាត់សំណងជាមុនដោយសមរម្យ និង យុត្តិធម៌
- បម្រើផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ
- ធ្វើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះការធ្វើអស្សាមិករណ៍ដែលមានពាក់ព័ន្ធទៅនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់នេះ មិនគ្របដណ្តប់លើកិច្ចព្រមព្រៀង ឬ អនុស្សារណៈ ស្តីពីការគាំពារវិនិយោគរវាងរាជរដ្ឋាភិបាល និង ប្រទេសជាដៃគូដែលមានចែងពីអស្សាមិករណ៍ទេ ។ ក្នុងករណីដែលពុំមានកិច្ចព្រមព្រៀងនេះទេ ឬ ក្នុងករណីដែលកិច្ចព្រមព្រៀង ឬ អនុស្សារណៈពុំមានចែងពីអស្សាមិករណ៍ គឺត្រូវស្ថិតនៅក្រោមអានុភាពនៃច្បាប់នេះ ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមានដូចតទៅ :

**អស្សាមិករណ៍** សំដៅដល់ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុរបស់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន ដីសំណង់ និង ដីណាំដាំដុះសម្រាប់បម្រើការស្ថាបនា ស្តារ និង ពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈដែលបម្រើប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ព្រមទាំងផ្តល់នូវសំណងជាមុនដោយសមរម្យ និង យុត្តិធម៌ ។

**ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិ** សំដៅដល់រូបវន្តបុគ្គល នីតិបុគ្គលឯកជន និង នីតិបុគ្គលសាធារណៈ រួមមាន កម្មសិទ្ធិករ ភោគី និង អ្នកមានសិទ្ធិទាំងឡាយនៅលើទីតាំងដីដែលជាអ្នកទទួលរងនូវផលប៉ះពាល់ដោយសារគម្រោងអស្សាមិករណ៍ ។

**ផលប្រយោជន៍សាធារណៈ ឬ ទូទៅ** សំដៅដល់ការប្រើប្រាស់ដី ឬ ទ្រព្យសម្បត្តិដោយសាធារណជនទូទៅ ឬ ដោយទីភ្នាក់ងារ ឬ ស្ថាប័នរដ្ឋ ឬ សាធារណៈ ។

**តម្រូវការនៃផលប្រយោជន៍ជាតិ** សំដៅដល់សកម្មភាព ឬ គម្រោងមានជាអាទិ៍ :

- ការសាងសង់ ស្តារ ថែទាំ ឬ ពង្រីក សំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការងារសន្តិសុខ
- ការកាន់កាប់ដី ឬ ទ្រព្យសម្បត្តិ ដើម្បីអនុវត្តជាក់ស្តែងនយោបាយការពារបូរណភាពទឹកដី ។

**អ្នកអនុវត្តគម្រោង** សំដៅដល់រដ្ឋ សហគ្រាស និង គ្រឹះស្ថានសាធារណៈ អ្នកម៉ៅការ ឬ វិនិយោគិន ។

**ភតិកៈ** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលទទួលសិទ្ធិកាន់កាប់ និង សិទ្ធិប្រើប្រាស់លើអចលនវត្ថុ ពីម្ចាស់អចលនវត្ថុ ។

**បុគ្គលដែលធ្វើការរារាំង** សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលឯកជនទាំងឡាយណាដែលជាមេក្លោង អ្នកសមគំនិត អ្នកញុះញង់ ដែលធ្វើសកម្មភាពដោយផ្ទាល់ ឬ ដោយប្រយោល ដោយគំនិតទុច្ចរិតក្នុងគោលដៅធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងអស្សាមិករណ៍ ។

**មាត្រា ៥.-**

គម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ មានជាអាទិ៍ :

ក- ការសាងសង់ ឬ ពង្រីកផ្លូវអយស្ម័យយាន ផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ដោយរួមទាំងរចនាសម្ព័ន្ធ និង ឧបករណ៍ ។

ខ- ការសាងសង់ ឬ ពង្រីកស្ថានីយថាមពល រចនាសម្ព័ន្ធ ឧបករណ៍ និង ខ្សែ សម្រាប់ការបញ្ជូន និង ចែកចាយថាមពលអគ្គិសនី ។

គ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ប្រៃសណីយ៍ និង ទូរគមនាគមន៍ និង ប្រព័ន្ធព័ត៌មានវិទ្យា ។

ឃ- ការសាងសង់ ឬ ពង្រីកផ្លូវ ផ្លាក្រុង ចំណតយានយន្ត ទីផ្សារ សួនច្បារ និង ទីលានសាធារណៈ ។

ង- ការសាងសង់ ឬ ពង្រីកប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធ លូទឹកកខ្វក់ និង កន្លែងបម្រើសេវាសាធារណៈផ្សេងទៀត ។

ច- ការសាងសង់ ឬ ពង្រីកអគារ សម្រាប់អប់រំបណ្តុះបណ្តាលវិទ្យាសាស្ត្រ វប្បធម៌ ថែរក្សាសុខភាព សន្តិសុខសង្គម និង កីឡាដ្ឋានសម្រាប់សម្តែងជូនជាសាធារណៈ ។

ឆ- ការសាងសង់ ឬ ពង្រីកកន្លែងចម្រាញ់ និង កន្លែងប្រព្រឹត្តកម្ម សំណង់ ឧបករណ៍ សម្រាប់ការការពារធម្មជាតិ និង បរិស្ថាន ។

ជ- ការសាងសង់ ឬ ពង្រីកអគារ និង ឧបករណ៍សម្រាប់ស្រាវជ្រាវ និង សម្រាប់ ការធ្វើអាជីវកម្មរ៉ែ និង ធនធានធម្មជាតិផ្សេងទៀត ។

ឈ- ការសាងសង់ ឬ ពង្រីកបណ្តាញឧស្ម័ន បណ្តាញបំពង់ប្រេងឥន្ធនៈ រោងចក្រចម្រាញ់ប្រេង រោងចក្រប្តូមប្រេង និង បណ្តាញដទៃទៀត ។

ញ- ការសាងសង់ ឬ ពង្រីកអគារតាំងទីលំនៅដែលបណ្តាលមកពីការបំផ្លាញ យ៉ាងធ្ងន់ធ្ងរពីធម្មជាតិមាន រញ្ជួយផែនដី ទឹកជំនន់ អគ្គិភ័យ និង គ្រោះបាក់ដីជាដើម និង ការរៀបចំសម្រាប់ការតាំងទីលំនៅឡើងវិញ ។

ដ- ការសាងសង់ ឬ ពង្រីកអគារសម្រាប់ការការពារ និង ការគាំពារប្រជាជន ។

ឋ- ការសាងសង់ ឬ ពង្រីកទីកន្លែងឆ្លងកាត់ព្រំដែន ។

ឌ- ការកសាង ពង្រីក ឬ ការរៀបចំសំណង់ចាំបាច់ដល់កិច្ចការពារជាតិ ឬ ការរក្សាសន្តិសុខ ។

ល- ការបង្កើតឡើងថ្មីនូវតំបន់ការពារធនធានធម្មជាតិ ព្រៃឈើ បេតិកភ័ណ្ឌវប្បធម៌បុរាណវិទ្យា ឬ ការពារបរិស្ថាន ។

ឍ- ការអនុវត្តតាមតម្រូវការរបស់ជាតិ តាមការកំណត់របស់រាជរដ្ឋាភិបាល។

## ជំពូកទី ២
## គោលការណ៍ទូទៅ

**មាត្រា ៦.-**

អស្សាមិករណ៍ អាចធ្វើលើអចលនវត្ថុមួយផ្នែកឬទាំងស្រុង ឬ លើសិទ្ធិប្រត្យក្សនៃអចលនវត្ថុ ។

**មាត្រា ៧.-**

មានតែរដ្ឋទេដែលជាអ្នកធ្វើអស្សាមិករណ៍ ដើម្បីប្រើប្រាស់ក្នុងគោលដៅជាផលប្រយោជន៍សាធារណៈ និង ផលប្រយោជន៍ជាតិ ។

អស្សាមិករណ៍អាចអនុវត្តទៅបាន លុះត្រាតែយកទៅអនុវត្តគម្រោង ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

**មាត្រា ៨.-**

រដ្ឋត្រូវតែទទួលទិញយកនូវចំណែកនៃអចលនវត្ថុ ដែលនៅសេសសល់ពីអស្សាមិករណ៍ ដោយថ្លៃសមរម្យ និង យុត្តិធម៌ តាមសំណើរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលពុំអាចរស់នៅស្បែរគម្រោងបាន ឬ ពុំអាចសាងសង់លំនៅឋានបាន ឬ ពុំអាចប្រកបអាជីវកម្មអ្វីផ្សេងទៀតបាន ។

**មាត្រា ៩.-**

អចលនវត្ថុដែលត្រូវបានដកហូតនេះ ត្រូវប្រើប្រាស់សម្រាប់តែក្នុងគោលដៅដែលបានគ្រោងទុកនៅក្នុងប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដើម្បីប្រយោជន៍សាធារណៈ ឬ តម្រូវការនៃផលប្រយោជន៍ជាតិប៉ុណ្ណោះ និង មិនអាចឱ្យទុកនៅចោលទំនេរដោយគ្មានហេតុផលសមស្រប ឬ ផ្ទេរឱ្យតតិយជនណាម្នាក់ក្នុងគោលដៅបម្រើផលប្រយោជន៍ឯកជន

ROYAUME DU CAMBODGE ... ROYAL ... ចុះផ្សាយ ...

អចលនវត្ថុដែលនៅសល់ពីតម្រូវការប្រើប្រាស់ ត្រូវផ្តល់អាទិភាពលក់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ តាមអត្រាតម្លៃនៃការទូទាត់សំណង ។ ក្នុងករណីដែលម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនព្រមទទួលយកអចលនវត្ថុដែលសល់ពីតម្រូវការប្រើប្រាស់វិញទេ ត្រូវរក្សាទុកអចលនវត្ថុនោះជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

**មាត្រា ១០.-**

ក្នុងករណីពិសេស និង បន្ទាន់ ដែលសុវត្ថិភាពសាធារណៈតម្រូវ ដូចជា ប្រយុទ្ធប្រឆាំងគ្រោះអគ្គិភ័យ ទឹកជំនន់ ភ្លើងឆេះព្រៃ រញ្ជួយដី សង្គ្រាមដែលប្រុងនឹងកើតឡើង ឬ ការវាយប្រហារដោយភេរវកម្ម និង ស្ថានភាពផ្សេងៗទៀតដែលកំណត់ដោយរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលអាចធ្វើការដកហូតអចលនវត្ថុ ឬ សិទ្ធិប្រត្យក្សលើអចលនវត្ថុជាបណ្តោះអាសន្នដោយមិនចាំបាច់ធ្វើការពិគ្រោះយោបល់ឡើយ ហើយត្រូវប្រគល់ជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិវិញនៅពេលចប់ការដកហូតនេះ ។

ក្នុងករណីបន្ទាន់ និង ចាំបាច់ដែលផលប្រយោជន៍ជាតិតម្រូវ រាជរដ្ឋាភិបាលមានអំណាចឆន្ទានុសិទ្ធិក្នុងការធ្វើអស្សាមិករណ៍ ដោយមិនចាំបាច់រៀបចំធ្វើការពិគ្រោះយោបល់តាមនីតិវិធី ដូចមានចែងក្នុងជំពូកទី ៤ នៃច្បាប់នេះទេ ។

**មាត្រា ១១.-**

មុននឹងដំណើរការការងារអស្សាមិករណ៍ រាជរដ្ឋាភិបាលត្រូវគ្រោងថវិកាប្រចាំឆ្នាំឱ្យបានគ្រប់គ្រាន់ ហើយត្រូវផ្តល់ឥណទានឱ្យគ្រប់ចំនួន និង ទាន់ពេលវេលាជូនគណៈកម្មាធិការអស្សាមិករណ៍ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់យកទៅទូទាត់សំណងជូនម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលរងនូវផលប៉ះពាល់ដោយសារអស្សាមិករណ៍ ។

## ជំពូកទី ៣

## យន្តការអស្សាមិករណ៍

**មាត្រា ១២.-**

គណៈកម្មាធិការអស្សាមិករណ៍មួយត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងក្រសួងស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៣.-**

អនុគណៈកម្មាធិការអស្សាមិករណ៍ ជាសេនាធិការនៃគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបានបង្កើតឡើង និង ដឹកនាំដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និង មានតំណាងមន្ទីរជំនាញ អាជ្ញាធរពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់អនុគណៈកម្មាធិការអស្សាមិករណ៍ត្រូវកំណត់ដោយអនុក្រឹត្យ ដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ។

**មាត្រា ១៤.-**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវបានបង្កើតឡើង និង ដឹកនាំដោយតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង មានតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ៤
## នីតិវិធីនៃអស្សាមិករណ៍
### ផ្នែកទី ១
### នីតិវិធីមុនអស្សាមិករណ៍

**មាត្រា ១៥.-**

អស្សាមិករណ៍ ត្រូវធ្វើឡើងដោយផ្អែកលើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ និង មានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួង ស្ថាប័នសាមី ។

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវរៀបចំសំណើស្តីពីគម្រោងអស្សាមិករណ៍ដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និង សម្រេច ។

**មាត្រា១៦.-**

មុននឹងធ្វើសំណើស្តីពីគម្រោងអស្សាមិករណ៍ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើការអង្កេតជាសាធារណៈ ដោយត្រូវកត់ត្រាភិនភាគឱ្យបានលម្អិតចំពោះរាល់សិទ្ធិរបស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ លើអចលនវត្ថុ និង ទ្រព្យសម្បត្តិផ្សេងៗទៀតដែលមានជាប់ពាក់ព័ន្ធនឹងការផ្តល់សំណង ព្រមទាំងត្រូវកត់ត្រានូវរាល់បញ្ហាពាក់ព័ន្ធ ។

ក្នុងការធ្វើការអង្កេតនេះ គណៈកម្មាធិការអស្សាមិករណ៍ត្រូវរៀបចំចាត់ចែងធ្វើការពិគ្រោះយោបល់ជាសាធារណៈ នៅក្នុងកម្រិតអាជ្ញាធរ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងភូមិ ឬ សហគមន៍ដែលរងនូវអស្សាមិករណ៍ ដើម្បីផ្តល់ពត៌មាន ជាក់លាក់ ច្បាស់លាស់ និង ទទួលបាននូវមតិយោបល់ពីគ្រប់ភាគីពាក់ព័ន្ធអំពីសំណើនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

ដើម្បីកំណត់ពេលវេលាដកហូត ឬ ទីកន្លែងដែលផ្តល់ថ្មី ឬ សំណង គណៈកម្មាធិការអស្សាមិករណ៍ ត្រូវសាកសួរគ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យបានគ្រប់ជ្រុងជ្រោយ អំពីបញ្ហាអចលនវត្ថុ ដែលពាក់ព័ន្ធនឹងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការអស្សាមិករណ៍ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានាដាក់ជូន និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា១៧.-**

ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការអស្សាមិករណ៍ត្រូវចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ដែលក្នុងនោះត្រូវជម្រាបដល់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិឱ្យបានដឹងអំពីអចលនវត្ថុដែលជាកម្មវត្ថុនៃការដកហូតនោះ និង ត្រូវចែងអំពីគោលបំណង នៃការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិលើអចលនវត្ថុឱ្យបានច្បាស់លាស់ ដោយអនុវត្តតាមនីតិវិធី ដូចខាងក្រោម :

ក- កំណត់អំពីកម្មវត្ថុនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ទីតាំង [illegible] និង រយៈពេលសម្រាប់អនុវត្តគម្រោង និង អាជ្ញាធរមានសមត្ថកិច្ច ដែលមានសិទ្ធិដើម្បីធ្វើការដកហូតកម្មសិទ្ធិ និង/ ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិឯកជន

ខ- កំណត់អំពីសំណងសមរម្យ និង យុត្តិធម៌

គ- កំណត់រយៈពេលនៃបណ្តឹងតវ៉ា

ឃ- ផ្ញើសេចក្តីប្រកាសទៅដល់គ្រប់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិដោយភ្ជាប់នូវលិខិតថតចម្លងនៃច្បាប់នេះ

ង- ដាក់ស្លាកសម្គាល់ថា អចលនវត្ថុនេះជាកម្មវត្ថុត្រូវយកហូតសម្រាប់បម្រើគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ

ច- ផ្សព្វផ្សាយសេចក្តីប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ

ឆ- បិទផ្សាយសេចក្តីប្រកាសនៅសាលាឃុំ សង្កាត់ ពាក់ព័ន្ធនឹងទីតាំងគម្រោងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ហើយសេចក្តីប្រកាសនេះត្រូវផ្សព្វផ្សាយជូនដល់ប្រជាជនដែលមានអចលនវត្ថុពាក់ព័ន្ធដោយមេភូមិ ។

**មាត្រា ១៨.-**

បន្ទាប់ពីទទួលបាននូវសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិអាចធ្វើបណ្តឹងសុំឱ្យមានការអង្កេត ដើម្បីឱ្យដឹងថាជាតម្រូវការមួយចាំបាច់ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិពិតប្រាកដមែន ឬ ក៏អាចបង្វែរទីតាំងគម្រោងទៅកន្លែងណាផ្សេងវិញបាន ។ បណ្តឹងនេះអាចធ្វើឡើងតាមរយៈមេធាវី ឬ តំណាងរបស់ខ្លួន ។

បណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីបានទទួលសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ជូនចំពោះគណៈ-កម្មាធិការដោះស្រាយបណ្តឹងតវ៉ា ដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់នេះ ។ ខ្លឹមសារសំខាន់ៗនៃបណ្តឹងមាន ជាអាទិ៍ :

- ឈ្មោះម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាសយដ្ឋាន និង លេខទូរស័ព្ទ
- មូលហេតុនៃការធ្វើបណ្តឹង
- ការរៀបរាប់អំពីលក្ខណៈស្របច្បាប់នៃដីនោះ
- ផលប្រយោជន៍របស់ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិនៅលើដីដែលត្រូវ

ROYAUME DU CAMBODGE

ប៉ុន្តែម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិមិនអាចធ្វើពាក្យបណ្តឹងតវ៉ាសុំឱ្យមានធ្វើការអង្កេតបានទេ ចំពោះតម្រូវការសម្រាប់កិច្ចអភិវឌ្ឍផ្លូវជាតិធំៗ ស្ពាន ផ្លូវរទេះភ្លើង ការតភ្ជាប់ការចែកចាយបណ្តាញទឹក ភ្លើង បំពង់បង្ហូរប្រេងកាត បំពង់បង្ហូរទឹកកខ្វក់ ខ្សែបណ្តាញ ឬ លូមេបង្ហូរទឹក ប្រព័ន្ធធារាសាស្ត្រ ។

បន្ទាប់ពីបានធ្វើការអង្កេតចប់ជាស្ថាពរក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ នៃថ្ងៃធ្វើការ គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ា ត្រូវធ្វើរបាយការណ៍ ដែលក្នុងនោះត្រូវលើកឡើងនូវអនុសាសន៍នានា និង សុំការសម្រេចពីរាជរដ្ឋាភិបាល ។

## ផ្នែកទី ២
## កិច្ចដំណើរការអស្សាមិករណ៍

**មាត្រា ១៩.–**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ អាចធ្វើទៅបានលុះត្រាតែគណៈកម្មាធិការអស្សាមិករណ៍បានផ្តល់សំណងឱ្យម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិជាមុន ដោយសមរម្យ និង យុត្តិធម៌ តាមគោលការណ៍ និង នីតិវិធីនៃការទូទាត់សំណងដូចមានចែងក្នុងផ្នែកទី ៣ ជំពូកទី ៤ នៃច្បាប់នេះ ។

ការដកហូតនៅតែអាចប្រព្រឹត្តទៅបាន ទោះបីទំនាស់នៅមិនទាន់បានដោះស្រាយរួចរាល់ហើយក្តី ។ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលបានទទួលប្រាក់សំណងតាមការកំណត់របស់គណៈកម្មាធិការអស្សាមិករណ៍ នៅតែមានសិទ្ធិបន្តការប្តឹងរបស់ខ្លួនទៅតាមនីតិវិធីនៃការជំទាស់ និង ការដោះស្រាយទំនាស់ដូចបានកំណត់ក្នុងមាត្រា ៣៤ ជំពូកទី ៦ នៃច្បាប់នេះ ។

**មាត្រា ២០.–**

ការដកហូតកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដទៃទៀត ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ ។ សេចក្តីសម្រេចអស្សាមិករណ៍ ត្រូវកំណត់ជាអាទិ៍ :

- កម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុដែលត្រូវបានរកឃើញ
- សំណងដែលត្រូវទូទាត់
- កាលបរិច្ឆេទដែលតម្រូវឱ្យម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិធ្វើការរុះរើចាកចេញពីទីតាំង និង ធ្វើការប្រគល់អចលនវត្ថុ ជូនគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២១.-**

គណៈកម្មាធិការអស្សាមិករណ៍ ត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចអស្សាមិករណ៍ និង ត្រូវផ្ដល់សំណងគ្រប់ចំនួនដល់ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មុននឹងធ្វើអស្សាមិករណ៍ ។

## ផ្នែកទី ៣
## ការទូទាត់សំណងនៃអស្សាមិករណ៍

**មាត្រា ២២.-**

ប្រាក់សំណងដែលត្រូវផ្ដល់ឱ្យទៅម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ ត្រូវគិតតាមថ្ងៃទីផ្សារ ឬ ថ្លៃជំនួសនៅកាលបរិច្ឆេទនៃការចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ។

ថ្លៃទីផ្សារ ឬ ថ្លៃជំនួសត្រូវកំណត់ដោយគណៈកម្មការ ឬ ភ្នាក់ងារឯករាជ្យមួយ តាមការជ្រើសរើសរបស់គណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៣.-**

ម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មានសិទ្ធិទទួលបាននូវសំណងលើការខូចខាតអចលនវត្ថុជាក់ស្ដែង ដែលមានចាប់ពីថ្ងៃចេញសេចក្ដីប្រកាសស្ដីពីគម្រោងអស្សាមិករណ៍ ដែលជាកាលបរិច្ឆេទចុងក្រោយសម្រាប់មានសិទ្ធិទទួលបាននូវសំណងសមរម្យ និង យុត្តិធម៌ ។

**មាត្រា ២៤.-**

សំណងត្រូវទូទាត់ជាសាច់ប្រាក់ ជាទ្រព្យ ឬ ជាសិទ្ធិជំនួសទៅតាមភាពជាក់ស្ដែង ដោយមានការយល់ព្រមពីម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ និង ពីគណៈកម្មាធិការអស្សាមិករណ៍ ។

ROYAUME DU CAMBODGE ... ROYAL

បែបបទ និង នីតិវិធីនៃការទូទាត់សំណង ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២៥.–**

ប្រាក់សំណងត្រូវគិតតាមតម្លៃសំណងសរុប ដកចំនួនទឹកប្រាក់បន្ទុកពន្ធប្រថាប់ត្រា និង/ ឬ ពន្ធលើដីធ្លីមិនប្រើប្រាស់ដែលកន្លងមកមិនទាន់បានបង់ជូនរដ្ឋ ហើយគណៈកម្មាធិការអស្សាមិករណ៍ ត្រូវបង់ប្រាក់ពន្ធកាត់ទុកទាំងនោះចូលថវិកាជាតិ តាមនីតិវិធីជាធរមាន ។

**មាត្រា ២៦.–**

ប្រាក់សំណងចំពោះកម្មសិទ្ធិលើអចលនវត្ថុ និង សិទ្ធិប្រត្យក្សលើអចលនវត្ថុ មិនត្រូវបានគិតដល់ការប្រែប្រួលនៃតម្លៃដែលកើតមានឡើង ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍នោះឡើយ ដោយការប្រែប្រួលទាំងនោះអាចពាក់ព័ន្ធដល់ការផ្លាស់ប្តូរវិធានការបម្រុងផ្ទៃដីទុកដែលមានក្នុងផែនការនគរូបនីយកម្ម ដែលកំណត់តំបន់ប្រើប្រាស់ដីធ្លី ឬ ផែនការប្រើប្រាស់ដីធ្លីដែលបានអនុម័តត្រឹមត្រូវ ឬ ដោយការប្រែប្រួលនោះបណ្តាលមកពីសេចក្តីប្រកាស ស្តីពីគម្រោងអស្សាមិករណ៍ ។

**មាត្រា ២៧.–**

បន្ទាប់ពីទទួលបានប្រាក់សំណងគ្រប់ចំនួនរួចហើយ ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ត្រូវទទួលខុសត្រូវក្នុងការថែរក្សា ស្នាក់អាស្រ័យ កាន់កាប់ និង ទទួលផលដែលលើសិទ្ធិ និង អចលនវត្ថុ រហូតដល់មានការទទួលយកអចលនវត្ថុទាំងនោះ ដោយគណៈកម្មាធិការអស្សាមិករណ៍ ។

**មាត្រា ២៨.–**

គណៈកម្មាធិការអស្សាមិករណ៍អាចទទួលយកអចលនវត្ថុ ឬ សិទ្ធិលើអចលនវត្ថុនោះក្រោយពី :

- បានអនុវត្តតាមនីតិវិធី និង លក្ខខណ្ឌដូចមានចែងក្នុងផ្នែកទី ១ និង ផ្នែកទី ២ ជំពូកទី ៥ នៃច្បាប់នេះ

- ការផ្តល់ប្រាក់សំណងត្រូវបានអនុវត្តតាមគោលការណ៍ និង នីតិវិធីដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី ៤ នៃច្បាប់នេះ ។

**មាត្រា ២៩.-**

ភតិកៈអចលនវត្ថុដែលមានកិច្ចសន្យាត្រឹមត្រូវ ត្រូវទទួលបាននូវសំណងសម្រាប់ការវិខាទនានា ពាក់ព័ន្ធនឹងការផ្លាស់ប្តូរហ្វូតជាអាទិ៍ ការរុះរើសំណង់ សម្ភារៈ ការដឹកជញ្ជូនទៅកាន់ទីតាំងថ្មី ។

ចំពោះភតិកៈអចលនវត្ថុដែលកំពុងប្រកបអាជីវកម្ម ត្រូវមានសិទ្ធិទទួលបាននូវសំណងលើផលប៉ះពាល់ដល់អាជីវកម្មនិងការឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃដើមទុនដែលបានចំណាយជាក់ស្តែង សម្រាប់សកម្មភាពនៃការប្រកបរបរអាជីវកម្មនោះ ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

ចំពោះការផ្លាស់ប្តូរយកទីតាំងដែលកំពុងមានសកម្មភាពអាជីវកម្ម ម្ចាស់អចលនវត្ថុត្រូវមានសិទ្ធិទទួលបានសំណងឧបត្ថម្ភបន្ថែមដោយអត្រាសមរម្យ និង យុត្តិធម៌ លើតម្លៃនៃទ្រព្យសម្បត្តិដែលរងផលប៉ះពាល់ជាក់ស្តែង ដោយគិតត្រឹមថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ។

## ជំពូកទី ៥
## អន្តរកាលនៃការកាន់កាប់ និង គ្រប់គ្រងអចលនវត្ថុ

**មាត្រា ៣០.-**

ចាប់ពីថ្ងៃចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ម្ចាស់អចលនវត្ថុ និង/ឬម្ចាស់សិទ្ធិពុំអាចលក់ ឬ ផ្ទេរអចលនវត្ថុនោះឱ្យអ្នកដទៃបានឡើយ ។ លិខិតឯកសារនានា និង នីតិវិធីទាំងអស់ដែលផ្ទុយនឹងបទប្បញ្ញត្តិនេះ ត្រូវចាត់ទុកជាមោឃៈ ។

ចំពោះការប្រើប្រាស់ដី ឬ អចលនវត្ថុពាក់ព័ន្ធ ត្រូវរក្សាលក្ខណៈ និង ទំហំប្រើប្រាស់ដូចមាននៅពេលចេញសេចក្តីប្រកាសស្តីពីគម្រោងអស្សាមិករណ៍ ហើយមិនត្រូវសាងសង់សំណង់នៅលើដីនោះថែមទៀតឡើយ ។ សកម្មភាពណាដែលផ្ទុយនឹងបញ្ញត្តិខាងលើនេះម្ចាស់អចលនវត្ថុ និង/ឬ ម្ចាស់សិទ្ធិ មិនត្រូវមានសិទ្ធិទទួលបានសំណងលើការសាងសង់សំណង់ថ្មីបន្ថែមនោះឡើយ ។

**មាត្រា ៣១.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចកាន់កាប់អចលនវត្ថុទាំងនោះ បានត្រឹមរយៈពេល ១ ( មួយ ) ខែ បន្ទាប់ពីគណៈកម្មាធិការអស្សាមិករណ៍បានទូទាត់សំណងគ្រប់ចំនួនស្របតាមនីតិវិធី ដូចមានចែងនៅក្នុងជំពូកទី ៤ នៃច្បាប់នេះ លើកលែងតែមានការព្រមព្រៀង ឬ មានការអនុញ្ញាតផ្ទុយពីនេះ ។

ក្នុងករណីម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិពុំព្រមចាកចេញពីទីកន្លែងនោះ គណៈ-កម្មាធិការអស្សាមិករណ៍អាចស្នើសុំទៅស្ថាប័នមានសមត្ថកិច្ច ឬ អាជ្ញាធរសាធារណៈ ដើម្បីចាត់វិធានការ តម្រូវឱ្យជននោះចាកចេញពីទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ។

## ជំពូកទី ៦
## ការដោះស្រាយទំនាស់

**មាត្រា ៣២.-**

គណៈកម្មាធិការអស្សាមិករណ៍ និង គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា មានសមត្ថកិច្ចទទួលពិនិត្យ និង ដោះស្រាយបណ្ដឹងតវ៉ា ។

**មាត្រា ៣៣.-**

ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ ដែលមិនយល់ស្របនឹងសេចក្ដីសម្រេចរបស់គណៈកម្មាធិការអស្សាមិករណ៍ អាចប្ដឹងទៅគណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ។

**មាត្រា ៣៤.-**

ក្នុងករណីដែលមិនមានការយល់ព្រមចំពោះសេចក្ដីសម្រេចរបស់គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ា ម្ចាស់អចលនវត្ថុ និង/ ឬ ម្ចាស់សិទ្ធិ អាចប្ដឹងទៅតុលាការមានសមត្ថកិច្ច ចំពោះនីតិវិធីអស្សាមិករណ៍ដែលធ្វើឡើងមិនបានត្រឹមត្រូវ ការដកហូតដែលមិនយកទៅបម្រើផលប្រយោជន៍សាធារណៈ ផលប្រយោជន៍ជាតិ និង ការទូទាត់សំណងដែលធ្វើឡើងមិនបានគ្រប់ចំនួនសមរម្យ និង យុត្តិធម៌ ។

ទម្រង់បែបបទ និង នីតិវិធីប្ដឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ៣៥.-**

មន្ត្រីមានសមត្ថកិច្ចដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងរដ្ឋបាល ដោយមិនទាន់គិតពីទណ្ឌកម្មផ្សេងទៀតស្របតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន ។

**មាត្រា ៣៦.-**

បុគ្គលណាដែលធ្វើការរារាំងដល់ការអនុវត្តសេចក្តីសម្រេចអស្សាមិករណ៍ដោយគំនិតទុច្ចរិត ធ្វើឱ្យរាំងស្ទះដល់ដំណើរការនៃការអនុវត្តគម្រោងដែលបម្រើឱ្យផលប្រយោជន៍សាធារណៈ ឬ ផលប្រយោជន៍ជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ( មួយ ) ខែ ដល់ ១ ( មួយ ) ឆ្នាំ និង ពិន័យជាប្រាក់ពី ១០០.០០០ ( មួយសែន ) រៀល ដល់ ២.០០០.០០០ ( ពីរលាន ) រៀល ។

**មាត្រា ៣៧.-**

បុគ្គលណាដែលបានកាន់កាប់ ប្រើប្រាស់ដោយរំលោភបំពានលើទីកន្លែងដែលបានធ្វើអស្សាមិករណ៍រួចហើយ ត្រូវផ្តន្ទាទោសតាមបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាន ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៩.–

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១០

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

នស/រកម.០២១០.០០៩

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:១៨៥ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនគេន

# ឧបសម្ព័ន្ធទី ៣

នស/រកត/០៨០៦/៣៣៩

# ព្រះរាជក្រឹត្យ

## ស្តីពី

## គោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សម្ពោហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/ ០២៨៩/ ០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានទ្រង់យល់ព្រះរាជក្រមលេខ ធស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដែលបានការឯកភាព ពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៦

# គ្រាស់បន្ទាប់

## មាត្រា ១.-

ព្រះរាជក្រឹត្យនេះ មានគោលដៅកំណត់គោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ។

## មាត្រា ២.-

អនុបយោគ គឺជាប្រតិបត្តិការនៃការធ្វើចំណាត់ថ្នាក់ឡើងវិញ លើទ្រព្យសម្បត្តិរបស់រដ្ឋ ដែលនាំឱ្យមានការផ្លាស់ប្តូរឋានៈ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

## មាត្រា ៣.-

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ ត្រូវគោរពតាមល័ក្ខខ័ណ្ឌដូចខាងក្រោម ÷

- ទ្រព្យសម្បត្តិនោះ លែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬ
- ទ្រព្យសម្បត្តិនោះ បាត់បង់លក្ខណៈសម្បត្តិពេញលេញរបស់ខ្លួនក្នុងការបម្រើប្រយោជន៍សាធារណៈ ឬ
- ទ្រព្យសម្បត្តិនោះ លែងជាការប្រើប្រាស់ដោយផ្ទាល់ ដោយសាធារណជន។

## មាត្រា ៤.-

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិទាំងឡាយណា ដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរួចជាស្រេច។

## មាត្រា ៥.-

រាជរដ្ឋាភិបាល សម្រេចធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ដោយអនុក្រឹត្យ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ។៥

មាត្រា ៦.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៧.-

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៦

នស/រកត/០៨០៦/៣៦០

លេខ : ៣២១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

# ឧបសម្ព័ន្ធទី ៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧២ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

៚៚៚៚៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ , នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

អនុក្រឹត្យនេះមានគោលបំណង ÷

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយ ក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច

- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុង ដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន

- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រម ទាំង ទទួលយកមតិ យោបល មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង ។

**មាត្រា ២ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ៣ .–**

ក្រសួងបរិស្ថាន មានភារៈកិច្ច ÷

ក.ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ.

ខ.តាមដាន ឃ្លាំមើល និងចាត់វិធានការ ឱ្យម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច ។

**មាត្រា ៤ .-**

ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគំរោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគំរោង ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៥ .-**

អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគំរោង ខេត្ត-ក្រុង មានភារៈកិច្ច ÷

- បញ្ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគំរោងដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង
- ពិនិត្យ និងសំរេចលើគំរោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរ បរិស្ថានថ្នាក់ខេត្ត-ក្រុង ដែល ក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣
## តម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

**មាត្រា ៦ .-**

ម្ចាស់គំរោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគំរោងដែលតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧ .-**

ម្ចាស់គំរោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍សិក្សាបុរេលិទ្ធភាពទៅក្រសួងបរិស្ថាន ។

**មាត្រា ៨ .-**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ ។

**មាត្រា ៩ .–**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុង មាត្រា ៧ និងមាត្រា ៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង ចំពោះ គំរោងថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ១០ .–**

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និង របាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១១ .–**

ម្ចាស់គំរោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់ បរិស្ថាន និងការតាមដាន ឃ្លាំមើល ការអនុវត្តន៍គំរោង ។ តំលៃសេវាការងារនេះត្រូវកំណត់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ ។

**មាត្រា ១២ .–**

ម្ចាស់គំរោងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូច មានចែងក្នុងមាត្រា ១៩ ជំពូកទី៨ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធាន ធម្មជាតិ ។

**មាត្រា ១៣ .–**

ពាក្យសុំត្រូវបំពេញដោយម្ចាស់គំរោង និងត្រូវផ្តល់ជូនដោយក្រសួងបរិស្ថាន ចំពោះគំរោង ថ្នាក់ក្រសួង-ស្ថាប័ន និងត្រូវផ្តល់ជូនដោយមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគំរោងថ្នាក់ ខេត្ត-ក្រុង ។

## ជំពូកទី ៤

## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

**មាត្រា ១៤ .–**

ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និង ផ្តល់លិខិតចំលង ទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៥ .–**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយះពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គំរោង ។

**មាត្រា ១៦ .–**

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឱ្យមានរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៧ .–**

ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយះពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ពីម្ចាស់គំរោង ។

**មាត្រា ១៨ .–**

ក្នុងករណី ក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា១៧ នោះ ស្ថាប័នអនុម័តគំរោងអាចកំណត់ថា គំរោងនោះត្រូវបានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ ។

**មាត្រា ១៩ .–**

ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគំរោងផង និងជាម្ចាស់គំរោងផងនោះ ម្ចាស់គំរោងត្រូវមានភារៈកិច្ចអនុវត្តតាមកិច្ចដំណើរការ ដូចមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០ .-**

មុនចាប់ដំណើរការអនុវត្តគំរោង ម្ចាស់គំរោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថានលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## ជំពូកទី ៥
## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន ចំពោះសកម្មភាពមានស្រាប់

**មាត្រា ២១ .-**

ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពី អនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការ ដែលបានទទួលការអនុម័តពីថ្នាក់ក្រសួង-ស្ថាប័ន ។

**មាត្រា ២២ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថាសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ តម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៣ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថានបានចេញសេចក្ដីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤ .-**

ក្នុងរយៈពេលយ៉ាងយូរ ០២ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបានទទួលការអនុម័តពីថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ២៥ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលមន្ទីរបរិស្ថានខេត្ត-ក្រុងពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៦ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃដែល មន្ទីរបរិស្ថានខេត្ត-ក្រុងបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ ។

## ជំពូកទី៦

## លក្ខខំណ្ឌ នៃការអនុម័តគំរោង

**មាត្រា ២៧ .-**

ស្ថាប័នអនុម័តគំរោង ត្រូវណែនាំម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធ ឱ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានរៀបរាប់ក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន ។

**មាត្រា ២៨ .-**

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធចេញបញ្ជាឱ្យផ្អាកសកម្មភាព ចំពោះ...

ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃតំរោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ២៩ .-**

ម្ចាស់តំរោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវពត៌មាន ឬមិនបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នាទៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០/២១/ ២២/២៣ និងមាត្រា ២៥ ជំពូកទី៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣០ .-**

កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣១ .-**

មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា របស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តិបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារៈកិច្ចរៀង១ខ្លួន ។

**មាត្រា ៣៤ .-**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

សែន

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

**ចំលងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៣
- កាលប្បវត្តិ - ឯកសារ

តារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧២.អនក្រ.បក ចុះថ្ងៃទី១១..ខែសីហាឆ្នាំ១៩៩៩

ចំណាត់ថ្នាក់គំរោងឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទអាជីវកម្ម | ទំហំ |
|---|---|---|
| **១** | **វិស័យឧស្សាហកម្ម** | |
| **១.១** | **ផ្នែក ស្បៀង, ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់** | |
| ១.១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.២ | មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ | ≥ ១.៥០០ លីត្រ/ថ្ងៃ |
| ១.១.៣ | មូលដ្ឋានផលិតជំណាប់ផ្លែឈើ | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.១.៥ | មូលដ្ឋានផលិតស្រា | គ្រប់ទំហំ |
| ១.១.៦ | មូលដ្ឋានផលិតស្រាបៀរ - អាល់កុល | គ្រប់ទំហំ |
| ១.១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥ ១០.០០០ នាក់ប្រើប្រាស់ |
| ១.១.៨ | មូលដ្ឋានផលិតបារី | ≥ ១០.០០០ កញ្ចប់/ថ្ងៃ |
| ១.១.៩ | មូលដ្ឋានផលិត កែច្នៃសន្លឹកថ្នាំជក់ | ≥ ៣៥០ តោន/ឆ្នាំ |
| ១.១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១២ | មូលដ្ឋានផលិតទឹកត្រី - ស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ | ≥ ៥០០.០០០ លីត្រ/ឆ្នាំ |
| **១.២** | **ផ្នែកវាយនភ័ណ្ឌ, សំលៀកបំពាក់, និង ផលិតផលស្បែក** | |
| ១.២.១ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.២ | រោងចក្រកាត់ដេរ - បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.៣ | រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី | គ្រប់ទំហំ |
| ១.២.៤ | រោងចក្រផលិតអេប៉ុង - កៅស៊ូមូស | គ្រប់ទំហំ |
| **១.៣** | **ផ្នែកផលិតផលពីឈើ** | |
| ១.៣.១ | រោងចក្រក្ការបន្ទះ | ≥ ១០០.០០០ ម៉ែ/ឆ្នាំឈើមូល |

| | | |
|---|---|---|
| ១.៣.២ | មូលដ្ឋានផលិតគ្រឿងសង្ហារឹម | ≥ ១.០០០ម៣/ឆ្នាំ ឈើមូល |
| ១.៣.៣ | រោងចក្រអារឈើ | ≥ ៥០.០០០ម៣/ឆ្នាំឈើមូល |
| **១.៤** | **វិស័យផលិតក្រដាស** | |
| ១.៤.១ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.៤.២ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| **១.៥** | **វិស័យគីមី - ផលិតផលពីកៅស៊ូ និងប្លាស្ទិក** | |
| ១.៥.១ | រោងចក្រប្លាស្ទិក | គ្រប់ទំហំ |
| ១.៥.២ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥ ៥០០ តោន/ឆ្នាំ |
| ១.៥.៣ | រោងចក្រកៅស៊ូក្រែប | ≥ ១.០០០ តោន/ឆ្នាំ |
| ១.៥.៤ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.៥.៥ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.៥.៦ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន/ឆ្នាំ |
| ១.៥.៧ | រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត | គ្រប់ទំហំ |
| ១.៥.៨ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៥.៩ | រោងចក្រគីមីប្រេងកាត | គ្រប់ទំហំ |
| ១.៥.១០ | រោងចក្រផលិតម្សៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក | គ្រប់ទំហំ |
| **១.៦** | **វិស័យផលិតផលពីរ៉ែ មិនមែនជាលោហៈ** | |
| ១.៦.១ | រោងចក្រស៊ីម៉ងត៍ | គ្រប់ទំហំ |
| ១.៦.២ | រោងចក្រចំរាញ់ប្រេងកាត | គ្រប់ទំហំ |
| ១.៦.៣ | រោងចក្រផលិតឧស្ម័ន | គ្រប់ទំហំ |
| ១.៦.៤ | សំណង់បង្ហូរប្រេង និងឧស្ម័ន | ≥ ២ គ.ម |
| ១.៦.៥ | កន្លែងស្តុកប្រេងឥន្ធនៈសំរាប់ចែកចាយ | ≥ ១.០០០.០០០ លីត្រ |
| ១.៦.៦ | ស្ថានីយប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |
| ១.៦.៧ | ការធ្វើអាជីវកម្មរ៉ែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១.៦.៨ | រោងចក្រផលិតកែវ - ដបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៦.៩ | មូលដ្ឋានផលិតឥដ្ឋក្បឿង | ≥ ១៥០.០០០ ដុំ/ខែ |
| ១.៦.១០ | មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ | ≥ ៩០.០០០ ដុំ/ខែ |
| ១.៦.១១ | រោងចក្រផលិតថ្មស្មួយ | គ្រប់ទំហំ |
| ១.៦.១២ | មូលដ្ឋានផលិតគ្រឿងសំណង់បេតុង | ≥ ៩០០ តោន/ខែ |
| ១.៦.១៣ | រោងចក្រផលិតខ្លាញ់គោ - ប្រេងម៉ាស៊ីន | គ្រប់ទំហំ |
| ១.៦.១៤ | ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត (ការខួកសាកល្បង , ការធ្វើឲ្យរញ្ជួយដី ) | គ្រប់ទំហំ |
| **១.៧** | **ផ្នែកឧស្សាហកម្មលោហៈ មូលដ្ឋាន** | |
| ១.៧.១ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.២ | រោងចក្រតំឡើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.៣ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| **១.៨** | **ផ្នែកឧស្សាហកម្មកែច្នៃលោហៈ** | |
| ១.៨.១ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - លួសបន្លា - សំណាញ់ | ≥ ៣០០ តោន/ខែ |
| ១.៨.២ | រោងចក្រស្លដែក - ដែកថែប - អាលុយមីនីញ៉ូម | គ្រប់ទំហំ |
| ១.៨.៣ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| **១.៩** | **ផ្នែកឧស្សាហកម្មផ្សេងៗ** | |
| ១.៩.១ | មូលដ្ឋានកែច្នៃសំណល់ - ដុតសំណល់ | គ្រប់ទំហំ |
| ១.៩.២ | មូលដ្ឋានសំអាតទឹកសំអុយ | គ្រប់ទំហំ |
| ១.៩.៣ | រោងចក្រអគ្គិសនី | ≥ ៥ MW |
| ១.៩.៤ | រោងចក្រវារីអគ្គិសនី | ≥ ១ MW |
| ១.៩.៥ | រោងចក្រផលិតសំឡី | ≥ ១៥ តោន/ខែ |
| ១.៩.៦ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ [illegible] |

| | | |
|---|---|---|
| **២** | **វិស័យកសិកម្ម** | |
| ២.១ | ព្រៃសម្បទាន | ≥ ១០.០០០ ហិចតា |
| ២.២ | អាជីវកម្មព្រៃកប់ | ≥ ៥០០ ហិចតា |
| ២.៣ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហ.ត |
| ២.៤ | ផ្ទៃដីដំណាំកសិកម្ម - ឧស្សាហកម្ម | ≥ ១០.០០០ ហ.ត |
| ២.៥ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | គ្រប់ទំហំ |
| ២.៦ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហ.ត |
| ២.៧ | ប្រព័ន្ធដោះទឹក | ≥ ៥.០០០ ហ.ត |
| ២.៨ | ផែនេសាទ | គ្រប់ទំហំ |
| **៣** | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ | ≥ ៥០ ហ.ត |
| ៣.២ | ទីលានវាយកូនគោល | ≥ ១៨ រន្ធ |
| **៤** | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍន៍ទីក្រុង | គ្រប់ទំហំ |
| ៤.២ | តំបន់ឧស្សាហកម្ម | គ្រប់ទំហំ |
| ៤.៣ | សំណង់ស្ពានថ្នល់ | ទម្ងន់ ≥ ៣០ តោន |
| ៤.៤ | សំណង់អាគារ | កំពស់ ≥ ១២ ម. ឬ<br>ក្រឡាផ្ទៃ ៨.០០០ ម$^{២}$ |
| ៤.៥ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៦ | សំណង់សណ្ឋាគារ | ≥ ៦០ បន្ទប់ |
| ៤.៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ | ≥ ៤០ បន្ទប់ |
| ៤.៨ | សំណង់ផ្លូវជាតិ | ≥ 100 គ.ម |
| ៤.៩ | សំណង់ផ្លូវដែក | គ្រប់ទំហំ |
| ៤.១០ | សំណង់កំពង់ផែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៩.១១ | សំណង់អាកាសយានដ្ឋាន | គ្រប់ទំហំ |
| ៩.១២ | ការបូមភក់ - ល្បប់ | ≥ ៥០.០០០ ម$^{២}$ |
| ៩.១៣ | កន្លែងចាក់សំរាមទីក្រុង | ≥ ប្រជាជន ២០០.០០០នាក់ |

# ឧបសម្ព័ន្ធទី ៥

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ទិធាន និង នីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ និងច្បាប់ទាំងឡាយដែលធ្វើវិសោធនកម្មច្បាប់នេះ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលរចនាសម្ព័ន្ធមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៦

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសំរាប់គ្រប់គ្រង និងចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ ទាក់ទងនឹង ÷

- ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ
- ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
- ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ
- ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

**មាត្រា ២.-**

គោលការណ៍ទូទៅសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិរបស់រដ្ឋ មានដូចខាងក្រោម ÷

១- រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងរបស់នីតិបុគ្គលសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាសេនាធិការឱ្យរាជរដ្ឋាភិបាល លើការលក់ ការដូរ និងការជួល នូវទ្រព្យសម្បត្តិរបស់រដ្ឋ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការដូរចលនទ្រព្យ និងអចលនទ្រព្យ ដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ជូនរាជរដ្ឋាភិបាល ។

២- ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ដែលកំពុងកាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្មទ្រព្យសម្បត្តិរបស់រដ្ឋ ជាអាជ្ញាធរកាន់កាប់ប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋ

នៅក្នុងន័យនៃអនុក្រឹត្យនេះ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានសមត្ថកិច្ចត្រឹមតែប្រើប្រាស់ ថែរក្សា និងស្នើសុំ លក់ ដូរ ឬជួល ។

៣- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ ត្រូវចុះបញ្ជីនៅក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៤- ទ្រព្យសម្បត្តិរបស់រដ្ឋទាំងអស់ ដែលរួមមានទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់នីតិបុគ្គលសាធារណៈ អាចត្រូវបានលក់ ដូរ ជួល ឬផ្តល់ឱ្យជាសម្បទានផ្សេងទៀតបាន លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ។ លក្ខខណ្ឌ និងនីតិវិធីនៃការលក់ ការដូរ និងការជួលទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដែលមានចែងនៅក្នុងអនុក្រឹត្យនេះ។ ចំណែកឯលក្ខខណ្ឌ និងនីតិវិធីនៃការធ្វើសម្បទានទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវកំណត់ដោយបទប្បញ្ញត្តិដោយឡែក។

**មាត្រា ៣.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ទ្រព្យសម្បត្តិទាំងនេះអាចជាចលនទ្រព្យ និងអចលនទ្រព្យ។ ទ្រព្យសម្បត្តិរបស់រដ្ឋ សំដៅលើទ្រព្យសម្បត្តិទាំងឡាយ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងទ្រព្យសម្បត្តិទាំងឡាយ ដែលរដ្ឋប្រគល់ទៅឱ្យនីតិបុគ្គលសាធារណៈដទៃទៀត កាន់កាប់ ប្រើប្រាស់ ថែរក្សា និងធ្វើអាជីវកម្ម។

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺមានទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋ ក្រៅពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដូចបានកំណត់ក្នុងមាត្រា ៥៨ នៃរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ព្រមទាំងមាត្រា ១២ និងមាត្រា ១៥ នៃច្បាប់ភូមិបាល ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១។

**មាត្រា ៤.-**

ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងអស់ រួមទាំងទ្រព្យសម្បត្តិ ដែលកំពុងស្ថិតនៅក្រោមការកាន់កាប់របស់រដ្ឋ របស់នីតិបុគ្គលសាធារណៈដទៃទៀត អាចជាកម្មវត្ថុនៃការជួល ការលក់ និងការដូរបាន ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ក៏ដូចជាទ្រព្យសម្បត្តិសាធារណៈរបស់នីតិបុគ្គលសាធារណៈដទៃទៀត មិនអាចជាកម្មវត្ថុនៃការលក់ ការដូរ ឬការផ្ទេរកម្មសិទ្ធិណាមួយបានឡើយ។ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទាំងនេះ អាចជាកម្មវត្ថុនៃការជួលបានតែក្នុងលក្ខខណ្ឌ និងនីតិវិធីដែលមានបញ្ញត្តិនៅក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ២

## ការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ

**មាត្រា ៥.-**

ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលត្រូវចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ រួមមានចលនទ្រព្យ និងអចលនទ្រព្យ ទាំងអស់ដែលស្ថិតនៅក្រោមអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដូចជា ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត។

**មាត្រា ៦.-**

ការធ្វើបញ្ជីសារពើភ័ណ្ឌ ចែកចេញជាបួនថ្នាក់ រួមមាន ÷

១- ថ្នាក់កណ្តាល ឬថ្នាក់ក្រសួង ស្ថាប័ន

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋដែលកាន់កាប់ដោយក្រសួង ស្ថាប័ន ត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ថ្នាក់ដឹកនាំក្រសួងស្ថាប័ន ជាប្រធាន
- ប្រធាននាយកដ្ឋានជំនាញពាក់ព័ន្ធ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ ដែលបានរៀបចំរួច ។

២- ថ្នាក់មន្ទីរជំនាញតាមខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិកដូចខាងក្រោម ÷

- ប្រធានមន្ទីរជំនាញសាមីដែលទទួលខុសត្រូវអង្គភាពប្រើប្រាស់ ជាប្រធាន
- ប្រធានការិយាល័យប្រើប្រាស់នៃមន្ទីរជំនាញ ជាសមាជិក
- ប្រធានការិយាល័យប្រើប្រាស់ តាមស្រុកខណ្ឌ ជាសមាជិក ។

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវ លើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត ក្រុង ។

៣- ថ្នាក់ខេត្ត ក្រុង

គណៈកម្មការបញ្ជីសារពើភ័ណ្ឌត្រូវបង្កើតឡើង រួមមានសមាជិកដូចខាងក្រោម ÷

ក. សាលាខេត្ត ក្រុង :

| | |
|---|---|
| - នាយខុទ្ទកាល័យ ឬប្រធានក្រុមហិរញ្ញវត្ថុ | ជាប្រធាន |
| - គ្រប់ប្រធានការិយាល័យផ្ទៃក្នុងរបស់សាលាខេត្ត ក្រុង | ជាសមាជិក ។ |

ខ. សាលាស្រុក ខណ្ឌ :

| | |
|---|---|
| - អភិបាលស្រុក ខណ្ឌ | ជាប្រធាន |
| - ប្រធានការិយាល័យផ្ទៃក្នុង· | ជាសមាជិក |
| - មេឃុំ- ចៅសង្កាត់ | ជាសមាជិក ។ |

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌ និងត្រូវមានហត្ថលេខាពីប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្ត ក្រុង ព្រមទាំងមានការឯកភាពពីអភិបាលខេត្ត ក្រុង ។

៤- ថ្នាក់នីតិបុគ្គលសាធារណៈដទៃទៀត

គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតឡើងដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌ រួមមានសមាជិក ដូចខាងក្រោម ÷

| | |
|---|---|
| - ប្រធានអង្គភាព | ជាប្រធាន |
| - ប្រធានផ្នែកជំនាញពាក់ព័ន្ធ | ជាសមាជិក |

ប្រធាន និងសមាជិកនៃគណៈកម្មការនេះ ត្រូវចុះហត្ថលេខាទទួលខុសត្រូវលើបញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួច ។

**មាត្រា ៧.-**

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកជំរុញ និងណែនាំដល់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ឱ្យរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ តាមបែបបទ និងនីតិវិធីដែលមានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវធ្វើបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវរួចរាល់ និងផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ យ៉ាងយូរនៅចុងត្រីមាសទី ១ នៃឆ្នាំបន្ទាប់ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសរសេរបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិរបស់រដ្ឋចូលក្នុងបញ្ជីសារពើភ័ណ្ឌ ។

រាល់បញ្ជីសារពើភ័ណ្ឌដែលបានរៀបចំរួចរាល់ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវផ្តល់ចំនួនពីរច្បាប់ ជូន ដល់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីតំកល់ទុក និងតាមដាន ។

អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ ជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៣
## ការជួលទ្រព្យសម្បត្តិរបស់រដ្ឋ
### ផ្នែកទី ១
### ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ៨.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យ-សម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៩.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួន ជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួលនោះ ។

**មាត្រា ១០.-**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋត្រូវរៀបចំធ្វើឡើង ក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិដែលត្រូវការជួល អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសំរេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។ ក្នុងករណីចាំបាច់ ត្រូវមានការសម្រេចជាមុនពីប្រមុខរាជរដ្ឋាភិបាល ។

នីតិវិធីលំអិតនៃការដេញថ្លៃ និងការចរចា ពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១១.-**

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១២.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គល គឺរិតជាតិ ឬអន្តរជាតិ ចាប់ពី ២ ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវជួល ។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១- ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ

២- ប្រកួតប្រជែងដោយផ្ទាល់មាត់ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

**មាត្រា ១៣.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១- ការដេញថ្លៃមិនទទួលបានលទ្ធផល

២- លក្ខណៈពិសេសនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលតំរូវឱ្យអ្នកជួលត្រូវបំពេញបន្ថែមនូវលក្ខខណ្ឌចាំបាច់ផ្សេងៗទៀត ។

៣- មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំជួលតែមួយ ។

**មាត្រា ១៤ ..**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការជាស្ថាពរ ដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ មានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាជួល ដើម្បីរៀបចំនូវសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចបន្តសាជាថ្មីបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី) ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃបានមិនព្រមចរចា ពិភាក្សា រៀបចំកិច្ចសន្យាជួល តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យាត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសំរួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ យ៉ាងយូរ ក្រោយពីទទួលបានពីអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ។

កិច្ចសន្យាត្រូវចែងអំពីលក្ខខណ្ឌចាំបាច់ដែលមានជាអាទិ៍ ៖

១- ការកំណត់ថ្លៃឈ្នួល និងការបង់ថ្លៃឈ្នួល ដោយគិតតាមខែ ត្រីមាស ឬ ឆ្នាំ តាមការព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ។

២- ក្នុងករណីបង់ថ្លៃឈ្នួលយឺតយ៉ាវ អ្នកទទួលជួលត្រូវទទួលការពិន័យ ២ (ពីរ) ភាគរយក្នុងមួយខែលើថ្លៃឈ្នួល ដែលត្រូវបង់តាមខែ ត្រីមាស ឬ ឆ្នាំ ចាប់ពីរយៈពេល ៦០ (ហុកសិប) ថ្ងៃ ក្រោយការកំណត់តទៅ។ ប្រាក់ពិន័យនេះ ត្រូវគណនាតាមរូបមន្តការប្រាក់សមាស។

៣- ក្នុងករណីខកខានបង់ថ្លៃឈ្នួលក្នុងរយៈពេលសរុប ៦ (ប្រាំមួយ) ខែ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋត្រូវលុបកិច្ចសន្យា និងត្រូវអនុវត្តតាមផ្លូវច្បាប់ជាធរមាន បន្ទាប់ពីមានការយល់ព្រមពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ។ ក្នុងករណីនេះ ប្រសិនបើអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមិនអាចអនុវត្តបានទេ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនឹងចាត់វិធានការ ក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីលុបកិច្ចសន្យា និងចាត់វិធានការតាមផ្លូវច្បាប់ជាធរមាន។

កិច្ចសន្យាជួលទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយណា ដែលមិនគោរពតាមនីតិវិធី និងមិនចែងនូវលក្ខខណ្ឌចាំបាច់ដូចខាងលើនេះ ត្រូវចាត់ទុកជាមោឃៈ។

## ផ្នែកទី ២

## ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

**មាត្រា ១៥.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលជាកម្មវត្ថុនៃការជួល រួចលើកសំណើសុំជួលទ្រព្យសម្បត្តិសាធារណៈនោះ មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ១៦.-**

ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋត្រូវគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម ÷

១- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនត្រូវធ្វើឱ្យមានការកែប្រែទិសដៅនៃការប្រើប្រាស់ ឬធ្វើឱ្យមានការខូចខាតដល់ទ្រព្យសម្បត្តិទាំងនោះឡើយ ។

២- ការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនត្រូវមានការប៉ះពាល់ ឬធ្វើឱ្យផ្លាស់ប្តូរដល់មុខងារបំរើសេវាសាធារណៈរបស់ទ្រព្យសម្បត្តិទាំងនោះឡើយ ។

**មាត្រា ១៧.-**

ក្រោយពីទទួលបានការអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចរៀបចំដំណើរការនៃការជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនេះ ទៅតាមនីតិវិធីដូចដែលកំណត់នៅក្នុងផ្នែកទី២ នៃជំពូកនេះ ។

**មាត្រា ១៨.-**

កិច្ចសន្យាជួលទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចមានរយៈពេលលើសពី ១៥ (ដប់ប្រាំ) ឆ្នាំឡើយ ។ កិច្ចសន្យានេះធ្វើឡើងក្រោមរូបភាពជាលិខិតអនុញ្ញាតកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋដែលមានលក្ខណៈជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបានគ្រប់ពេលវេលា ក្នុងបំណងការពារទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងបំរើប្រយោជន៍សាធារណៈ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានភារកិច្ចរៀបចំសៀវភៅបន្ទុកដែលកំណត់អំពីលក្ខខណ្ឌផ្សេងៗនៃការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនោះ ។

## ផ្នែកទី ៣

## ការកែសម្រួលបំពេញបន្ថែមលើកិច្ចសន្យាជួល និងការបង់ចំណូល

**មាត្រា ១៩.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ដែលជាភាគីនៃកិច្ចសន្យាជួលមានរយៈពេល ៩ ( ប្រាំបួន) ខែ ដើម្បីពិនិត្យ និងធ្វើការកែសម្រួលលើកិច្ចសន្យាជួលទ្រព្យសម្បត្តិរបស់រដ្ឋទាំងឡាយ ដែលបានធ្វើឡើងមុនអនុក្រឹត្យនេះចូលជាធរមាន ដោយរៀបចំបន្ថែមនូវល័ក្ខខ័ណ្ឌចាំបាច់ដូចដែលមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុន នៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀត តាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤

## ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ២១.-**

បទប្បញ្ញត្តិទាំងឡាយនៃជំពូកនេះ ត្រូវអនុវត្តចំពោះការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលកំពុងស្ថិតក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា ការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងនីតិបុគ្គលសាធារណៈដទៃទៀត ទាំងអចលនទ្រព្យ និងចលនទ្រព្យ ។

**មាត្រា ២២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ជាអ្នកលើកសំណើសុំលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ហើយត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរដ្ឋនេះ ដែលជាកម្មវត្ថុនៃការលក់ទៅឱ្យភាគីម្ខាងទៀត ដោយភ្ជាប់ឯកសារពាក់ព័ន្ធទាំងអស់នេះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ២៣.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ២៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃមួយលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ដោយផ្អែកលើមូលដ្ឋានបច្ចេកទេស និងតម្លៃទីផ្សារ ហើយលើកសំណើនៃការវាយតម្លៃរបស់ខ្លួនជូនអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ។ គណៈកម្មការវាយតម្លៃនេះ ត្រូវមានតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នជំនាញពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យ សម្បត្តិរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការលក់នោះ ។

**មាត្រា ២៥.-**

ការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវរៀបចំធ្វើឡើងក្រោមរូបភាពនៃការដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ដូចករណីនៃការជួលដែរ ។

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការលក់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋត្រូវពិនិត្យ ផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ។ ក្នុងករណីចាំបាច់ត្រូវមានការសម្រេចជាមុនពីរាជរដ្ឋាភិបាល ។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ២៦.-**

ការដេញថ្លៃអាចប្រព្រឹត្តទៅបាន បើមានការចូលរួមពីរូបវន្តបុគ្គល ឬនីតិបុគ្គលគីតជាតិ ឬអន្តរជាតិ ចាប់ពី ២ (ពីរ) ឡើងទៅ និងអាស្រ័យលើវិសាលភាពនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលត្រូវលក់ ។

ការដេញថ្លៃអាចប្រព្រឹត្តទៅតាមរូបភាព :

១-ប្រកួតប្រជែងដោយចំហ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

២-ប្រកួតប្រជែងដោយផ្ទាល់មាត់ ជាលក្ខណៈជាតិ ឬអន្តរជាតិ ។

**មាត្រា ២៧.-**

ការចរចាពិគ្រោះថ្លៃអាចប្រព្រឹត្តទៅបានក្នុងករណីណាមួយដូចខាងក្រោម ÷

១-បើការដេញថ្លៃមិនទទួលបានលទ្ធផល ។

២-មានរូបវន្តបុគ្គល ឬនីតិបុគ្គលស្នើសុំទិញតែមួយ ។

៣-អ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះស្នើសុំទិញពីរដ្ឋ ក្នុងករណីអ្នកជួលទ្រព្យសម្បត្តិរបស់រដ្ឋនោះបានចំណាយទុនវិនិយោគបានយ៉ាងតិចចំនួន ៣០ (សាមសិប)ភាគរយនៃគម្រោងវិនិយោគ ឬក្នុងករណីដែលរដ្ឋបានផ្តល់មធ្យោបាយ និងហេដ្ឋារចនាសម្ព័ន្ធដែលមានរួចស្រេច ហើយគម្រោងនោះបានដំណើរការរយៈពេល ១(មួយ) ឆ្នាំ យ៉ាងតិច ។

**មាត្រា ២៨.-**

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ ឬការចរចាពិគ្រោះថ្លៃ ដែលទទួលស្គាល់ជាផ្លូវការជាស្ថាពរពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាលហើយនោះ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ សម្រាប់ពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាលក់-ទិញ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀត ដែលរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងជាការចាំបាច់ ។ ក្នុងករណីអ្នកដេញថ្លៃមិនព្រមចរចាពិភាក្សារៀបចំកិច្ចសន្យាទិញ-លក់តាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសចូលថវិការដ្ឋ ។

បន្ទាប់ពីមានការព្រមព្រៀងលើរាល់លក្ខខណ្ឌនៃសេចក្តីព្រាងកិច្ចសន្យា រវាងភាគីកិច្ចសន្យា និងក្រោយពីទទួលបានការពិនិត្យ និងកែសម្រួលពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋរួចរាល់ ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា ។

**មាត្រា ២៩.-**

ចំណូលដែលបានមកពីការលក់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលមេទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬក្នុងខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

**មាត្រា ៣០.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនភាគីឯកជនបាន អាចធ្វើទៅបានលុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចប់សព្វគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត តាមកំណត់ច្បាប់ ។

## ជំពូកទី ៥
## ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

**មាត្រា ៣១.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ គឺជាការផ្ទេរកម្មសិទ្ធិទៅវិញទៅមករវាងភាគីឯកជន និងភាគីរដ្ឋ ។

ការដូរធ្វើឡើងក្នុងគោលបំណងដោះស្រាយទីកន្លែងបំពេញការងារ រៀបចំតំបន់រដ្ឋបាលឱ្យបានសមស្របទៅតាមតម្រូវការជាក់ស្តែង និងតាមទិន្នាការអភិវឌ្ឍន៍ ។

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ អាចស្នើដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទាំងឡាយ ដែលរួមមានចលនទ្រព្យ និងអចលនទ្រព្យ ដើម្បីបានមកវិញនូវទ្រព្យសម្បត្តិថ្មីសមស្រប ដែលផ្តល់ឱ្យដោយភាគីឯកជន ។

**មាត្រា ៣២.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវរៀបចំឱ្យបានត្រឹមត្រូវនូវរាល់ឯកសារពាក់ព័ន្ធនឹងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលជាកម្មវត្ថុនៃការដូរជាមួយនឹងទ្រព្យសម្បត្តិដែលផ្តល់ដោយឯកជន មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល ។

**មាត្រា ៣៣.-**

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាចលនទ្រព្យ ជាសមត្ថកិច្ចរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ លើកលែងតែចលនទ្រព្យដែលមានតម្លៃខ្ពស់ ។

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាអចលនទ្រព្យ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៤.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវបង្កើតគណៈកម្មការវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដោយមានការចូលរួមពីតំណាងរបស់អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងរបស់ស្ថាប័នពាក់ព័ន្ធ ដើម្បីសិក្សាវាយតម្លៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរនោះ ស្របតាមគោលការណ៍បច្ចេកទេស និងតម្លៃទីផ្សារ ។

មាត្រា ៣៥.-

ការដូរទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ជាមួយនឹងទ្រព្យសម្បត្តិរបស់ភាគីឯកជន ត្រូវប្រព្រឹត្តិតាមរូបភាពដេញថ្លៃជាសាធារណៈ ឬចរចាពិគ្រោះថ្លៃ ទៅតាមនីតិវិធីដូចដែលមានចែងក្នុងមាត្រា ២៦ និងមាត្រា ២៧ នៃអនុក្រឹត្យនេះ។

ភាគីឯកជនដែលចូលរួមដេញថ្លៃ ឬចរចាពិគ្រោះថ្លៃ ត្រូវមានទ្រព្យសម្បត្តិសមស្រប ដើម្បីជាថ្នូរនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

ល័ក្ខខ័ណ្ឌ និងការទូទាត់តម្លៃនៃការដូរ ត្រូវកំណត់ឡើងដោយសៀវភៅបន្ទុកមួយ ដែលត្រូវរៀបចំដោយអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអាជ្ញាធរនេះត្រូវផ្ញើសៀវភៅបន្ទុកនោះមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់សុំការសម្រេចពីរាជរដ្ឋាភិបាល។

មាត្រា ៣៦.-

ផ្អែកលើសំណើរបស់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងលទ្ធផលនៃការវាយតម្លៃលើទ្រព្យសម្បត្តិឯកជនរបស់រដ្ឋដែលជាកម្មវត្ថុនៃការដូរ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវពិនិត្យផ្តល់យោបល់ និងសម្រេចជាគោលការណ៍ឱ្យដេញថ្លៃ ឬចរចារពិគ្រោះថ្លៃ។ ក្នុងករណីចាំបាច់ អាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ត្រូវស្នើសុំការសម្រេចជាមុនពីរាជរដ្ឋាភិបាល។

នីតិវិធីលម្អិតនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៣៧.-

ផ្អែកតាមលទ្ធផលនៃការដេញថ្លៃ និងការចរចាពិគ្រោះថ្លៃ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការស្ពាពរដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ឬរាជរដ្ឋាភិបាល អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ដើម្បីពិភាក្សាជាមួយភាគីដែលត្រូវចុះកិច្ចសន្យាដូរ ដើម្បីរៀបចំសេចក្តីព្រាងកិច្ចសន្យានោះ។ រយៈពេលនេះអាចពន្យាជូនបានមួយលើកទៀតដែលមានរយៈពេលយ៉ាងយូរ ៣ (បី)ខែ ប្រសិនបើពិនិត្យឃើញមានមូលហេតុសមស្រប និងចាំបាច់។ ក្នុងករណីអ្នកដេញថ្លៃបាន មិនព្រមចរចាពិភាក្សា រៀបចំកិច្ចសន្យាដូរតាមរយៈពេលកំណត់នោះ គោលការណ៍ ឬលទ្ធផលនៃការដេញថ្លៃនឹងត្រូវទុកជាមោឃៈ ហើយប្រាក់កក់នឹងត្រូវរឹបអូសបង់ចូលថវិការរដ្ឋ។

ភាគីនៃកិច្ចសន្យាមានសិទ្ធិចុះហត្ថលេខា លុះត្រាតែលក្ខខណ្ឌទាំងអស់នៃសេចក្តីព្រាងកិច្ចសន្យា ត្រូវបានព្រមព្រៀងរវាងភាគីនៃកិច្ចសន្យា ហើយត្រូវបានពិនិត្យ កែសម្រួល និងយល់ព្រមដោយអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋជាមុនសិន ។

**មាត្រា ៣៨.-**

ការផ្ទេរកម្មសិទ្ធិពីរដ្ឋជូនឯកជន អាចធ្វើទៅបាន លុះត្រាតែមានការបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ អំពីការបង់ប្រាក់គ្រប់ចូលថវិការដ្ឋ ការបំពេញកាតព្វកិច្ចស្របតាមសៀវភៅបន្ទុកដេញថ្លៃ ឬកិច្ចសន្យាចរចាពេញគ្រប់ ការបង់ថ្លៃពន្ធប្រថាប់ត្រាគ្រប់ចំនួនជូនរដ្ឋ និងពន្ធអាករផ្សេងទៀត ។

**មាត្រា ៣៩.-**

ចំណូលដែលបានមកពីការជួលទ្រព្យសម្បត្តិរបស់រដ្ឋ អ្នកទទួលជួលត្រូវបង់ចូលថវិការដ្ឋក្នុងខ្ទង់ចំណូលផលទុននៃទ្រព្យសម្បត្តិរបស់រដ្ឋ ឬខ្ទង់ថវិកាផ្សេងទៀតតាមការកំណត់របស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

## ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ

**មាត្រា ៤០.-**

ការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ត្រូវធ្វើឡើងតាមគោលការណ៍ និងបទប្បញ្ញត្តិដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ។

វិធាន និងនីតិវិធីនៃការធ្វើអនុបយោគ ត្រូវបានកំណត់នៅក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៤១.-**

អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មានតួនាទីធ្វើការអង្កេតជាសាធារណៈ និងធ្វើរបាយការណ៍បញ្ជាក់អំពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលបានបាត់បង់លក្ខណៈសម្បត្តិរបស់ខ្លួន ក្នុងការបម្រើផលប្រយោជន៍សាធារណៈ តាមលក្ខខ័ណ្ឌដូចមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ ហើយស្នើសុំធ្វើអនុបយោគ ដោយមានភ្ជាប់សំណុំឯកសារទាំងអស់

មកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ដើម្បីពិនិត្យ និងលើកយោបល់ជូនរាជរដ្ឋាភិបាលសម្រេច តាមរយៈអនុក្រឹត្យ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា ៤២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៤៣
- ឯកសារ- កាលប្បវត្តិ